ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ផ្លូវរថភ្លើងខ្មែរក្រហម

◆ មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលាស្តីអំពី «ការសិក្សាពិសោធន៍លើហ្សែន ដើម្បីជួយព្យាបាលជំងឺមហារីក និងគំណពូជ ដល់និស្សិតផ្នែកវេជ្ជសាស្ត្រ សុខាភិបាលដែលចុះជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៩១ ខែមីនា ឆ្នាំ២០២៤

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



ប្រជាជនធ្វើការក្នុងកងចល័តក្នុងរបបខ្មែរក្រហមដើរនៅតាមបណ្ដោយផ្លូវរថភ្លើង (ឆ្នាំ១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


◆ ផ្លូវរថភ្លើងខ្មែរក្រហម ................................ ១
◆ មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលាស្ដីអំពី «ការសិក្សាពិសោធន៍ទៅលើហ្សែន ដើម្បីជួយព្យាបាលជំងឺមហារីក និងតំណពូជ .............. ១២


### ផ្នែកឯកសារ


◆ យុគ ហេង ហៅ ហៃ ៖ ប្រធានកងរថក្រោះ..... ១៥


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ ភូមិស្រែតាំងយ៉ ................................... ១៩
◆ សិស្សវិទ្យាល័យ ហ៊ុនសែនអូររាំងឪ ចូលរួមវេទិកាថ្នាក់រៀនស្ដីអំពី «ប្រវត្តិសាស្ត្រកម្ពុជា ........... ២១
◆ សិស្សមកពីវិទ្យាល័យ ក្រែក ចូលរួមវេទិកាថ្នាក់រៀនស្ដីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ........................... ២៣
◆ ង៉ែត គឿ ៖ កងចល័ត......................... ២៧
◆ ប៊ុន មុំ ៖ អតីតយុទ្ធនារីខ្មែរក្រហម ............ ២៩
◆ ង៉ែត វែន ៖ ប្រជាជនមូលដ្ឋាន ................. ៣១
◆ ញា គឿន ៖ កងចល័តដឹកប្រឡាយ ........... ៣៣
◆ សូ សុភ័ណ្ឌ ៖ អតីតកងនារីជួលជុលផ្លូវ ...... ៣៥
◆ ជា ឡូន ៖ គឺជាជនជាតិមិល និងជាអតីត ..... ៣៧
◆ អ៊ឹម វៀត គ្រូបង្រៀនកុមារនៅក្នុងសម័យ ... ៣៨


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


◆ សិស្សានុសិស្សនៃវិទ្យាល័យ ហេង សំរិនបុស្សស្រុកចូលរួមវេទិកាថ្នាក់រៀនចុងសប្ដាហ៍...... ៤០
◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្ដីអំពី «ប្រវត្តិសាស្ត្រកម្ពុជា.......... ៤៣
◆ សិស្សវិទ្យាល័យ ចារថ្មី ចូលរួមវេទិកាថ្នាក់រៀនស្ដីអំពី «ទំនាក់ទំនងការបរទេសទូទៅ .......... ៤៦
◆ សិស្សវិទ្យាល័យ ហ៊ុនសែន ស្គន់ និងវិទ្យាល័យ ហេង សំរិនបុស្សស្រុក ចូលរួម ............... ៤៨
◆ សិស្សវិទ្យាល័យ សុខអាន១ខសភា និងវិទ្យាល័យ សុខ អាន ដូងខ្ពស់ បូរីជលសារចូលរួមវេទិកា.. ៥០
◆ សិស្សវិទ្យាល័យ តាលោ ចូលរួមវេទិកាថ្នាក់រៀនស្ដីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ .. ៥៤


### ផ្នែកស្រាវជ្រាវរកគ្រួសារ


◆ ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)..... ៥៨



**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្មេរលេខនេះ ៖** ព្រំ ផល្លា, ធី គឹមហុង, ឡុង ដានី, ជឹម សុខគា, ស៊ុយ សុខមាន, ឡាំ ស្រីនីត, ជីន សុខណេង, វី ស៊ីថា, សាំង ចាន់ធូ, សួត វិចិត្រ, សុភ័ក្ត្រ ភាណា, ទូច វណ្ណេត, ង៉ាន់ វីន, មឿន ស្រីណុច និង ហង្ស ឆាំឆាន
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ផ្លូវរថភ្លើងខ្មែរក្រហម

**ព្រំ ផល្លា**




*មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្តោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ មកពីតាមបណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្តោតសំខាន់ទៅលើ«ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ មកពីតាមបណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។

**ទិដ្ឋភាពទូទៅ និងគោលបំណង៖**

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានរំឭកខួបអនុស្សាវរីយ៍លើកទី៣០ នៃអ្នកស្ម័គ្រចិត្តសហរដ្ឋអាមេរិក (Ameri Corps) ដែលជាទីភ្នាក់ងារសម្រាប់សេវាជាតិ និងការងារស្ម័គ្រចិត្ត។ ទីភ្នាក់ងារនេះបង្កើតឡើងដោយប្រធានាធិបតី គ្លីនតុន នៅឆ្នាំ១៩៩៣ ដើម្បីផ្តល់ការងារដល់ប្រជាជនសហរដ្ឋអាមេរិកនៅទូទាំងប្រទេស អាចបម្រើសហគមន៍របស់ខ្លួន មានដូចជា



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្តោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ មកពីតាមបណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ការផ្តោតទៅលើបញ្ហាប្រែប្រួលអាកាសធាតុ ការអប់រំ ការអភិរក្សភាសាកំណើត ការគាំទ្រដល់ទាហានចូលនិវត្តន៍ នៅពេលដែលគាត់ផ្លាស់ប្តូរពីភារកិច្ចយោធាទៅជាប្រជាជនស៊ីវិល និងជួយលើវិស័យយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋពេញវ័យឲ្យរស់នៅក្នុងសង្គមឡើងវិញ។

ការផុសគំនិត និងឥទ្ធិពលនៃអ្នកស្ម័គ្រចិត្តសហរដ្ឋអាមេរិកនេះ បានកើតឡើងមកលើមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយបានជ្រើសរើសអ្នកស្ម័គ្រចិត្តកម្ពុជា (CamboCorps) ដើម្បីបង្កើតនូវស្មារតីដូចគ្នានឹងសេវាកម្មជាតិ និងការងារស្ម័គ្រចិត្តសម្រាប់យុវជនកម្ពុជា។ នៅឆ្នាំ២០២១ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើសអ្នកស្ម័គ្រចិត្តកម្ពុជា ដើម្បីផ្សារភ្ជាប់យុវជនកម្ពុជាជាមួយនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងគោលបំណងឲ្យអ្នកស្ម័គ្រចិត្តកម្ពុជារៀនសូត្រពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គាំទ្រគាត់ក្នុងការទទួលបានការថែទាំ និងពិនិត្យសុខភាព ព្រមទាំងបង្កើតកិច្ចសន្ទនាអន្តរជំនាន់ដែលរួមចំណែកក្នុងការថែរក្សាប្រវត្តិសាស្ត្រកម្ពុជា។

សម្រាប់អ្នកជំនាន់មុន ដែលបានឆ្លងកាត់សង្គ្រាមលោកលើកទីពីរនៅអឺរ៉ុប ឬរបបខ្មែរក្រហមនៅប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ផ្លូវរថភ្លើង គឺជាមធ្យោបាយមួយដែលត្រូវបានប្រើប្រាស់សម្រាប់ឧក្រិដ្ឋកម្មជាប្រព័ន្ធប្រឆាំងនឹងមនុស្សជាតិ ឬ



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្តោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ មកពីតាមបណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពើប្រល័យពូជសាសន៍ តាមរយៈការជម្លៀសប្រជាជនជាច្រើនដោយបង្ខំ។

ប្រជាជនប្រហែលប្រាំមួយលាននាក់នៅអឺរ៉ុប និងពីរលាននាក់នៅកម្ពុជា ត្រូវបានបាត់បង់ជីវិត។ ស្ថានីយនីមួយៗប្រែក្លាយទៅជាទីកន្លែងកំណត់ដោគវាសនារបស់ប្រជាជន ហើយប្រជាជនទាំងអស់ត្រូវបានអស់ជីវិតនៅជុំវិញរបបណាស៊ីប្ញុវាលពិឃាតនៃរបបខ្មែរក្រហម។

ព្រឹត្តិការណ៍ទាំងនេះ បានរំឭកយើងពីការចងចាំរបស់អ្នកជំនាន់មុនអំពីរបៀប ដែលផ្លូវរថភ្លើងបានប្រើប្រាស់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅពេលនោះ។

នេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលមនុស្សជំនាន់ក្រោយមិនអាចបំភ្លេចបាន។

តាមរយៈការវិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធថ្មីៗកាន់តែកើនឡើង និងសម្រាប់អំឡុងពេលប៉ុន្មានទសវត្សរ៍ខាងមុខ ទីតាំងប្រវត្តិសាស្ត្រទាំងនេះអាចនឹងត្រូវបាត់បង់ ហើយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក៏មិនអាចបន្តប្រាប់រឿងរ៉ាវទាំងនោះបានទៀតដែរ។

ពេលនេះអាចជាឱកាសដ៏ល្អបំផុតសម្រាប់យុវជនដើម្បីធ្វើទស្សនកិច្ចសិក្សាកន្លែងប្រវត្តិសាស្ត្រដែលអំពើប្រល័យពូជសាសន៍បានកើតឡើង តាមរយៈកម្មវិធីមានឈ្មោះថា "ផ្លូវរថភ្លើងខ្មែរក្រហម៖ ទស្សនកិច្ចសិក្សាអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យសម្រាប់យុវជន ការជម្លៀសដោយបង្ខំ នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)" ដែលអ្នកស្ម័គ្រចិត្តកម្ពុជា នឹងជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដើម្បីស្តាប់ការពិត។ ដំណើរទស្សនកិច្ចសិក្សានេះមានគោលបំណងស្នូលចំនួនបី៖

## ១ - ស្វែងយល់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលត្រូវបានជម្លៀសដោយបង្ខំតាមរថភ្លើង

នៅពេលដែលខ្មែរក្រហមកាន់អំណាចគ្រប់គ្រងទីក្រុង ខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ឃោរឃៅមួយ ដោយបានបណ្តេញប្រជាជនចេញពីលំនៅដ្ឋានដោយបង្ខំ។ ការជម្លៀសនេះ បានផ្តល់ផលវិបាកដល់ផ្លូវកាយ និងផ្លូវចិត្ត និងបានបំផ្លាញសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ ជនរងគ្រោះនៃការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហមត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះដោយគ្មានហេតុផលតាមច្បាប់ជាតិ និងអន្តរជាតិ។ ដោយសារតែឧក្រិដ្ឋកម្មនេះមានភាពជាក់ស្តែង ហើយស្ទើរតែគ្រប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានឃើញ ឬជួបប្រទះដោយផ្ទាល់ ធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ងាយស្រួលក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងពីររូបគឺ នួន ជា និងខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់

មួយជីវិត ពីការជម្លៀសដំណាក់កាលទីមួយ និងទីពីរ នៅក្នុងសំណុំរឿង០០២/០១។

**ខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មជម្លៀសប្រជាជនដោយបង្ខំជាបីដំណាក់កាល៖**

**ដំណាក់កាលទីមួយ៖** គឺភ្លាមៗនៃការចូលកាន់កាប់ទីក្រុងនានា នៅថ្ងៃទី១៧ ខែមេសា ដល់ ខែកញ្ញា ឆ្នាំ១៩៧៥។ ទាហានខ្មែរក្រហមតែងតែប្រាប់ប្រជាជនតាមរយៈការណ៍កាំភ្លើងថា ចាកចេញតែបីថ្ងៃប៉ុណ្ណោះ ដើម្បីគេចពីការទម្លាក់គ្រាប់បែក បេ៥២ របស់សហរដ្ឋអាមេរិក។

**ដំណាក់កាលទីពីរ៖** គឺចាប់ពីក្រោយខែកញ្ញា ឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៧។ ប្រជាជនមកពីភូមិភាគកណ្តាល ភូមិភាគនិរតី និងភូមិភាគបូព៌ា ត្រូវបានជម្លៀសឆ្ពោះទៅកាន់ខេត្តសៀមរាប ព្រះវិហារ និងភូមិភាគពាយ័ព្យ រួមមានខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។ ប្រជាជនត្រូវបានគេប្រាប់ថាផ្លាស់ទីលំនៅដើម្បីទៅតំបន់ដែលមានអាហារច្រើន និងដីមានជីវជាតិសម្រាប់ការដាំដុះ។

**ដំណាក់កាលទីបី៖** គឺចាប់ពីចុងឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៨។ ការជម្លៀសនេះធ្វើឡើងសម្រាប់ប្រជាជនមកពីភូមិភាគបូព៌ា នៅពេលមានសង្គ្រាមកាន់តែខ្លាំងជាមួយវៀតណាម និងការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា។ អ្នកជម្លៀសទាំងនោះគឺជាកម្មាភិបាល និងទាហានខ្មែរក្រហម ត្រូវបានចោទប្រកាន់ថា ជាជនក្បត់ និងមានទំនាក់ទំនងជាមួយវៀតណាម ឬ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា និងប្រជាជនថ្មីដែលជម្លៀសមកពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗ។ ប្រជាជនភាគច្រើនគឺមកពីខេត្តព្រៃវែង និងស្វាយរៀង ត្រូវបញ្ជូនទៅខេត្តពោធិ៍សាត់ ឬខេត្តបាត់ដំបង។

អ្នកជម្លៀសត្រូវបានដឹកជញ្ជូនទៅកាន់គោលដៅចុងក្រោយ តាមរយៈមធ្យោបាយឡានដឹកទំនិញ រទេះគោ ទូករថភ្លើង ឬដោយថ្មើរជើង។ រថភ្លើងហាក់ដូចជាមធ្យោបាយអំណោយផលរបស់ខ្មែរក្រហម



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្តោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ មកពីតាមបណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រើសម្រាប់ការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី២ និងដំណាក់កាលទី៣ ទៅកាន់ខេត្តពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ។ ក្នុងទូររថភ្លើងមួយមានប្រជាជនប្រហែល១០០នាក់ ឈរចង្អៀតគ្នា ហើយសំខាន់ទៀតនោះ គឺគ្មានអាហារ និងទឹកគ្រប់គ្រាន់សម្រាប់បរិភោគ។ ដោយសារស្ថានភាពធ្វើដំណើរមានភាពអាក្រក់ ធ្វើឲ្យប្រជាជនជាច្រើនបានស្លាប់ក្នុងពេលជម្លៀសដោយបង្ខំនោះ។

**២ - បង្កើនការយល់ដឹងអំពីរឿងរ៉ាវដែលមិនបានចងក្រង ឬបោះពុម្ពផ្សាយ នៃប្រវត្តិសាស្ត្រផ្ទាល់មាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម**

ដំណើរទស្សនកិច្ចសិក្សានេះមានការចូលរួមពីអ្នកស្ម័គ្រចិត្តកម្ពុជា តាមរយៈបទពិសោធន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការចងក្រង និងផ្សព្វផ្សាយប្រវត្តិសាស្ត្រផ្ទាល់មាត់ពិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មានប្រជាជនពីរលាននាក់ បានស្លាប់ក្នុងរបបខ្មែរក្រហម ប៉ុន្តែមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណប្រាំ

លាននាក់ ដើម្បីប្រាប់ពីអ្វីដែលគាត់បានជួបប្រទះ។ ក្នុងចំណោមប្រជាជនប្រាំលាននាក់នោះ ដែលស្មើនឹង ៣៣.១៦% នៃចំនួនប្រជាជនសរុប ប្រជាជនជាច្រើនបានស្លាប់ តែនៅមានប្រជាជនមួយចំនួននៅមានជីវិត ដែលរឿងរ៉ាវរបស់គាត់នៅតែមិនទាន់បានស្តាប់ និងមិនទាន់ដឹងឮនៅឡើយ។

## ៣ - ផ្តល់ឱកាសដល់យុវជនដើម្បីស្វែងយល់ពីផ្លូវរថភ្លើង និងការធ្វើដំណើរតាមរថភ្លើងដើម្បីលើកកម្ពស់ការចូលរួមពីលទ្ធិប្រជាធិបតេយ្យ។

នៅក្នុងសម័យបច្ចុប្បន្ន រថភ្លើងត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយសម្រាប់ការធ្វើដំណើរប្រចាំថ្ងៃ និងរួមចំណែកដល់ការអភិវឌ្ឍសង្គមប្រកបដោយប្រសិទ្ធភាព និងមានតម្លៃទាប និងបញ្ចៀសផលប៉ះពាល់ដល់ បរិស្ថាន ដែលនាំមកនូវនិរន្តរភាព។

នៅប្រទេសឥណ្ឌាវិញ មានទស្សនៈមួយលើកឡើងអំពីផ្លូវរថភ្លើង ដែលបានឆ្លុះបញ្ចាំងពីចលនាដើម្បីសេរីភាពដឹកនាំដោយ មហាត្មៈ គន្ធី (Mahatma Gandhi)។ គោលការណ៍អហិង្សារបស់លោកមហាត្មៈ គន្ធី បាននាំឲ្យប្រទេសឥណ្ឌាទទួលបានឯករាជ្យពីចក្រភពអង់គ្លេស និង បានក្លាយជាប្រទេសប្រជា-ធិបតេយ្យនៅលើពិភពលោក ដែលមានប្រជាជនសរុបចំនួន ១.៤ ពាន់លាននាក់។

ទស្សនៈសំខាន់ពីរអំពីប្រវត្តិសាស្រ្តទាក់ទងនឹងផ្លូវរថភ្លើងគឺ ១).ផ្លូវរថភ្លើងនៃភាពអស់សង្ឃឹមដែលធ្លាប់ប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង ២).ផ្លូវរថភ្លើងជាសេចក្តីសង្ឃឹម សម្រាប់ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យតាមរយៈអត្ថប្រយោជន៍នៃផ្លូវរថភ្លើង។

**និសរដោ៖**

សិរីសោភ័ណ, ព្រះនេត្រព្រះ, ថ្មពួក, សិរីសោភ័ណ, និងភ្នំស្រុក ស្ថិតក្នុងផ្នែកទី៥ ភូមិភាគពាយ័ព្យ ដែលគ្រប់គ្រងដោយ រស់ ញឹម ជាលេខាភូមិភាគ ដែលមាន តា កី និងតាប៉ែត ជាអនុលេខា។

ទីតាំងដែលបានកំណត់គឺ (១) តំបន់៥ ស្ថិតនៅស្ថានីយរថភ្លើងក្រុងសិរីសោភ័ណ ដឹកនាំដោយ ម៉ែន ជុន ហៅ ហ៊ីង និង អនុលេខាតំបន់ឈ្មោះ ឆ្នាំង ហៅ ជាល ដែលជាកូនប្រុសរបស់ រស់ ញឹម។ (២) ប្រាសាទបន្ទាយឆ្មារត្រូវបានរងគ្រោះដោយសង្គ្រាមស៊ីវិលនៅឆ្នាំ១៩៧០ ដល់ឆ្នាំ ១៩៧៥ និងត្រូវបានបោះបង់ចោលនៅក្នុងរបបខ្មែរក្រហម ហើយក៏នៅតែស្ថិតនៅក្នុងតំបន់សមរភូមិនៅបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ (៣) ស្រុកព្រះនេត្រព្រះ ដែលជាកន្លែងធ្វើការក្នុងលក្ខខណ្ឌការងារដ៏ឃោរឃៅ និងដឹកនាំដោយ អាន ម៉ោង ដែលត្រូវបានសម្លាប់នៅឆ្នាំ១៩៧៧ និងបន្ទាប់មកដឹកនាំដោយ អ៊ឹម ចែម ដែលជាជនសង្ស័យក្នុងសំណុំរឿង០០៤ របស់ អ.វ.ត.ក. ដែលត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវលើឧក្រិដ្ឋកម្មនៅ ទំនប់ត្រពាំងថ្ម។ កន្លែងចុងក្រោយគឺវត្តរំលេច ស្ថិតក្នុងតំបន់២ ស្ថិតក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ វត្តរំលេច គឺជាកន្លែងសម្លាប់មនុស្សក្នុងរបបខ្មែរក្រហម។ វត្តរំលេច មានប្រជាជនខ្មែរក្រោមជាច្រើននាក់ត្រូវបានសម្លាប់ ហើយក៏មានប្រជាជនជាច្រើននាក់ដែលត្រូវបានជម្លៀសដោយបង្ខំពីខេត្តស្វាយរៀង និងខេត្តព្រៃវែង ក៏ត្រូវបានសម្លាប់ក្នុងបរិវេណវត្តនេះ។

ខាងក្រោមគឺជាមតិយោបល់របស់អ្នកស្ម័គ្រចិត្តកម្ពុជាដែលបានចូលរួមដំណើរទស្សនកិច្ចនេះ៖

### ហ៊ឹម ស្រីឡឹង

ខ្ញុំឈ្មោះ ហ៊ឹម ស្រីឡឹង ពេលខ្ញុំបានចូលរួមទស្សនកិច្ចសិក្សាតាមរថភ្លើងខ្ញុំមានអារម្មណ៍ប្លែក ព្រោះការជិះរថភ្លើងគឺជាលើកទីមួយរបស់ខ្ញុំដែលធ្វើឲ្យខ្ញុំរំភើប។ នៅម៉ោង១២ថ្ងៃត្រង់អ្នកស្ម័គ្រចិត្តកម្ពុជាទាំងអស់នៅលើរថភ្លើងមិនទាន់ទៅដល់គោលដៅនៅឡើយ។ ខ្ញុំមានអារម្មណ៍ថាក្តៅខ្លាំងណាស់ ហើយត្រូវការផឹកទឹកច្រើនដង ទាំងដឹងថានៅលើរថភ្លើងបន្ទប់ទឹកពិបាកប្រើ។ ប្រសិនបើយើងក្រឡេកមើលប្រជាជនដែលបានជម្លៀសក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ ប្រជាជនគ្មានសូម្បីតែបាយហូប នៅលើរថភ្លើងចំណែកកន្លែងអង្គុយសម្រាកប្រជៀតគ្នាមិនស្រួលដូចរថភ្លើងដែលខ្ញុំកំពុងជិះទេ។

ទស្សនកិច្ចសិក្សាតាមរថភ្លើងបានធ្វើឲ្យខ្ញុំបង្កើនទំនាក់ទំនងសមាជិកក្រុម ឲ្យមានភាពស្និទ្ធស្នាលគ្នា បង្កើតភាពសប្បាយរីករាយ ហើយខ្ញុំបានហូបអាហារជាមួយអ្នកស្ម័គ្រចិត្តកម្ពុជាផ្សេងទៀតលើរថភ្លើង។ ជាចុងក្រោយខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរៀបចំកម្មវិធីទស្សនកិច្ចសិក្សាតាមរថភ្លើងនេះឡើងដោយមានការយកចិត្តទុកដាក់មានកន្លែងស្នាក់នៅស្អាត ធ្វើឲ្យក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាមានភាពកក់ក្តៅ។

### សល់ ការ៉ាណើ

### អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តរតនគិរី

ខ្ញុំឈ្មោះ សល់ ការ៉ាណើ អាយុ២៣ឆ្នាំ គឺជាជនជាតិដើមភាគតិច ចារ៉ាយ មកពីខេត្តរតនគិរី។ ខ្ញុំគឺជាអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី១។ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤ ខ្ញុំបានទទួលឱកាសចូលរួមកម្មវិធីទស្សនកិច្ចសិក្សាតាមរថភ្លើងគឺជាដំណើរទស្សនកិច្ច «ស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជនសិក្សាឈ្វេងយល់ដោយផ្តោតទៅលើការជម្លៀសប្រជាជនដោយបង្ខំ និងជម្លៀសប្រជាជនលើកទី២ ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ កាលពីលើកមុនខ្ញុំធ្លាប់បានចូលរួមកម្មវិធីជិះរថភ្លើងម្តងរួចមកហើយដែលមានទិសដៅពីភ្នំពេញទៅខេត្តកំពត ប៉ុន្តែលើកនេះទិសដៅពីភ្នំពេញទៅ ខេត្តពោធិ៍សាត់ និង បន្តទៅខេត្តបន្ទាយមានជ័យ។

ក្នុងដំណើរទស្សនកិច្ចសិក្សាតាមរថភ្លើងនេះមានភាពផ្សេងគ្នាពីការចូលរួមលើកមុនត្រង់ខែមីនាដែលជិតឈានដល់ខែមេសា មានអាកាសធាតុក្តៅហួតហែង នៅតាមផ្លូវព្រៃព្រឹក្សា ផ្កាស្មៅ ពុំរីកស្រស់បំព្រងឡើយដោយសាររងកម្តៅថ្ងៃខ្លាំង។ ចំណែកទិដ្ឋភាពអ្នករួមដំណើរ និងលោកគ្រូ អ្នកគ្រូ ក្នុងរថភ្លើងមានសភាពក្តៅដោយសារគ្មានម៉ាស៊ីនត្រជាក់និងកង្ហារ ធ្វើឲ្យមានភាពអាប់អួ ពុំសូវស្រស់ស្រាយ។ នៅតាមផ្លូវខ្ញុំព្យាយាមសង្កេតមើលផ្ទះប្រជាជននៅអមសងខាងផ្លូវរថភ្លើង ខ្ញុំឃើញមានការលំបាកដោយសារជីវភាពខ្វះខាត។ កាលឃើញទិដ្ឋភាពបែបនេះ ធ្វើឲ្យខ្ញុំមានការអាណិតអាសូរព្រោះមើលទៅមានផ្ទះតូចៗប្រក់ស្បូវ និងស័ង្កសីដែលមិនអាចទ្រនិងអាកាសធាតុក្តៅ និងព្យុះភ្លៀងបានឡើយ។ ខ្ញុំបានប្តូរការគិតមកវិញថាតើត្រូវធ្វើ និងចូលរួមជាមួយរាជរដ្ឋាភិបាលបែបណាដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការប្រសើរឡើង។

ក្រឡេកមើលអ្នកដំណើរក្នុងរថភ្លើងមានសភាពក្តៅ និងរងនូវធូលីដី។ បើប្រៀបធៀបជាមួយការជម្លៀសប្រជាជនកាលជំនាន់ប៉ុល ពត ថាតើប្រជាជនជម្លៀសរងទុក្ខលំបាកប៉ុនណា បើក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាធ្វើដំណើរដោយមានការរៀបចំត្រឹមត្រូវកំណត់ចំនួនមនុស្ស មានអាហារហូបចុកគ្រប់គ្រាន់ និយាយថាលំបាកចុះ ទម្រាំប្រជាជនជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហមលំបាកយ៉ាងណា? ហើយអ្នកដែលមានបញ្ហាសុខភាពអាចសន្ធប់។ គិតទៅពិតជាអាណោចអាធ័មណាស់សម្រាប់ប្រជាជនកាលជំនាន់នោះ រងនូវភាពអយុត្តិធម៌បែបនេះ។ រឿងរ៉ាវសោកនាដកម្មបានផុតរលត់ទៅហើយ តើយើងយុវជនជំនាន់ក្រោយគួរធ្វើបែបណាដើម្បីកែប្រែឲ្យប្រទេសជាតិរីកចម្រើន និងកុំឲ្យវិលទៅរករបបខ្មែរក្រហមទៀត? ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់ឱកាសឲ្យខ្ញុំបានរៀនសូត្រ និងទទួលបានបទពិសោធន៍ថ្មីៗ។

### អឿន សុខ

ខ្ញុំឈ្មោះ អឿន សុខ ហើយនេះគឺជាលើកទីមួយដែលខ្ញុំបានធ្វើដំណើរទស្សនកិច្ចសិក្សាតាមរថភ្លើង។ ខ្ញុំគិតថាទស្សនកិច្ចសិក្សានេះប្លែកសម្រាប់ខ្ញុំមុនពេលជិះរថភ្លើងខ្ញុំគិតថារថភ្លើងគឺមិនឈប់ច្រើនដងនោះទេ ហើយអ្នកបើកបរលឿន និងរលាក់ខ្លាំង។ ប៉ុន្តែជាក់ស្តែងខុសពីការគិតទុករបស់ខ្ញុំ រថភ្លើងបើកយឺតជាងឡានដោយសារល្បឿនរថភ្លើង គឺបើកថេររហូត។ មួយទៀតខ្ញុំទទួលបានពីការធ្វើដំណើរនេះគឺយើងអាចមើលទេសភាពហើយមានអារម្មណ៍ដូចជាស្និទ្ធស្នាលជាមួយធម្មជាតិ។ ខ្ញុំគិតថារថភ្លើងប្រសិនបើជិះខែវស្សាប្រហែលកាន់តែមើលឃើញទេសភាពស្អាតជាងនេះ។

## ជា សាន់ណា

### អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តពោធិ៍សាត់

ខ្ញុំឈ្មោះ ជា សាន់ណា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី១ មកពីខេត្តពោធិ៍សាត់។ បន្ទាប់ពីខ្ញុំបានធ្វើដំណើរទស្សនកិច្ចសិក្សាស្តីពីអំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ខ្ញុំមានអារម្មណ៍រំភើបសប្បាយរីករាយជាខ្លាំងព្រោះបានធ្វើដំណើរជាក្រុមៗ ទោះបីជាក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាជួបការលំបាកខ្លះៗរថភ្លើងរលាក់និងអាកាសធាតុក្តៅ និងមានធូលីនិងដីហុយ ប៉ុន្តែយើងអាចអង្គុយបានស្រួល មានទឹកដឹក មានបាយហូបគ្រប់គ្រាន់។ ភាពខុសគ្នាត្រង់ចំណុចនេះបានធ្វើឲ្យខ្ញុំគិតស្រមៃទៅដល់រឿងរ៉ាវរបស់លោកតាលោកយាយ អ៊ំ ពូមីង ដែលរស់រានមានជីវិតពីរបបប៉ុល ពត តើគាត់លំបាកយ៉ាងណាទៅ បើសម័យនោះធ្វើដំណើរមិនដឹងគោលដៅច្បាស់លាស់ ថាខ្លួនត្រូវខ្មែរក្រហមយកទៅណា ទូរថភ្លើងមានមនុស្សច្រើនណែន រកកន្លែងអង្គុយគ្មាន គ្មានអាហារបរិភោគគ្រប់គ្រាន់។ នេះហើយធ្វើឲ្យខ្ញុំគិតរួចសម្លឹងមើលទៅផ្លូវរថភ្លើង ហើយខ្ញុំមានអារម្មណ៍សោកសៅជាខ្លាំង នឹកអាណិតដល់ឪពុករបស់ខ្ញុំដែលបាត់បង់ឪពុក (ជីតារបស់ខ្ញុំ) តាំងពីគាត់នៅក្មេងដោយសារតែរបបប៉ុល ពត។ រឿងនេះក៏បានជំរុញឲ្យខ្ញុំចង់ចេះ ចង់យល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមយ៉ាងខ្លាំង ដើម្បីអាចប្រាប់អ្នកដទៃអំពីផលវិបាកសោកនាដកម្មក្នុងរបបខ្មែរក្រហម និងធ្វើឲ្យខ្ញុំមានការតស៊ូក្នុងជីវិត និងទប់ស្កាត់កុំឲ្យមានរឿងរ៉ាវបែបនេះកើតឡើងទៀត។

## ខាំ ស៊ូខែ

### អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តរតនគិរី

ខ្ញុំឈ្មោះ ខាំ ស៊ូខែ គឺជាអ្នកស្ម័គ្រចិត្តជំនាន់ទី១ មកពីខេត្តរតនគិរី។ នាព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា បានធ្វើដំណើរចេញពីសណ្ឋាគារ រ៉ាយ ខនើរ ដោយរៀបចំឡើងរថយន្តក្រុងដើម្បីបន្តដំណើរទៅកាន់ស្ថានីយរថភ្លើងក្នុងក្រុងភ្នំពេញ។ ម៉ោង៥និង៤៥នាទីព្រឹក ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាក៏បានមកដល់ស្ថានីយដោយសុវត្ថិភាព។ ជាមួយគ្នានេះដែរ ក្រុមការងារក៏បានថតរូបជុំគ្នា។ ម្នាក់ៗសប្បាយរីករាយយ៉ាងក្រៃលែង ព្រោះអ្នកខ្លះធ្លាប់ជិះ អ្នកខ្លះក៏មិនធ្លាប់ជិះរថភ្លើងដោយធ្លាប់តែនឹកស្រមៃរូបភាព។ ក្រុមយុវជនស្ម័គ្រចិត្តទាំង៨ជំនាន់ដែលមកពីខេត្តផ្សេងៗបានមកជួបជុំគ្នានៅទីនេះ។ យុវជនមកពីក្រុង ស្រុកផ្សេងៗ ក៏បានរាក់ទាក់គ្នាដោយក្តីគោរព និងរីករាយ ដោយអ្នកខ្លះធ្លាប់ស្គាល់គ្នាពីមុនមកដែរ។ នៅវេលាម៉ោង៦ និង៥០នាទី រថភ្លើងចាប់ផ្តើមបន្លឺសំឡេងដើម្បីឲ្យជាសញ្ញាដល់អ្នកដំណើរទូទៅថារថភ្លើងត្រៀមនឹងបើកចេញទៅ និងឲ្យត្រៀមលក្ខណៈ។ ពេលរថភ្លើងចេញពីស្ថានីយនៅអមសងខាងផ្លូវខ្ញុំឃើញមានអគារខ្ពស់ៗ ផ្ទះប្រជាជនតូចធំស្អាតៗ រថភ្លើងក៏បន្លឺសំឡេងជាបន្តបន្ទាប់ឲ្យអ្នកនៅខាងមុខបានដឹង និងប្រុងប្រយ័ត្នកុំធ្វើដំណើរឆ្លងផ្លូវ។ ពេលចេញដំណើរ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាសប្បាយរីករាយជាមួយដំណើរទស្សនកិច្ចដែលអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឱកាស ក៏ដូចជាបានបង្កើតនូវកម្មវិធីនេះឡើង។ ធ្វើដំណើរបានមួយសន្ទុះធំ ខាងក្រុមការងារក៏បានចែកនូវអាហារសម្រន់ម្នាក់មួយកញ្ចប់។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលបានចូលរួម និងស្គាល់ពីការធ្វើ



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្តោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ មកពីតាមបណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដំណើរតាមរថភ្លើងនេះ។ រថភ្លើងបើកមកជិតដល់ភូមិស្រែព្រិត នៅតាមដងផ្លូវអមដោយរុក្ខជាតិគ្រប់ប្រភេទ វាលស្រែ មានដើមត្នោតដុះឈរនិងកោងទៅតាមធម្មជាតិ។ រថភ្លើងក៏បន្តផ្លង់ និងជៀសផ្លូវគ្នាជាមួយរថភ្លើងដែលដឹកអីវ៉ាន់មកពីប្រទេសថៃជាច្រើនទូ។ ក្រុមយុវជនខ្លះដេក ខ្លះអានសៀវភៅ ខ្លះលេងល្បែងកម្សាន្តយ៉ាងសប្បាយរីករាយ។ នៅវេលាម៉ោង១០និង៣៥នាទីរថភ្លើងបានឈប់សម្រាកដើម្បីឲ្យភ្ញៀវទិញរបស់របរ ក៏ដូចជា បត់ដៃបត់ជើងនៅស្ថានីយពោធិ៍សាត់។ អ្នកលក់ដូរជាច្រើនមានទឹកមុខរីករាយក្នុងការលក់ដូរប្រកបដោយសុជីវធម៌។ បន្តមកទៀតនៅវេលាម៉ោង១២និង៣០នាទីក្រុមការងារបានចែកអាហារថ្ងៃត្រង់ និងហូបនៅលើរថភ្លើង។ មកដល់ស្ថានីយរថភ្លើង «រាជាយស្ម័យយានខេត្តបាត់ដំបង» មានភាពអ៊ូអរ និងរីកចម្រើនជាការកត់សម្គាល់ តែមេឃបញ្ចេញកម្ដៅក្ដៅជាខ្លាំងដល់ទៅ៣៥អង្សា។ ពេលនេះក៏បានធ្វើឲ្យខ្ញុំនឹកឃើញរឿងរ៉ាវកាលពីសម័យខ្មែរក្រហម ដោយក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា មានអាហារហូបគ្រប់គ្រាន់ ប៉ុន្តែគួញថាពិបាក ចុះទម្រាំប្រជាជនកម្ពុជាជម្លៀសដោយបង្ខំកាលនោះមិនដឹងជាលំបាកយ៉ាងណានោះទេ។ បើតាមរយៈការអាន និងសិក្សាសៀវភៅប្រវត្តិសាស្ត្រ, សៀវភៅសាក្សីប្រវត្តិសាស្ត្រ និងសៀវភៅការជម្លៀសប្រជាជនដោយបង្ខំនៅសម័យខ្មែរក្រហម។ កាលនោះដែលប្រជាជនសែនលំបាកវេទនា ដោយក្នុងមួយទូៗដាក់ប្រជាជនរាប់រយនាក់ ដោយមិនមានទឹក មិនមានអាហារហូប និងរងកម្ដៅ។ ប្រជាជនដែលឡើងជិះរថភ្លើងមិនទាន់ត្រូវដាក់ទណ្ឌកម្ម ហើយយកទៅសម្លាប់ចោលក៏មានដែរ។ ខ្ញុំគិតស្រមៃមើល ម៉ោង៤ល្ងាច រថភ្លើងបានមកដល់ចំណតសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដោយសុវត្ថិភាព។ ការធ្វើដំណើរដ៏វែងឆ្ងាយនេះ បានឆ្លងកាត់ខេត្តចំនួន៣គឺខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ដែលជាខេត្តគោលដៅនៃក្រុមការងារចុះមកទស្សនកិច្ច។ ពេលចុះពីរថភ្លើង ម្នាក់ៗអស់កម្លាំងហត់ហេវដោយសារតែអាកាសធាតុក្ដៅ។

ខ្ញុំធ្លាប់ជាក្មេងរស់នៅតែក្នុងខេត្ត និងស្រុករបស់ខ្លួន គឺមិនដែលស្គាល់នូវទឹកដីខេត្តផ្សេងៗ ពិសេសមិនដែលស្គាល់ទីក្រុងភ្នំពេញ។ ចាប់តាំងពីខ្ញុំបានចូលជាអ្នកស្ម័គ្រចិត្តកម្ពុជា នៃអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាមក បានធ្វើឲ្យខ្ញុំមានឱកាស និងបានស្គាល់ទីកន្លែងផ្សេងក្នុងប្រទេស ពិសេសបានឃើញនិងបានជិះរថភ្លើង។ ខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ដែលបានមានឱកាសចូលរួមនូវដំណើរទស្សនកិច្ចនេះ។ ខ្ញុំពិតជាអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានរៀបចំទស្សនកិច្ចសិក្សាអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ហើយផ្ដល់ឱកាសឲ្យខ្ញុំបានរៀនសូត្រ និងបានស្គាល់នូវយុវជនមកពីបណ្ដាខេត្តផ្សេងៗ។



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិប-តេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្ដោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ មកពីតាមបណ្ដាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## កើត សុរចនា
## អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង

ខ្ញុំឈ្មោះ កើត សុរចនា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី១មកពីខេត្តស្វាយរៀង។ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤ ខ្ញុំបានធ្វើដំណើរទស្សនកិច្ចសិក្សាអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិប-តេយ្យជាមួយអ្នកស្ម័គ្រចិត្តកម្ពុជា ទាំង៨ជំនាន់តាម

រថភ្លើងពីភ្នំពេញឆ្ពោះទៅកាន់ស្ថានីយរថភ្លើងក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។ អំឡុងពេលធ្វើដំណើរ ខ្ញុំបានអាននូវប្រវត្តិក៏ដូចជាសាច់រឿងខ្លះៗរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់បានឆ្លងកាត់ ការជម្លៀសតាមរថភ្លើងជាមួយក្រុមគ្រួសាររបស់គាត់ ក៏ដូចជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលខ្ញុំធ្លាប់បានធ្វើការសម្ភាសន៍សាច់រឿងនៅក្នុងភូមិរបស់ខ្ញុំ។ ប្រជាជនកម្ពុជាត្រូវបានខ្មែរក្រហមជម្លៀសពីតំបន់មួយទៅតំបន់មួយតាមរថភ្លើង។

រឿងរ៉ាវដែលប្រជាជនកម្ពុជាបានឆ្លងកាត់ពិតជាលំបាក គ្រួសារខ្លះត្រូវបែកបាក់គ្នា ទៅធ្វើការកន្លែងផ្សេងៗ តាមការចាត់តាំងរបស់ខ្មែរក្រហម ហើយគ្រួសារខ្លះទៀតត្រូវបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់ដោយមិនបានរស់នៅជុំគ្នា។ មានគ្រួសារខ្លះទៀតត្រូវវង្វេងសមាជិកគ្រួសារអំឡុងពេលជម្លៀសតាមរថភ្លើងដែរ។ តាមរយៈការអានសាច់រឿងក៏ដូចជាធ្លាប់បានសម្ភាសន៍អ្នករស់រានមានជីវិតដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ខ្ញុំពិតជាពិបាកទទួលយកណាស់ និងបានបង្ហាញអំពីក្ដីឈឺចាប់នៃការព្រាត់ប្រាស់ បាត់បង់សមាជិកគ្រួសារ។ បើនិយាយអំពីដំណើរទស្សនកិច្ចសិក្សាអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យនេះ សម្រាប់ខ្ញុំផ្ទាល់យល់ថា ការធ្វើដំណើរមានការសម្របសម្រួល រៀបចំ និងគាំទ្រយ៉ាងច្រើនពីមជ្ឈមណ្ឌលឯកសារកម្ពុជា ទាំងការធ្វើដំណើរ ស្នាក់នៅ ការហូបចុក និងការគិតគូរពីសុខភាព ថ្វីត្បិតតែការធ្វើដំណើរនេះមានការនឿយហត់តិចតួច ប៉ុន្តែខ្ញុំគិតថាមិនអាចប្រៀបបាននឹងការជម្លៀសប្រជាជនក្នុងរបបខ្មែរក្រហមទេ។ ប្រជាជនខ្លះត្រូវឃ្លាតឆ្ងាយពីផ្ទះសម្បែងភូមិកំណើតទៅរស់នៅតំបន់ផ្សេងដែលខ្លួនមិនស្គាល់ ទាំងភ័យខ្លាច ដោយសារតែធ្វើទៅតាមខ្មែរក្រហមបញ្ជា។ ពេលធ្វើដំណើរប្រជាជននឿយហត់ស្រេកឃ្លានដោយសារមិនមានការផ្គត់ផ្គង់អាហារគ្រប់គ្រាន់ និងមានបញ្ហាសុខភាព ប៉ុន្តែប្រជាជននៅតែស៊ូទ្រាំ។ ប្រជាជនត្រូវទៅរស់នៅតំបន់ផ្សេងៗដោយមិនដឹងអំពីគោលដៅ និងការងារពិតប្រាកដឡើយ ហើយត្រូវរស់នៅបែកពីក្រុមគ្រួសារ ក្រោមការគាបសង្កត់ និងពុំមានសិទ្ធិសេរីភាព។

## យ៉ុង ផល្លីន

ខ្ញុំឈ្មោះ យ៉ុង ផល្លីន អាយុ១៩ឆ្នាំ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ មកពីខេត្តក្រចេះ។ ខ្ញុំពិតជាអរគុណសម្រាប់ការធ្វើដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» តាមរថភ្លើង ដែលបានផ្ដល់ឱកាសឲ្យខ្ញុំបានសិក្សាតាមរយៈការជិះរថភ្លើងជាលើកទីមួយសម្រាប់ខ្ញុំ។ ខ្ញុំរីករាយដោយមើលឃើញទេសភាពជាច្រើន ក៏ដូចជាភ្នំ វាលស្រែ ប៉ុន្តែ ខែមីនា នេះមានអាកាសធាតុក្ដៅដែលជាបទពិសោធន៍មួយសម្រាប់ខ្ញុំដែរ។ ការជិះរថភ្លើងដើម្បីសិក្សាពីរបបខ្មែរក្រហមដែលជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងខេត្តផ្សេងៗ។ ការជម្លៀសតាមរថភ្លើងនេះពិតជាពិបាកណាស់សម្រាប់ប្រជាជាជន ដែលនៅតែអាល័យផ្ទះសម្បែងរបស់ខ្លួន។ ការជិះរថភ្លើងគឺមានមនុស្សច្រើនហើយក្ដៅថែមទៀត។ ការធ្វើដំណើតាមរយៈរថភ្លើងពេលនេះមានការរៀបចំសម្ភារគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏ខ្ញុំគិតថានៅជួបការលំពិបាក ចុះទម្រាំនៅអំឡុងរបបខ្មែរក្រហមមានការជម្លៀសប្រជាជនដោយបង្ខំគឺពិតជាមានភាពលំបាកខ្លាំងណាស់ ប្រឈមមុខទៅនឹងកង្វះអាហារ ទឹក និងមិនមានកន្លែងស្នាក់នៅត្រឹមត្រូវ។

## ញុក ទៅ

### អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តក្រចេះ

ខ្ញុំឈ្មោះ ញុក ង៉ៅ ភេទប្រុស អាយុ២៥ឆ្នាំ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ មកពីខេត្តក្រចេះ។ ខ្ញុំពិតជាអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ការរៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» ដោយជិះតាមរថភ្លើង។ ការជិះរថភ្លើងនេះគឺជាលើកទីមួយសម្រាប់ខ្ញុំ។

នៅក្នុងដំណើរទស្សនកិច្ចសិក្សានេះ ខ្ញុំបានទៅ

ទស្សនាប្រាសាទបន្ទាយឆ្មារ ប៉ុន្តែជាអកុសល ខ្ញុំឃើញប្រាសាទមានសភាពបែកបាក់ជាច្រើន ដោយសារសង្គ្រាម ធម្មជាតិ និងអាយុកាលរបស់ប្រាសាទ។ ប្រាសាទដែលនៅមានរូបរាងល្អសេសសល់ប្រហែលប្រមាណ២០ភាគរយតែប៉ុណ្ណោះ។ ខ្ញុំពិតជាសោកស្ដាយខ្លាំងណាស់ចំពោះប្រាសាទដែលដូនតាបានកសាងទុកឲ្យកូនចៅជំនាន់ក្រោយបានឃើញស្នាដៃដ៏អស្ចារ្យ។

## វេន ចិន្តា

ខ្ញុំឈ្មោះ វេន ចិន្តា អាយុ២១ឆ្នាំ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ មកពីខេត្តកំពង់ស្ពឺ។ ខ្ញុំសូមអរគុណដល់លោកគ្រូ អ្នកគ្រូ និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានរៀបចំដំណើរទស្សនកិច្ចសិក្សាអំពី«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជន ផ្ដោតសំខាន់ទោះលើការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ដោយធ្វើដំណើរតាមរយៈរថភ្លើងដែលចេញពីរាជធានីភ្នំពេញ ទៅខេត្តពោធិ៍សាត់- ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ ខ្ញុំមិនធ្លាប់បានជិះរថភ្លើងពីមុនមកទេ។ ខ្ញុំមានអារម្មណ៍ប្លែកពេលឃើញផ្ទះប្រជាជន វាលស្រែ ភ្នំ និងឃើញការរស់នៅរបស់ប្រជាជននៅតាមទីជនបទ។ ប៉ុន្តែនៅពេលដែលជិះយូរៗទៅអារម្មណ៍សប្បាយក៏ចាប់ផ្ដើមរសាត់ទៅបន្តិចម្ដងៗ ព្រោះខ្ញុំឃើញផ្ទះរបស់ប្រជាជនមួយចំនួនមានសភាពទ្រុឌទ្រោម ដំបូលប្រក់ស័ង្កសីស្របពេលអាកាសធាតុក្ដៅខ្លាំង។ ចំណែកនាងខ្ញុំនៅក្នុងទូរថភ្លើងវិញមានអារម្មណ៍ក្ដៅស្អុះស្អាប់ដោយសារអាកាសធាតុនៅពេលនេះស្ថិតក្នុងរដូវប្រាំងដែលជារដូវក្ដៅខ្លាំង។ ខ្ញុំអង្គុយក៏ពិបាកដោយសាររថភ្លើងបរទៅមុខរលាក់ខ្លាំង។ ទន្ទឹមនឹងការលំបាកនេះ នាងខ្ញុំបានស្រមៃទៅទិដ្ឋភាពក្នុងរបបខ្មែរក្រហមដែលបានជម្លៀសប្រជាជនដោយបង្ខំតាមរយៈរថភ្លើង ហើយផ្ទុកមនុស្សជាច្រើននាក់ក្នុងមួយទូៗ។ តើប្រជាជនជម្លៀសមានអារម្មណ៍បែបណា ស្របពេលអាកាសធាតុក្ដៅខ្លាំង? ប្រជាជនក្នុងទូរថភ្លើងមាន



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្ដោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ មកពីតាមបណ្ដាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចំនួនច្រើន និងគ្មានអាហារសម្រាប់ហូប ហើយត្រូវធ្វើដំណើរវែងឆ្ងាយទៀត ទាំងនេះពិតជាលំបាកខ្លាំងណាស់ មិនគួរណាមានរបបបែបនេះកើតឡើងក្នុងប្រទេសកម្ពុជាទេ។ ដោយឡែកក្នុងដំណើរទស្សនកិច្ចនេះ ក្រុមការងារបានរៀបចំអាហារ ទឹក និងដាក់អ្នកស្ម័គ្រចិត្តកម្ពុជានៅក្នុងទូរថភ្លើងមានចំនួនកំណត់ ហើយខ្ញុំនៅតែមានអារម្មណ៍ថាពិបាក ចុះទម្រាំប្រជាជនជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម។

នៅក្នុងដំណើរទស្សនកិច្ចនេះ នាងខ្ញុំក៏បានទៅទស្សនកិច្ចនៅប្រាសាទបន្ទាយឆ្មារដែរ។ នាងខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយជាខ្លាំង ពីព្រោះមិនធ្លាប់បានមកទីកន្លែងនេះពីមុនមក។ ទន្ទឹមនឹងការសប្បាយរីករាយ នាងខ្ញុំក៏មានអារម្មណ៍សោកស្ដាយព្រោះប្រាសាទបន្ទាយឆ្មារមានសភាពទ្រុឌទ្រោមស្ទើរតែគ្មានរូបរាងជាប្រាសាទទៅហើយ។ សង្គ្រាមបានបំផ្លិចបំផ្លាញសម្បត្តិដែលជាកេរមរតកបុរាណរបស់បុព្វបុរសខ្មែរដែលខិតខំកសាងតាំងពីបុរាណកាល។ ក្នុងនាមខ្ញុំជាយុវជនខ្មែរ ខ្ញុំនឹងសិក្សាពីប្រវត្តិសាស្ត្ររបស់ប្រទេសឲ្យបានច្រើន និងចូលរួមថែរក្សាប្រាសាទបុរាណដែលនៅសេសសល់កុំឲ្យមានការបាត់បង់តទៅទៀត។

ជាចុងក្រោយ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌល

ឯកសារកម្ពុជាដែលបានរៀបចំកម្មវិធីទស្សនកិច្ចសិក្សានេះឡើង ដែលអាចឲ្យខ្ញុំបានសិក្សាពីរបបខ្មែរក្រហមកាន់តែច្បាស់ថែមទៀត។ ខ្ញុំសង្ឃឹមថានឹងមានកម្មវិធីបែបនេះបន្តទៀត ដើម្បីឲ្យអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់បានឈ្វេងយល់បន្ថែមពីរបបខ្មែរក្រហម។

## ភឿន លីណា

ខ្ញុំឈ្មោះ ភឿន លីណា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា។ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤ គឺជាថ្ងៃដំបូង ដែលខ្ញុំបានចូលរួមក្នុងការធ្វើដំណើរទស្សន-កិច្ចតាមរយៈការជិះរថភ្លើង ពីភ្នំពេញទៅកាន់ខេត្តពោធិ៍សាត់ និងចេញពីពោធិ៍សាត់ បន្តដំណើររហូតដល់ខេត្តបន្ទាយមានជ័យ ក្រោមប្រធានបទការជម្លៀសដោយបង្ខំនៅក្នុងរបបខ្មែរក្រហម។ ក្នុងដំណើរទស្សនកិច្ចសិក្សានេះ ខ្ញុំទទួលបានបទពិសោធន៍ជាច្រើនទាំងភាពសប្បាយរីករាយ និងការបង្កើតទំនាក់ទំនង។ ម្យ៉ាងវិញទៀត ខ្ញុំទទួលបានការចែករំលែកនូវបទពិសោធន៍ពីតាយាយ អ៊ំពូមីងដែលបានឆ្លងកាត់ការជម្លៀសក្នុងរបបខ្មែរក្រហម ហើយនៅរស់រានមានជីវិតមកដល់សព្វថ្ងៃ។ ពេលជិះរថភ្លើងពេលនេះ ខ្ញុំក៏មានអារម្មណ៍ឈឺចុករោយពេញខ្លួន ប៉ុន្តែបើប្រៀបធៀបជាមួយនឹងរបបខ្មែរក្រហមដែលជម្លៀសប្រជាជនដោយបង្ខំ ដែលមិនមានកន្លែងអង្គុយស្រួល ជាមួយមនុស្សណែនណាន់តាន់តាប់ មិនមានអាហារ អាកាសធាតុក្តៅ និងគ្មានសម្ភារគ្រប់គ្រាន់នោះគឺពិតជាលំបាកខ្លាំងណាស់។ ខ្ញុំពិតជារំភើប និងពេញចិត្តដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជា-ធិបតេយ្យ» ដែលអាចឲ្យខ្ញុំបានសិក្សារៀនសូត្រពីកម្មវិធីនេះ។



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ ដោយផ្តោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)» ដល់អ្នកស្ម័គ្រចិត្តកម្ពុជា ចំនួន៦៨នាក់ មកពីតាមបណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលា ស្ដីអំពី «ការសិក្សាពិសោធន៍ទៅលើហ្សែន ដើម្បីជួយព្យាបាលជំងឺមហារីក និងគំណពូជ ដល់និស្សិតផ្នែកវេជ្ជសាស្ត្រសុខាភិបាលដែលចុះជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

សោម ប៊ុនថន




ក្រុមការងាររគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំសិក្ខាសាលាលើកទី៥ ស្ដីអំពី «តើការសិក្សាពីហ្សែន នឹងចូលរួមចំណែកដូចម្ដេចទៅលើការថែទាំសុខភាពរបស់អ្នកជំងឺមហារីក និងគំណពូជឲ្យកាន់តែល្អប្រសើរឡើង?» ដល់និស្សិតផ្នែកវេជ្ជសាស្ត្រសុខាភិបាល ចំនួន៨០នាក់ មកពីសាកលវិទ្យាល័យសុខាភិបាល សាលាពេទ្យទាហាន សាកលវិទ្យាល័យអន្តរជាតិ សាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងសាកលវិទ្យាល័យន័រតុន ប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា ដោយមានការចូលរួមពីវាគ្មិន វេជ្ជបណ្ឌិត ម៉ាណុប ភិធុផាកន គឺជាសាស្ត្រាចារ្យផ្នែកវេជ្ជសាស្ត្រ និង មន្ទីរពិសោធន៍ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រ មន្ទីរពេទ្យសិរិរាជ សាកលវិទ្យាល័យម៉ាហ៊ីឌុល ប្រទេសថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងាររគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំសិក្ខាសាលា ស្ដីអំពី«តើការសិក្សាពីហ្សែន នឹងចូលរួមចំណែកដូចម្ដេចទៅលើការថែទាំសុខភាពរបស់អ្នកជំងឺមហារីក និងជំងឺគំណពូជឲ្យកាន់តែល្អប្រសើរឡើង?» ដល់និស្សិតផ្នែកវេជ្ជសាស្ត្រសុខាភិបាលចំនួន៨០នាក់ មកពីសាកលវិទ្យាល័យសុខាភិបាល សាលាពេទ្យទាហាន សាកលវិទ្យាល័យអន្តរជាតិ សាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងសាកលវិទ្យាល័យន័រតុន ប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារ កាំបូឌីយ៉ាណា

ដោយមានការចូលរួមពីវាគ្មិន វេជ្ជបណ្ឌិត ម៉ាណុប ភិធុផាកន គឺជាសាស្ត្រាចារ្យផ្នែកវេជ្ជសាស្ត្រ និងមន្ទីរពិសោធន៍ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រ មន្ទីរពេទ្យសិរិរាជ សាកលវិទ្យាល័យម៉ាហ៊ីឌុល ប្រទេសថៃ និងជាអតីតក្រុមប្រឹក្សាភិបាលវេជ្ជសាស្ត្រសេនេទិច នៅប្រទេសអាមេរិក ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៧។

នេះគឺជាសិក្ខាសិលាលើកទី៥ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជួយដល់និស្សិតពេទ្យកម្ពុជាឲ្យមានការយល់ដឹងកាន់តែទូលំទូលាយអំពីការសិក្សាទៅលើហ្សែន និងការធ្វើតេស្តស្វែងរកជំងឺផ្សេងៗ ជាពិសេស ជំងឺមហារីកដែលឆ្លងតាមហ្សែនរបស់មនុស្ស ដែលអាចជួយដល់ការព្យាបាលជំងឺមហារីក និងជំងឺតំណពូជដែលកើតឡើងទៅលើប្រជាជនកម្ពុជា ជាពិសេសដើម្បីជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងតែប្រឈមនឹងជំងឺទាំង១០យ៉ាង រួមមាន ១) ជំងឺលើសឈាម ២) ជំងឺក្រពះពោះវៀន ៣) ជំងឺគ្រុនចាញ់ ៤) ជំងឺផ្លូវចិត្ត ៥) ជំងឺបេះដូង ៦) ជំងឺឈឺសន្លាក់ ៧) ជំងឺហឺតរ៉ាំរ៉ៃ ៨) ជំងឺទឹកនោមផ្អែម ៩) ជំងឺរបេង និង១០) ជំងឺស្ពឹកតជ្រុក ដែលក្រុមការងារផ្នែកសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញក្នុងចំណោមមនុស្សដែលមានវ័យចាប់ពី៥៥ឆ្នាំឡើងទៅ ប្រមាណជាង៣២,០០០នាក់ ដែលបានផ្តល់បទសម្ភាសន៍ទាក់ទងនឹងសុខភាព។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះកំពុងតែប្រឈមនឹងបញ្ហាសុខភាព ហើយឈានដល់សភាពធ្ងន់ធ្ងរ និងបណ្តាលឲ្យស្លាប់បាត់បង់ជីវិត ប្រសិនបើមិនមានការថែទាំ និងព្យាបាលឲ្យបានត្រឹមត្រូវតាមវេជ្ជបញ្ជា។

នៅក្នុងសិក្ខាសាលាព្រឹកនេះ វេជ្ជបណ្ឌិត ម៉ាណុប ភិធុផាកនបានលើកឡើងអំពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីដើម្បីធ្វើតេស្តទៅលើសេនេតិច ដែលអាចឲ្យគ្រូពេទ្យដឹងអំពីជំងឺដែលកើតឡើងដោយសារហ្សែនរបស់មនុស្ស ឬកើតឡើងដោយសារជំងឺតំណពូជ ជាពិសេសជំងឺមហារីក ដើម្បីប្រើប្រាស់ថ្នាំព្យាបាលឲ្យបានត្រឹមត្រូវទៅតាមប្រភេទជំងឺ។ វេជ្ជបណ្ឌិត ម៉ាណុប ភិធុផាកនបានបន្តថា សព្វថ្ងៃ គ្រូពេទ្យមួយចំនួននៅ






ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំសិក្ខាសាលាលើកទី៥ ស្តីអំពី «តើការសិក្សាពីហ្សែន នឹងចូលរួមចំណែកដូចម្តេចទៅលើការថែទាំសុខភាពរបស់អ្នកជំងឺមហារីក និងតំណពូជឲ្យកាន់តែល្អប្រសើរឡើង?» ដល់និស្សិតផ្នែកវេជ្ជសាស្ត្រសុខាភិបាល ចំនួន៨០នាក់ មកពីសាកលវិទ្យាល័យសុខាភិបាល សាលាពេទ្យទាហាន សាកលវិទ្យាល័យអន្តរជាតិ សាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងសាកលវិទ្យាល័យន័រតុន ប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា ដោយមានការចូលរួមពីវាគ្មិន វេជ្ជបណ្ឌិត ម៉ាណុប ភិធុផាកន គឺជាសាស្ត្រាចារ្យផ្នែកវេជ្ជសាស្ត្រ និង មន្ទីរពិសោធន៍ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រ មន្ទីរពេទ្យសិរិរាជ សាកលវិទ្យាល័យម៉ាហ៊ីឌុល ប្រទេសថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រើវិធីសាស្ត្រទូទៅនៅឡើយនៅក្នុងការព្យាបាលជំងឺ ជាពិសេសគឺ ជំងឺលើសឈាម និងទឹកនោមផ្អែម ដែលបណ្តាលមកពីជាតិស្ករកើនឡើងជារៀងរាល់ថ្ងៃ ឬជំងឺមហារីក ដែលកើតឡើងទៅលើគ្រួសារដែលមានប្រវត្តិធ្លាប់កើតជំងឺនេះពីមុនមក ឬម្យ៉ាងទៀតកើតឡើងដោយសារការប្រព្រឹត្តរបស់ខ្លួនឯងផ្ទាល់

ដូចជា ការទម្លាប់ដក់បារីប្រចាំថ្ងៃដែលបណ្តាលឲ្យកើតជំងឺមហារីកសួត និងការទម្លាប់ហូបអាហារឆៅដែលបណ្តាលឲ្យកើតជំងឺមហារីកក្រពះ ពោះវៀនជាដើម។ ជំងឺមហារីកសុដន់ភាគច្រើនកើតលើស្រ្តីដែលមានវ័យចាប់ពី៥០ឆ្នាំឡើងទៅ ហើយក្នុងចំណោមនោះក៏កើតលើបុរសប្រមាណ៥ភាគរយផងដែរ។

រីឯ ជំងឺតំណពូជ គឺជាជំងឺកំណត់ដោយហ្សែនលើក្រូម៉ូសូម ហើយត្រូវបានបញ្ជូនផ្ទាល់ពីឪពុកម្តាយទៅឲ្យកូនពុំមានរំលងជំនាន់ឡើយ។ ជំងឺតពូជមានពីរប្រភេទគឺ ជំងឺតពូជលើក្រូម៉ូសូមធម្មតា និងលើក្រូម៉ូសូមភេទ។ ចំណែកក្រូម៉ូសូម គឺជាទម្រង់ឆ្នូរៗរាងសរសៃអំបោះដែលកើតពី អាស៊ីតដេអុកស៊ីរីបូនុយក្លេអិច (DNA) និងប្រូតេអ៊ីនដែលផ្ទុកព័ត៌មានសេនេទិច។

វេជ្ជបណ្ឌិត ម៉ាណុប ភិធុផាកនបានលើកឡើងថា នៅក្នុងប្រទេសរបស់លោក រដ្ឋាភិបាលបានបង្កើតកម្មវិធីសុខភាព (ការធ្វើតេស្តទៅលើហ្សែន) ថ្នាក់ជាតិ និងបានបង្កើតមន្ទីរពិសោធន៍យ៉ាងធំអស់រយៈពេល៥ឆ្នាំមកហើយ និងបានប្រមូលសំណាក (ទិន្នន័យ) ពីប្រជាជនប្រមាណជាង៥ម៉ឺននាក់នៅតាមមន្ទីរពេទ្យដើម្បីសិក្សា ហើយក្នុងចំណោមសំណាកទាំងនោះ ក៏អាចមានជនជាតិខ្មែរប្រមាណ២៥ភាគរយដែរដែលទៅពិនិត្យសុខភាពនិងព្យាបាលជំងឺក្នុងប្រទេសថៃដែរ។ លោកបន្តថា ទៅថ្ងៃអនាគតនឹងមានការធ្វើតេស្ត និងសិក្សាពិសោធន៍ទៅលើ DNA (គឺជាម៉ូលេគុលដែលអនុវត្តការណែនាំអំពីហ្សែនសម្រាប់ការអភិវឌ្ឍន៍មុខងារ ការលូតលាស់ និងការបន្តពូជនៃសារពាង្គកាយមានជីវិតទាំងអស់) ដើម្បីឲ្យដឹងរាល់ព័ត៌មាននៅក្នុងខ្លួនមនុស្ស ដែលអាចលូតលាស់ទៅជាជំងឺនៅពេលខាងមុខ ដើម្បីធ្វើការទប់ស្កាត់ជាមុន។

ចុងក្រោយ វេជ្ជបណ្ឌិត ម៉ាណុប ភិធុផាកន លើកឡើងថា ការបង្កើតកម្មវិធីសិក្សាទៅលើហ្សែនជាពិសេសការស្វែងរកជំងឺមហារីកដែលឆ្លងតាមហ្សែន នឹងមានប្រយោជន៍ខ្លាំងណាស់ដល់ប្រជាជនគ្រប់ជាតិសាសន៍ ដើម្បីបង្ការជំងឺ និងព្យាបាលជំងឺឲ្យបានត្រឹមត្រូវ។





វេជ្ជបណ្ឌិត ម៉ាណុប ភិធុផាកន គឺជាសាស្ត្រាចារ្យផ្នែកវេជ្ជសាស្ត្រ និង មន្ទីរពិសោធន៍ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រ មន្ទីរពេទ្យសិរិរាជ សាកលវិទ្យាល័យម៉ាហ៊ីឌុល ប្រទេសថៃ ជួបលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងទស្សនកិច្ចព្រះរាជបណ្ណាល័យហ្វូងម៉ែ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុត ហេង ហៅ ហៃ ៖ ប្រធានកងវរសេនាតូច

ដារ៉ារដ្ឋ មេត្តា



យោធាខ្មែរក្រហមនៅសមរភូមិ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យុត ហេង ហៅ ហៃ ភេទប្រុស អាយុ ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៧។ ខ្ញុំមានគ្រួសារឈ្មោះ ជិន លី។ ខ្ញុំកើតនៅភូមិព្រៃភ្លាំង ឃុំដំរីពួន ស្រុកព្រៃវែង (បច្ចុប្បន្នស្រុកស្វាយអន្ទរ) ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ អ៊ាង និង ម្តាយឈ្មោះ យ៉ុន។ នៅឆ្នាំ១៩៧៧ ឪពុកម្តាយខ្ញុំរស់នៅភូមិស្ដី ឃុំស្ដី ស្រុកចំការលើ ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូនចំនួន ១២នាក់ ក្នុងនោះមានប្រុសចំនួន៨នាក់ និងស្រីចំនួន៤នាក់។ នៅពេលខ្ញុំមានអាយុ៨ឆ្នាំ ម្តាយខ្ញុំយកខ្ញុំទៅរៀននៅវត្តភ្នំគង់ ស្ថិតនៅឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង អស់រយៈពេល២ឆ្នាំ។ នៅពេលខ្ញុំអាយុ១០ឆ្នាំ ឪពុកម្តាយ ខ្ញុំបានបញ្ជូនខ្ញុំឲ្យទៅរៀននៅសាលាឯករាម នៅក្នុងក្រុងព្រៃវែង។ នៅពេលនោះខ្ញុំរស់នៅជាមួយអ៊ំឈ្មោះ យឹម គឺជាស្ត្រីមេម៉ាយរស់នៅក្បែរវត្តសំសមី ក្រុងព្រៃវែង ខេត្តព្រៃវែង។ នៅទីនោះ ខ្ញុំបានចូលរៀនពីថ្នាក់ទី១០ ដល់ថ្នាក់ទី៧ (សង្គមចាស់)។ នៅក្នុងឆ្នាំ១៩៦២ ខ្ញុំប្រឡងចូលរៀននៅវិទ្យាល័យព្រះអង្គឌួង ក្រុងព្រៃវែង។ នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំប្រឡងឌីប្លូមជាប់ និងរៀននៅវិទ្យាល័យព្រះអង្គឌួងដដែល។ នៅសាលាខ្ញុំបានស្គាល់ សំអុល, លីម, អេន, យ៉ែន ព្រោះយើងរៀនថ្នាក់ទី២ នៅវិទ្យាល័យអង្គឌួងជាមួយគ្នា។

នៅខែសីហា ឆ្នាំ១៩៦៧ ខ្ញុំចូលរៀននៅថ្នាក់ទី១ នៅវិទ្យាល័យព្រះអង្គឌួង។ ខ្ញុំកាន់តែមានការជិតស្និទ្ធជាមួយឈ្មោះ ឡឿន, សំអុល, លីម និង អេន ហើយអ្នកទាំងនេះបានឲ្យសៀវភៅ ចម្រើន មកខ្ញុំ

អានដា ហូរហែ។ នៅខែកញ្ញា ឆ្នាំ១៩៦៧ ខ្ញុំចូលបដិវត្តន៍តាម ឈ្មោះ ខឿន, សំអុល, លីម និង អេន ហើយអ្នកទាំងនេះបានអប់រំខ្ញុំអំពីខ្លឹមសារបដិវត្តន៍ និងដាក់វិធានការឲ្យខ្ញុំអូសខិត្តប័ណ្ណប្រឆាំងនឹងសម្តេចព្រះ នរោត្តម សីហនុ និងបរិវារ។ នៅខែកុម្ភៈ ឆ្នាំ១៩៦៨ ខឿនបានបញ្ជូនឈ្មោះ គ្រុឌ ឲ្យទៅជួយធ្វើការនៅក្រុងព្រៃវែង ប៉ុន្តែ គ្រុឌ បានរត់ចូលសារភាពជាមួយខ្មាំង។ ពេលបែកការណ៍ ខ្ញុំ, សំអុល និង លីម ចេញពីសាលាអង្គខួង ហើយរត់មកកំពង់ចាម។ ខ្ញុំជាមួយឈ្មោះ ខឿន, ខឹម និង លាន បានទៅនៅភូមិស្ថិតនៅខាងលិចនាងគង្ហីង ខេត្តកំពង់ចាម។ ក្រោយមកខ្ញុំបានទៅនៅភូមិថ្មគោល ជាមួយឈ្មោះ សេង។ ខ្ញុំក្លែងប្រវត្តិរូបជាក្មេងកំព្រា គ្មានឪពុកម្តាយ មានតែបងប្អូន២នាក់ រកស៊ីលក់នំបុ័ងដើម្បីចិញ្ចឹមជីវិត។ ពេលខ្ញុំនៅភូមិថ្មគោល ខឿន ចេញចូលផ្ទះខ្ញុំជាញឹកញាប់ និងអូសទាញខ្ញុំឲ្យបែកចេញពីបដិវត្តន៍។

នៅខែតុលា ឆ្នាំ១៩៦៧ ខ្ញុំឈប់នៅផ្ទះជាមួយសេង ហើយខ្ញុំមករស់នៅជាមួយបងសឿង (គ្រួសាររបស់បង ពក) វិញ។ ភារកិច្ចរបស់ខ្ញុំនៅជាមួបងសឿង គឺធ្វើជានីរសារដើម្បីជូនផ្លូវមិត្តយើងចេញពីក្រុងភ្នំពេញ និងនាំអាវុធពីក្រុងទៅភូមិភាគឧត្តរ និងភូមិភាគ៥០៥។ នៅខែមេសា ឆ្នាំ១៩៦៩ ខ្ញុំឈប់នៅផ្ទះជាមួយបង សឿង ហើយខ្ញុំមករស់នៅក្នុងមន្ទីរជាមួយឈ្មោះ ឈឿន, លំ និង នូ វិញ។ ក្រោយមកឈ្មោះ លាន បានខ្ទេសនាមឈ្មោះ ភី មកឲ្យខ្ញុំគ្រប់គ្រង។ លាន ប្រាប់ខ្ញុំឲ្យខិតខំអូសទាញឈ្មោះ ភី ព្រោះគាត់មានបងប្អូនចូលធ្វើបដិវត្តន៍ច្រើនដែរ។ នៅខែតុលា ឆ្នាំ១៩៦៧ ខ្ញុំបានសម្រេចផែនការដោយចាត់តាំងឈ្មោះ ភី គឺជា សេ-អ៊ី-អា។ នៅខែវិច្ឆិកា ឆ្នាំ១៩៦៧ ដដែល អង្គការចាត់តាំងខ្ញុំឲ្យទៅធ្វើទូក ហើយពេលនោះ ខឿន និង ខ្ញុំ ទៅរកទិញទូកដល់កោះឧកញ៉ាតី។

នៅខែមីនា ឆ្នាំ១៩៧០មុនរដ្ឋប្រហារ ខ្ញុំនិង សាន អង្គុយនិយាយគ្នានៅលើខ្សាច់ជាប់មាត់ទឹកក្នុងភូមិកោះឧកញ៉ាតី។ ខ្ញុំនិយាយថាបដិវត្តន៍លំបាកណាស់ បែកឆ្ងាយពីបងប្អូនគ្មានថ្ងៃជួបមុខគ្នាទេ ហើយក៏មិនសង្ឃឹមឈ្នះដែរព្រោះខ្វះមុខខ្វះក្រោយ។ នៅខែឧសភា ឆ្នាំ១៩៧០ ខ្ញុំសម្រេចផែនការអូសទាញឈ្មោះ សាន។ ក្រោយមកខ្ញុំលើកផែនការជាមួយសាន ដើម្បីទាក់ទង ភឿង និង ផាត គឺជាសិស្សអត់ការងារធ្វើនៅកោះឧកញ៉ាតី។ នៅពាក់កណ្តាលខែមិថុនា ឆ្នាំ១៩៧០ ខ្ញុំចាប់បានចំណុចខ្សោយរបស់ ភឿន និង ផាត រឿងអត់មានការងារធ្វើហើយខ្ញុំបានប្រាប់ថាត្រូវធ្វើជា សេ-អ៊ី-អា ទើបមានលុយចាយមិនរហេមរហាម។ ចុងក្រោយ ភឿន និង ផាត បានប្តេជ្ញាចូលរួមក្រុម សេ-អ៊ី-អា ជាមួយខ្ញុំ។ ខ្ញុំបានយកប្រាក់អង្គការបដិវត្តន៍សម្រាប់ខ្ញុំធ្វើទុនរកស៊ីចំនួន៤000រៀល ទៅឲ្យអ្នកទាំងពីរនាក់នោះ។ បន្ទាប់មកខ្ញុំដាច់ខ្សែរយៈពីឈ្មោះ ខឿន និង ឈឿន ជាច្រើនខែដូច្នេះទិសការងារខាងមុខមិនដឹងត្រូវអនុវត្តយ៉ាងណាទេ។ នៅខែសីហា ឆ្នាំ១៩៧០ ខ្ញុំសម្រេចចិត្តទៅរកឈ្មោះ ខឿន,ឈឿន ដើម្បីទទួលការណែនាំ និងលើកទិសដៅការងារខាងមុខ។ ខ្ញុំចេញពីកោះឧកញ៉ាតីទៅក្រុងកំពង់ចាម ជួបជាមួយឈ្មោះ លំ។ លំ ផ្ញើខ្ញុំជាមួយប្រជាជនភូមិគៀនជ្រៃ ស្រុកកំពង់សៀម ដើម្បីទៅតំបន់រំដោះជួបជាមួយ ខឿន។ ខ្ញុំបានទៅដល់ភូមិស្រែវាលតាមរយៈនីរសាររបស់ស្រុកកំពង់សៀម។ ខ្ញុំបានជួប ខឿន ហើយពេលឃើញខ្ញុំ គាត់សប្បាយរីករាយណាស់ ព្រោះគាត់ចង់ជួបខ្ញុំយូរមកហើយ។ វេលាយប់ម៉ោង៨ ខឿន បានឲ្យខ្ញុំរាយការណ៍ និងនិយាយតិចៗនៅក្នុងបន្ទប់របស់គាត់អំពីសកម្មភាពខ្ញុំនៅទូក។ ខឿន ប្រាប់ភារកិច្ចថ្មីរបស់ខ្ញុំគឺត្រូវនាំគ្នាចូលមកតំបន់រំដោះ ទាំងអស់គ្នាដើម្បីធ្វើសកម្មភាពស៊ីរូងផ្ទៃក្នុងបក្សកុម្មុយនីស្ត ព្រោះខ្ញុំអាចសម្របខ្លួនបាន នឹងមិនបែកមុខបែកមាត់ទេ (បែកការណ៍សម្ងាត់ សេ-អ៊ី-អា)។ បញ្ហាទូកគាត់សម្រេចឲ្យខ្ញុំលក់ក្នុងតម្លៃប៉ុន្មានក៏បានដែរ គឺធ្វើយ៉ាងម៉េចបានចេញទៅតំបន់រំដោះឆាប់ៗ។ នៅខែកញ្ញា ឆ្នាំ១៩៧០ ទូកក៏លក់ដាច់ហើយខ្ញុំសល់សម្ភារប្រើប្រាស់មួយចំនួនបានលើកយកទៅផ្ញើនៅផ្ទះ ភឿង និង ផាត។ ខ្ញុំទិញវិទ្យុ១គ្រឿង កង់ប្រុស២ និងទិញនំល្អៗតាមការផ្តាំផ្ញើរបស់ ខឿន។

នៅពាក់កណ្តាលខែមករា ឆ្នាំ១៩៧១ ឈឿន បានបញ្ជូនខ្ញុំទៅនៅមន្ទីរតំបន់១៣០ ក្រោមការគ្រប់គ្រងរបស់មន្ទីរភូមិភាគដដែល។ ពេលនោះខ្ញុំបានទទួលតួនាទីគឺជាប្រធាននីរសារ និងជាជំនួយការខាងសេដ្ឋកិច្ចតំបន់១៣០ ដែលមានឈ្មោះ ហែម យ៉ន គឺជាប្រធាន។ ហែម យ៉ន បានប្រគល់ភារកិច្ចឲ្យខ្ញុំកសាងឈ្មោះ វ៉ាន់ ឲ្យបាន។ វ៉ាន់ គឺជាប្រធាននីរសារប្រចាំភូមិបន្ទីតាំងរ៉ែ ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ មានភារកិច្ចជូនផ្លូវភ្ញៀវចុះឡើង ដឹកបន្លែ អង្ករ ពីស្ទឹងជីនិត ទៅមន្ទីរក២៥ (មន្ទីរភូមិភាគខត្តរ)។ នៅខែមិថុនា ឆ្នាំ១៩៧១ ខ្ញុំត្រូវឈ្មោះ ឈឿន ឲ្យវិលទៅមន្ទីរភូមិភាគវិញព្រោះសភាពជំងឺខ្ញុំបានធូរស្រាលហើយ នៅញាក់តែម្តងម្កាលតែប៉ុណ្ណោះ។ ម្យ៉ាងទៀតនៅមន្ទីរ១៣០ ក៏មានឈ្មោះ សាន នៅមើលការខុសត្រូវហើយ។ ឯឈ្មោះ ហែម យ៉ន ក្រោយមកក៏ចេញទៅធ្វើជាលេខាស្រុកកំពង់ស្វាយ។ នៅមន្ទីរភូមិភាគខ្ញុំមាននាទីជាប្រធាន។ ឈ្មោះ ឈឿន មាននាទីជំនួយការរបស់ភូមិភាគ។ សកម្មភាពរបស់ខ្ញុំនៅក្នុងមន្ទីរក២៥ គឺបង្កជាបក្ខពួកទំនាស់គ្នានៅក្នុងគណៈមន្ទីរ។ ក្រោយមក ឃួន, ឈឿន បានពង្រឹងក្រុមសិល្បៈដោយឲ្យឈ្មោះ ម៉ម, កែវ, ព្រាប, អ៊ាង (គណៈកម្មាធិការភូមិភាគ) គឺជាអ្នកដើររើសតាមតំបន់ស្រុក ដើម្បីយកតួឯកស្អាតៗ។ គោលដៅពង្រីកសិល្បៈនេះកាន់តែពុករលួយរវាងបុរសនារី។

នៅខែមករា ឆ្នាំ១៩៧២ ខ្ញុំត្រូវបាន ឃួន ហៅទៅធ្វើការហើយពេលនោះ ឃួន បានបញ្ជាក់ប្រាប់ខ្ញុំថា ខ្ញុំត្រូវនៅក្រសួងភ័ស្តុភារភូមិភាគខត្តរ។ មុនខ្ញុំចេញដំណើរមួយថ្ងៃ ឃួនបានហៅខ្ញុំ, សែ, ឆុន, ហង់, សាន, សម្បត្តិ ទៅចូលរួមជប់លៀងកន្លែងគាត់នៅមន្ទីរជ-៧ ក្នុងព្រៃកៅស៊ូចម្ងាយពីស្រែវាល១០ គីឡូម៉ែត្រ ដើម្បី លាលែងតំណែង ខ្ញុំឈប់ធ្វើប្រធានមន្ទីរ ហើយឈ្មោះ សែ ឡើងជាប្រធានមន្ទីរជំនួសវិញ។ ចំណែកផ្នែក សេ-អ៊ី-អា ឃួនបញ្ជាក់ថា ខ្ញុំត្រូវផ្តាច់ខ្សែពីមន្ទីរដោយ សែ ត្រូវទទួលខុសត្រូវផ្ទាល់ដោយមានឈ្មោះ ឃួន ទទួលក្តាប់ សេ-អ៊ី-អា ពីលើ សែ។ ឃួនណែនាំក្រុមខ្ញុំកុំទាក់ទងគ្នាឲ្យសោះ ដើម្បីកុំឲ្យបែកការណ៍ ហើយត្រូវរក្សាការសម្ងាត់ សេ-អ៊ី-អា ឲ្យបានដាច់ខាត។ ព្រលឹមឡើងឈ្មោះ ឃួនបានជួបឈ្មោះ រដ្ឋ, សួ ធ្វើការនៅមន្ទីរភូមិភាគខត្តរ ពេលនោះ ឃួន បានចាត់តាំងគណៈកម្មាធិការភ័ស្តុភារ ភូមិភាគខត្តរ មានឈ្មោះ រដ្ឋ គឺជាប្រធាន, ខ្ញុំគឺជាអនុប្រធាន និង សួ គឺជាសមាជិក។ រួចឈ្មោះ ឃួន បានបែកសមរភូមិឲ្យយើងទទួលខុសត្រូវរៀងៗខ្លួន គឺ ឈ្មោះ រដ្ឋ និង ឈ្មោះ សួ ប្រចាំសមរភូមិកំពង់ធំ ហៅភ១៩ ហើយខ្ញុំប្រចាំសមរភូមិកំពង់ចាម ហៅ ភ១៨។ ពេលរសៀលថ្ងៃនោះ ឃួនបានហៅខ្ញុំ និងឈ្មោះ រដ្ឋ ទៅធ្វើការជាសម្ងាត់នៅផ្ទះគាត់ សម្រាកដើម្បីគាត់បញ្ជាក់ពីភារកិច្ចខ្ញុំទាំងពីរនាក់ ដែលជា សេ-អ៊ី-អា ត្រូវស៊ីរូងឲ្យជ្រៅក្នុងក្រសួងភ័ស្តុភារ ភូមិភាគខត្តរ។ ខ្ញុំត្រូវធ្វើយ៉ាងណាឲ្យរាំងស្ទះដល់សមរភូមិមុខ។ ក្រោយពីការណែនាំរបស់ ឃួន ខ្ញុំនិង រដ្ឋ បានចេញពីមន្ទីរជ៧ (មន្ទីរភូមិភាគខត្តរ) មកសម្រាកនៅភូមិស្ទឹ ឃុំស្ទឹស្រុកបំការលើ ក្នុងផ្ទះមួយកណ្តាលភូមិស្ទឹ ដើម្បីធ្វើជាមន្ទីរភ័ស្តុភារ ភ១៨ គឺជាភ័ស្តុភារប្រចាំសមរភូមិកំពង់ចាម។

នៅខែកុម្ភៈ ឆ្នាំ១៩៧២ ខ្ញុំចេញចូលទៅតាមកងវរសេនាតូច ដែលបោះទីតាំងការពារផ្លូវជាតិលេខ៦និងលេខ៧។ ពេលនោះខ្ញុំស្គាល់ឈ្មោះ សួង គឺជាប្រធានកងពល៤៥០ ដោយគាត់មានតួនាទីគឺជាប្រធានយោធាវរសេនាតូច៣១១។ នៅខែមេសា ឆ្នាំ១៩៧២ រដ្ឋ ហៅខ្ញុំឲ្យទៅប្រជុំជាមួយគាត់នៅមន្ទីរ ភ១៩ (មន្ទីរភ័ស្តុភារប្រចាំសមរភូមិកំពង់ធំ) ប្រចាំនៅកំពង់ថ្ម ចម្ងាយ៣០០ម៉ែត្រខាងជើងវត្តកំពង់ថ្ម ដើម្បីសួរពីកម្លាំង សេ-អ៊ី-អា និងក្តាប់សភាពការណ៍នៅភ័ស្តុភារនៅភ១៨ ឲ្យបានមួយរយភាគរយ។ នៅខែកក្កដា ឆ្នាំ១៩៧២ ខ្ញុំបានសម្រេចផែនការរបស់ សេ-អ៊ី-អា គឺទាក់ទងឈ្មោះ ឈិន, រ៉ុម ដោយមានខ្ញុំគឺជាអ្នកទទួលស្គាល់ និងឈ្មោះ មានណា គឺជាអ្នកខទ្ទេសនាម។

នៅខែសីហា ឆ្នាំ១៩៧២ សមរភូមិកំពង់ធំចាប់ផ្តើមវាយសម្រុកខ្លាំង តាមការណែនាំរបស់



*យោធាខ្មែរក្រហមនៅសមរភូមិ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*អង្គការក៏ឲ្យសមរភូមិកំពង់ចាម ចាប់ផ្ដើមវាយដែរ។ ខ្ញុំ, ណា, ឈិត បាននៅសមរភូមិតាំងគោក ដើម្បីបម្រើការងារភ័ស្ដុភារនៅសមរភូមិ។ ខ្ញុំសម្រាកនៅភូមិសណ្ដែកទ្រព្យ ក្នុងស្រុកជើងព្រៃ ហើយខ្ញុំក៏បានជួបជាមួយឈ្មោះ សំអុល គឺជាសេ-អ៊ី-អា ចាស់ ទទួលជាអនុលេខាស្រុកជើងព្រៃ។ យើងត្រូវជាមិត្តចាស់ សំអុល បានរៀបចំជប់លៀងឲ្យខ្ញុំ មានកាប់គោ ធ្វើមាន់ និងមានស្រាដែលអ្នកភូមិបិត។ រយៈពេលមួយថ្ងៃក្រោយមកឈ្មោះ ស្រេង គឺជាបញ្ជាការសមរភូមិ បានហៅខ្ញុំទៅជួបដោយសម្ងាត់ និងលើកឡើងថា «ត្រូវណែនាំទៅឈ្មោះ ណា ឲ្យពិនិត្យមើលអ្នករបួសបើល្មមៗបង្ហើយទៅដើម្បីកុំឲ្យមានកម្លាំងវាយយូរ»។*

*នៅខែមិថុនា ឆ្នាំ១៩៧៣ ខ្ញុំទទួលបានសំបុត្រមួយច្បាប់ពីឈ្មោះ រដ្ឋ ហើយខ្លឹមសារគឺប្រាប់ខ្ញុំអំពីកងទ័ពវាយនៅកំពង់ធំត្រូវដកពីកំពង់ធំទៅវាយនៅផ្លូវជាតិលេខ៦និង៧។ នៅដើមខែកក្កដា ឆ្នាំ១៩៧៣ ខ្ញុំបានចេញទៅសមរភូមិខាងជើងផ្លូវជាតិលេខ៦និង៧។ ពេលកងទ័ពបដិវត្តន៍វាយរំដោះចន្លោះផ្លូវស្គន់ រហូតដល់ព្រែកក្ដាម បក្ខពួកខ្ញុំបានអនុវត្តផែនការបំផ្លិចបំផ្លាញកម្លាំងកងទ័ព។ នៅខែសីហា ឆ្នាំ១៩៧៣ ផែនការអង្គការសម្រេចវាយផ្ដាច់ស្គន់តាំងគោក ព្រៃទទឹង ហើយរុញខ្លាំងឲ្យចូលក្រុងកំពង់ចាម ឲ្យបានយ៉ាងយូររយៈពេល១ខែក្នុងខែសីហា នេះ។ នៅចុងខែសីហា ឆ្នាំ១៩៧៣ ក្រុងកំពង់ចាម ត្រូវឯកោកម្រិតខ្ពស់ ហើយទិសអង្គការត្រូវវាយផ្ដាច់ក្រុងកំពង់ចាមឲ្យបាន។ ពេលនោះ ឃួន បានអញ្ជើញគណៈតំបន់៤១, ៤២ គណៈភ័ស្ដុភារ គណៈបញ្ជាការវរសេនាតូចទាំងអស់ ទាំងតំបន់ទាំងចល័តភូមិភាគទៅធ្វើការដើម្បីលើកវិធានការវាយផ្ដាច់តាមសំណូមពររបស់អង្គការ។ នៅខែកញ្ញា ឆ្នាំ១៩៧៣ សមរភូមិវាយផ្ដាច់ក្រុងកំពង់ចាម ចាប់ផ្ដើម។ ពេលនោះសកម្មភាពរបស់ ឈិត គឺមិនដឹកអង្ករឲ្យកងទ័ពហូបទាន់ពេលទេ។ អាហារប្រចាំថ្ងៃ ឈិត ចែកតែពោតក្រហមដោយយកលេសថាអង្ករដឹកមិនទាន់ពោតទេ ព្រោះលំបាកដឹកមកដោយសារភ្លៀងច្រើន ហើយទឹកទន្លេឡើងខ្លាំង។*

*នៅខែមករា ឆ្នាំ១៩៧៤ កងទ័ពបានវាយដាច់ផ្លូវជាតិលេខ១៥ ពីព្រែកក្ដាមរហូតដល់ពាមសត្ថាវត្តសំរោងខាងជើងវត្តគ្រួស។ ឈិត បានបោះទីតាំងនៅខាងជើងស្ពានពាមសត្ថាប្រហែល៣០០ម៉ែត្រ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៤ ខ្មាំងវាយបុកមកដណ្ដើមផ្លូវជាតិលេខ១៥យ៉ាងខ្លាំង។*

*នៅក្នុងចម្លើយសារភាពរបស់ ឃុត ហេង ហៅ ហៃ មានកម្រាស់៦០ទំព័រ ប៉ុន្តែមិនបានរៀបរាប់ពីមូលហេតុនៃការចាប់ខ្លួនរបស់គាត់ឡើយ ដោយសារខ្លឹមសារនៅត្រង់ទំព័រខ្លះបានបាត់ក្រោយរបបខ្មែរក្រហមដួលរលំ។*

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ J០០៥២០។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ឃុត ហេង ហៅ ហៃ ពិតប្រាកដយ៉ាងណានោះទេ?***

# ភូមិស្រែតាំងយ៉

ធី គីមហុង



ភូមិស្រែតាំងយ៉ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(ធី គីមហុង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិស្រែតាំងយ៉ គឺជាភូមិខបសម្ព័ន្ធមួយក្នុងចំណោមភូមិទាំង៩ នៃឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ភូមិស្រែតាំងយ៉មានប្រជាជនសរុបចំនួន ៩៦៨ នាក់ ក្នុងនោះមានស្រី៤៩១នាក់ និង ស្ត្រីមេម៉ាយចំនួន១៩គ្រួសារ។ ពាក់កណ្ដាលនៃចំនួនប្រជាជនសរុប គឺជាយុវជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ ភូមិស្រែតាំងយ៉មានព្រំប្រទល់ ខាងកើតជាប់ភូមិទួលគ្រួស ខាងលិចជាប់ភូមិដូននាគ ខាងជើងជាប់ភូមិស្រែយក្ស និងខាងត្បូងជាប់ដងស្ទឹងប្រម៉ោយ។ តាមការសាកសួរនឹងរៀបរាប់ពីមេភូមិស្រែតាំងយ៉ ឈ្មោះ គុជ ញិល បានឲ្យដឹងថា កាលពីមុនសង្គ្រាមស៊ីវិលឆ្នាំ១៩៧០ ភូមិស្រែតាំងយ៉ គឺជាឈ្មោះឃុំស្រែតាំងយ៉នៃស្រុកភ្នំក្រវាញ។ ពេលនោះឃុំស្រែតាំងយ៉ មានប្រជាជនរស់នៅប្រហែលជា៥០ទៅ៦០គ្រួសារ ដែលជាជនជាតិដើមភាគតិចព័រ ជនជាតិដើមភាគតិចជង និងជនជាតិខ្មែរ។ កាលនោះប្រជាជនរស់នៅឆ្ងាយៗពីគ្នាដោយប្រកបរបរធ្វើចម្ការ និងដាំស្រូវដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ចំពោះម្ហូបអាហារគឺប្រជាជនភាគច្រើនចេញទៅបរបាញ់សត្វនៅក្នុងព្រៃយកទុកជាអាហារប្រចាំថ្ងៃ។

នៅចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ពេលប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលខ្មែរ

ក្រហមបានចូលមកបង្កើតចលនាតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរនៅក្នុងឃុំស្រែតាំងយ៉ៗ ប្រជាជនភាគច្រើនត្រូវខ្មែរក្រហមឃោសនាឲ្យចូលបម្រើក្នុងចលនាកងទ័ពខ្មែររំដោះរបស់ខ្លួនៗ នៅរវាងពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ ខ្មែរក្រហមបានយកទីតាំងមួយក្នុងឃុំស្រែតាំងយ៉បង្កើតជាស្រុកពាមព្រួស តំបន់៦ ភូមិភាគពាយ័ព្យៗ បន្ទាប់ពីឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឃុំស្រែតាំងយ៉ក៏ដូចជា ភូមិ ឃុំ ផ្សេងទៀត ក្នុងស្រុកភ្នំក្រវាញ ត្រូវបានខ្មែរក្រហមបង្ខំឲ្យរស់នៅជាសហករណ៍ គឺត្រូវធ្វើការងារពលកម្មរួម ហូបចុករួម និងស្នាក់នៅរួមគ្នាៗ នៅអំឡុងឆ្នាំ១៩៧៧ ប្រជាជននៅក្នុងឃុំស្រែតាំងយ៉ និងស្រុកពាមព្រួសទាំងមូលត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំឲ្យទៅរស់នៅ ខាងស្រុកភ្នំក្រវាញ ស្រុកបាកាន និង ស្រុកមោងឫស្សីៗ

ក្រោយឆ្នាំ១៩៧៩ ប្រជាជនជម្លៀសទាំងនោះបានបន្តរស់នៅក្នុងស្រុកភ្នំក្រវាញ និងស្រុកមួយចំនួនទៀតក្នុងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ដោយសារឃុំស្រែតាំងយ៉បានក្លាយជាសមរភូមិក្តៅ និងមានការប្រយុទ្ធគ្នាជាញឹកញាប់រវាងកងទ័ពខ្មែរក្រហម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលសហការជាមួយកងទ័ពវៀតណាមៗ ចាប់តាំងពីមានសមាហរណកម្មរបស់កងកម្លាំងខ្មែរក្រហមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៧ និងឆ្នាំ១៩៩៨ ទើបមានប្រជាជនខ្លះដែលជាជនជាតិដើមភាគតិចព័រ និងខ្លះទៀតជាជនជាតិខ្មែរមកពីខេត្តកំពត ខេត្តតាកែវ និងមកពីខាងទន្លេសាបចូលមករស់នៅក្នុងភូមិស្រែតាំងយ៉នេះបណ្តើរៗៗ បន្ទាប់ពីសង្គ្រាមស៊ីវិលចប់ភ្លាមៗ នៅតាមផ្លូវសម្បូរណ៍ទៅដោយគ្រាប់មីនបង្កប់ក្នុងដីដែលបណ្តាលឲ្យប្រជាជនមានការពិបាកក្នុងការប្រកបមុខរបរធ្វើស្រែចម្ការ ដូច្នេះប្រជាជនភាគច្រើនដើររើសជ័រ និងកាប់ឈើលក់ឲ្យឈ្មួញៗ ក្រោយមកទើបមានការដោះគ្រាប់មីន ហើយប្រជាជនអាចប្រកបមុខរបរធ្វើស្រែចម្ការរហូតដល់បច្ចុប្បន្នៗ





ភូមិស្រែតាំងយ៉ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ៗ
(ធី គឹមហុង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យ ហ៊ុន សែន អូររាំងឪ

## ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ផ្តោតលើប្រធានបទ «ទំនាក់ទំនងការបរទេស និងភាពបរាជ័យ

*សុភ័ក្ត្រ ភាណា*



នៅរសៀលថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ សិស្សានុសិស្សថ្នាក់ទី១២ ចំនួន៦០នាក់ មកពីវិទ្យាល័យអូររាំងឪ បានចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ សិស្សានុសិស្សថ្នាក់ទី១២ ចំនួន៦០នាក់ មកពីវិទ្យាល័យអូររាំងឪ បានចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ វេទិកាថ្នាក់រៀននៅក្នុងថ្ងៃនេះ ផ្តោតសំខាន់ទៅលើប្រធានបទ«ទំនាក់ទំនងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ និងកត្តាដែលចូលរួមចំណែកនៅក្នុងភាពបរាជ័យនៃរបបនេះ»។

នៅមុនពេលចាប់ផ្តើមវេទិកាថ្នាក់រៀន សិស្សានុ-សិស្សបានស្តាប់ការពន្យល់បកស្រាយពីលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម អំពីពិព័រណ៍រូបថតដែលត្រូវបានដាក់តាំងបង្ហាញនៅក្នុងថ្នាក់ៗ ពិព័រណ៍ដែលតាំងបង្ហាញទាំងនេះបានផ្តល់នូវព័ត៌មានប្រវត្តិសាស្ត្រ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០ ដល់ទសវត្សរ៍ឆ្នាំ១៩៨០ ដោយផ្តោតជាពិសេសលើប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ពិព័រណ៍ទាំងនោះក៏បាននាំលេច



នៅរសៀលថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ សិស្សានុសិស្សថ្នាក់ទី១២ ចំនួន៦០នាក់ មកពីវិទ្យាល័យអូររាំងឪ បានចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារកោះថ្មៗ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់ពាក់ព័ន្ធទៅនឹងការដួលរលំនៃរបបខ្មែរក្រហមថែមទៀតផង។

បន្ទាប់ពីការបកស្រាយអំពីពិព័រណ៍បានបញ្ចប់ទៅ គ្រូខ្ទេស សុភ័ក្ត្រ ភាណា បានធ្វើបទបង្ហាញអំពីការវិភាគលម្អិតអំពីនយោបាយការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បទបង្ហាញរំលេចអំពីផ្នត់គំនិតនៃទំនាក់ទំនងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយផ្តោតទៅលើការសម្រេចចិត្តសំខាន់ៗធ្វើឡើងនៅក្នុងរបបនោះ និងផលវិបាកនៃសេចក្តីសម្រេចចិត្តទាំងនោះ។

តមក គ្រូខ្ទេស សុភ័ក្ត្រ ភាណា បានធ្វើការសរុបសេចក្តីដោយចោទជាសំណួរលើចំណុចសំខាន់ៗនៃមេរៀននៅក្នុងថ្ងៃនេះ។ សំណួរទាំងនោះ រួមមានផលប៉ះពាល់នៃគោលនយោបាយការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យចំពោះប្រទេសជិតខាង និងមតិយល់ឃើញរបស់សិស្សថាតើ គួរមានយុទ្ធសាស្ត្រការបរទេសណាមួយដែលកម្ពុជាប្រជាធិបតេយ្យគួរអនុវត្ត ជាជាងគោលនយោបាយការបរទេសជាក់ស្តែងដែលរបបនោះបានអនុវត្តជាដើម។

វេទិកាថ្នាក់រៀនក្នុងថ្ងៃនេះ នឹងផ្តល់ជាការត្រិះរិះពិចារណាចាំបាច់ទៅលើគោលនយោបាយការបរទេស



ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការដឹកនាំនៃរបបខ្មែរក្រហម។ ការរួមផ្សំគ្នារវាងពិព័រណ៍រូបថត និងការពិភាក្សាគ្នាយ៉ាងសកម្ម បានផ្តល់នូវការយល់ដឹងស៊ីជម្រៅអំពីរយៈកាលប្រវត្តិសាស្ត្រដ៏ចាំបាច់របស់កម្ពុជា។

# សិស្សមកពីវិទ្យាល័យ ក្រែក ចូលរួមវេទិកា

## ថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម

ឡុង ដានី



នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» ដល់សិស្សានុសិស្សថ្នាក់ទី១២ ចំនួន២៦នាក់ ក្នុងនោះមានស្រី១៣នាក់ មកពីវិទ្យាល័យក្រែក ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៨ព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» ផ្តោតសំខាន់ទៅលើប្រធានបទការឡើងកាន់អំណាចរបស់ខ្មែរក្រហម រួមមាន ការជម្លៀសប្រជាជនចេញពីទីក្រុង, ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ដល់សិស្សានុសិស្សថ្នាក់ទី១២ ចំនួន២៦នាក់ ក្នុងនោះមានស្រី១៣នាក់ មកពីវិទ្យាល័យក្រែក ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

គោលបំណងនៃការរៀបចំវេទិកាថ្នាក់រៀននេះគឺចង់ឲ្យសិស្សានុសិស្សរៀនសូត្របន្ថែមអំពីបរិបទប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), និយមន័យអំពើប្រល័យពូជសាសន៍, ការទប់ស្កាត់ និងកត្តាគ្រោះថ្នាក់នានាដែលនាំឲ្យកើត

មានអំពើប្រល័យពូជសាសន៍នាពេលអនាគត។ សិស្សានុសិស្សអាចផ្លាស់ប្តូរការគិតអំពីការប្រព្រឹត្តអំពើហិង្សា មកជាការកសាងសន្តិភាព ក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។

ជាកិច្ចចាប់ផ្តើមលោក ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មបានដឹកនាំសិស្សានុសិស្សដើរទស្សនាពិព័រណ៍រូបថតស្តីអំពីសង្គ្រាមកាលពីចុងទសវត្សរ៍ឆ្នាំ១៩៦០ រូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ រូបថតភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤រូបចេញទៅប្រទេសវៀតណាមនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីកសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។

បន្ទាប់មក លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានបង្រៀនសិស្សានុសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយផ្តោតលើប្រធានបទការឡើងកាន់អំណាចរបស់ខ្មែរក្រហម រួមមាន៖ ការជម្លៀសប្រជាជនចេញពីទីក្រុង, ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ ដំបូងលោក ឡុង ដានី បានជ្រើសយកវិធីសាស្ត្រ K-W-L (ដឹង, ចង់ដឹង, បានដឹងអ្វីខ្លះ) មកបង្រៀនសិស្សានុសិស្ស និងចាប់ផ្តើមដោយសួរសំណួរទៅសិស្សានុសិស្សទាំងអស់ថា តើប្អូនៗបានដឹងអ្វីខ្លះអំពីរបបខ្មែរក្រហម? បន្ទាប់មក លោក ឡុង ដានី សួរសំណួរបន្ថែមទៀតទៅកាន់សិស្សានុសិស្សទាំងអស់ តើប្អូនៗចង់ដឹងអ្វីខ្លះអំពីរបបខ្មែរក្រហម? នៅចុងក្រោយ ទើបលោក ឡុង ដានី ធ្វើបទបង្ហាញលើប្រធានបទការឡើងកាន់អំណាចរបស់ខ្មែរក្រហម៖

១) នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ បានរយៈពេល២ទៅ៣ម៉ោង មេដឹកនាំខ្មែរក្រហមបានបញ្ជាឲ្យកងទ័ពខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានា ទៅធ្វើការងារពលកម្មដ៏លំបាកវេទនានៅតាមវាលស្រែនៃតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ កងទ័ពខ្មែរក្រហមបានយកលេសក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ ហើយប្រជាជនត្រូវតែជម្លៀសចេញពីទីក្រុងភ្នំពេញតែរយៈពេល៣ថ្ងៃនឹងបានវិលត្រឡប់មកផ្ទះវិញ ដូច្នេះប្រជាជនទាំងអស់មិនចាំបាច់យកទ្រព្យសម្បត្តិច្រើនទៅតាមខ្លួន និងចាក់សោផ្ទះទេ។ ប៉ុន្តែការពិតខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនត្រឡប់មកផ្ទះសម្បែងវិញពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនជម្លៀសច្រើនលើសលប់បានស្លាប់ដោយសារការសម្លាប់ ការធ្វើការងារហួសកម្លាំង ការអត់អាហារ និងជំងឺ។

២) ចាប់តាំងពីចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្លាស់ទីប្រជាជន ជាពិសេសប្រជាជនថ្មីដោយបង្ខំឲ្យទៅនៅតាមទីជនបទ ហើយផ្លាស់ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ម្តងហើយម្តងទៀត នៅក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា (រួមបញ្ចូលទាំងការផ្លាស់ទីតាមរយៈរថភ្លើងពីភូមិភាគនិរតី និងភូមិភាគបស្ចិម ទៅកាន់ភូមិភាគពាយ័ព្យ)។ ការផ្លាស់ទីប្រជាជននេះពុំមានដូនដំណឹងជាមុនឡើយ ទើបបង្កជាទុក្ខវេទនា និងភាពលំបាកលំបិនដល់ប្រជាជន និងសហគមន៍ជាខ្លាំង។

៣) ចាប់តាំងពីរបបខ្មែរក្រហមធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមលែងទុកចិត្តលើកម្មាភិបាល យុទ្ធជន និងប្រជាជននៅភូមិភាគបូព៌ា។ ប្រជាជនភូមិភាគបូព៌ាត្រូវបានខ្មែរក្រហមចោទប្រកាន់ថាជាមនុស្សដែលមានក្បាលយួនខ្លួនខ្មែរ។ ប្រជាជនភូមិភាគបូព៌ាទាំងអស់គឺជាគោលដៅនៃការជម្លៀសដោយបង្ខំចេញពីភូមិភាគបូព៌ាទៅភូមិភាគ



នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» ដល់សិស្សានុសិស្សថ្នាក់ទី១២ ចំនួន២៦នាក់ ក្នុងនោះមានស្រី១៣នាក់ មកពីវិទ្យាល័យក្រែក ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពាយ័ព្យ ភូមិភាគកណ្តាល និងភូមិភាគឧត្តរ។ ការជម្លៀសដោយបង្ខំនេះ បានបណ្តាលឲ្យប្រជាជនភូមិភាគបូព៌ាជាច្រើនបានស្លាប់ដោយសារខ្មែរក្រហមសម្លាប់ ធ្វើការងារហួសកម្លាំង អត់អាហារ និងឈឺគ្មានថ្នាំព្យាបាល។

ជាកិច្ចបន្ត លោក ឡុង ដានី បានបង្ហាញសិស្សានុសិស្សអំពីទីតាំងទួលពោធិ៍ជ្រៃ គឺជាទីវាលធំមួយ ស្ថិតនៅក្បែរបឹងទន្លេសាប និងជាប់តំបន់ព្រៃរនាម ក្នុងភូមិសាស្ត្រស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ ទីតាំងទួលពោធិ៍ជ្រៃនេះត្រូវបានគេស្គាល់ថា គឺជាកន្លែងដែលខ្មែរក្រហមសម្លាប់ទាហាន លន់ នល់ និងជនស៊ីវិលរាប់ពាន់នាក់ក្នុងអំឡុងនៃការជម្លៀសដោយបង្ខំជាទ្រង់ទ្រាយធំលើកដំបូងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

ចុងបញ្ចប់នៃបទបង្ហាញ លោក ឡុង ដានី បានសង្ខេបអំពីដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំណុំរឿង ០០១ និងសំណុំរឿង ០០២ (សំណុំរឿង០០២ វគ្គទី១ និងសំណុំ០០២ វគ្គទី២)។ និយមន័យអំពើប្រល័យពូជសាសន៍ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើនេះ។

**បន្ទាប់ពីចប់វេទិកាថ្នាក់រៀន សិស្សានុសិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖**



ខ្ញុំបាទឈ្មោះ **ងួន ជាតិសុឆាថ** គឺជាសិស្សរៀនថ្នាក់ទី១២ មកពីវិទ្យាល័យក្រែក។ ខ្ញុំពិតជាមានការចាប់អារម្មណ៍ជាខ្លាំងទៅលើការតុបតែងរូបភាព។ ខ្ញុំបានចូលទៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្មឃើញការតាំងពិព័រណ៍ រូបភាព ធ្វើឲ្យខ្ញុំមានអារម្មណ៍ថា សម័យកាលនោះពិតជាព្រៃផ្សៃខ្លាំងណាស់ ព្រោះខ្ញុំឃើញរូបភាពក្មេងកំព្រា ជនពិការ

ដែលបាត់បង់គ្រួសារ ដោយសារការសម្លាប់។ ខ្ញុំឃើញការតុបតែងថ្នាក់រៀនស្រស់ស្អាត មើលទៅធ្វើឲ្យដឹងអំពីសម័យកាលដែលប្រជាជនរស់នៅយ៉ាងលំបាកវេទនា។ មុនពេលខ្ញុំមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខ្ញុំមានចំណេះដឹងមួយចំនួនទាក់ទងជាមួយរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា ការជម្លៀស ការឡើងកាន់អំណាចរបស់មេដឹកនាំខ្មែរក្រហម ការសម្លាប់ប្រជាជនយ៉ាងព្រៃផ្សៃ ការឲ្យប្រជាជនស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ការប្រើប្រជាជនឲ្យធ្វើការងារហួសកម្លាំង និងការឲ្យប្រជាជនរស់នៅរួម។ នៅពេលខ្ញុំបានមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់ប្រវត្តិសាស្ត្រសម្តេចតេជោ អ៊ិច១៦ ខ្ញុំពិតជារំភើបរីករាយជាខ្លាំង ព្រោះខ្ញុំបានដឹងអំពីប្រវត្តិសាស្ត្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកាន់តែច្បាស់ថែមទៀត។ ជាចុងក្រោយ ខ្ញុំសំណូមពរឲ្យមានកម្មវិធីទស្សនកិច្ចសិក្សាផ្ទាល់បែបនេះបន្តទៀត ពីព្រោះជាកិច្ចការមួយដ៏ល្អប្រសើរសម្រាប់សិស្សានុសិស្សគ្រប់រូប ដើម្បីឲ្យបានយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនឲ្យកាន់តែច្បាស់លាស់ និងមានចំណេះដឹងកាន់តែទូលំទូលាយ។

ខ្ញុំឈ្មោះ **ម៉ែ រតនា** ភេទស្រី គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យក្រែក។ ថ្ងៃនេះ ខ្ញុំមានអារម្មណ៍សប្បាយរីករាយក្រៃលែងដែលមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំកម្មវិធីទស្សនកិច្ចនេះឡើង។ មុនមកសិក្សានៅទីនេះ ខ្ញុំបានសិក្សារៀនសូត្រខ្លះៗអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ពេលខ្ញុំស្តាប់គ្រូខ្ទេសបង្រៀនចប់ធ្វើឲ្យខ្ញុំបានយល់ដឹងបន្ថែមពីប្រវត្តិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងរបបនេះបានធ្វើបាបប្រជាជនយ៉ាងសាហាវព្រៃផ្សៃបំផុត និងធ្វើឲ្យប្រជាជនកម្ពុជារងទុក្ខវេទនា បែកបាក់គ្រួសារ រស់នៅគ្មានសេរីភាព គ្មានអាហារហូបចុកគ្រប់គ្រាន់ និងធ្វើការច្រើនម៉ោងគ្មានពេលសម្រាក។ ជាចុងក្រោយ ខ្ញុំសូមសំណូមពរដល់មជ្ឈមណ្ឌលឯកសារកោះថ្មឲ្យរៀបចំកម្មវិធីនេះជាបន្តបន្ទាប់ទៀត ដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានសិក្សារៀនសូត្របន្ថែមអំពីប្រវត្តិសាស្ត្ររបស់ប្រទេសជាតិខ្លួន។

ខ្ញុំឈ្មោះ **អ៊ឹម ចរិយា** ភេទស្រី គឺជាសិស្សរៀនថ្នាក់ទី១២ មកពីសាលាវិទ្យាល័យក្រែក។ នៅក្នុងឱកាសទស្សនកិច្ចសិក្សាព្រឹកនេះ ខ្ញុំពិតជាមានការរីករាយជាខ្លាំង និងមានចំណាប់អារម្មណ៍ទាក់ទងរបបកម្ពុជាប្រជាធិបតេយ្យ។ មុននឹងខ្ញុំមកទស្សនកិច្ចសិក្សានេះ ខ្ញុំបានយល់ដឹងខ្លះៗអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា ការប្រើឲ្យប្រជាជនធ្វើការងារហួសកម្លាំង និងការជម្លៀសប្រជាជនចេញពីស្រុកកំណើត និងផ្ទះសម្បែងជាដើម។ ពេលដែលខ្ញុំមកសិក្សានៅទីនេះ ខ្ញុំមានការចេះដឹងបន្ថែមទៀត។ ខ្ញុំបានដឹងកាន់តែច្បាស់អំពីឧក្រិដ្ឋកម្មក្នុងសំណុំរឿងក្តី០០១ និងសំណុំរឿងក្តី០០២ថែមទៀត។ ជាចុងក្រោយ ខ្ញុំសូមសំណូមពរឲ្យលោកគ្រូមានវគ្គបណ្តុះបណ្តាលថ្មីៗអំពីប្រវត្តិសាស្ត្រខ្មែរក្រហមជាបន្តបន្ទាប់ទៀត។





នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» ដល់សិស្សានុសិស្សថ្នាក់ទី១២ ចំនួន២៦នាក់ ក្នុងនោះមានស្រី១៣នាក់ មកពីវិទ្យាល័យក្រែក ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ង៉ែត តឿ ៖ កងចល័ត

ឌីម សុខគា



ង៉ែត តឿ អាយុ៦១ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្រាំងគរ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ង៉ែត តឿ អាយុ៦១ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្រាំងគរ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ង៉ែត ទួន និងម្ដាយឈ្មោះ ជ័យ យិន។ ខ្ញុំមានបងប្អូនចំនួន៩ នាក់ គឺស្រី៤នាក់និងប្រុស៥នាក់។ ឪពុករបស់ខ្ញុំមានមុខរបរគឺជាអ្នកធាក់ស៊ីក្លូ។

កាលពីក្មេងខ្ញុំមិនបានចូលរៀនទេ។ ក្នុងរបបលន់ នល់ បងប្អូនខ្ញុំបានស្លាប់ម្នាក់ឈ្មោះ ង៉ែត ម៉ៅ ដោយសារការទម្លាក់គ្រាប់បែក។ ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងក្រុមគ្រួសារពីទីក្រុងភ្នំពេញឲ្យមករស់នៅទីជនបទ ដោយបានលើកហេតុផលថា បើយើងមានស្រុកកំណើតនៅស្រុកណាទៅស្រុកនោះវិញទៅ។ ខ្មែរក្រហមបានកំណត់ឲ្យចាកចេញពីទីក្រុងភ្នំពេញរយៈពេល៣ថ្ងៃ។ ប៉ុន្តែខុសពីការគិត៣ថ្ងៃ ក្លាយទៅ៣ឆ្នាំទៅវិញ។ អំឡុងពេលជម្លៀសចេញពីភ្នំពេញខ្ញុំបានធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល២៨ថ្ងៃ។ ខ្ញុំនិងក្រុមគ្រួសារអស់កម្លាំង ហេវហត់ ហើយបានឈប់សម្រាកនៅភូមិវះពោះ (ឈ្មោះភូមិពីមុនប៉ុន្តែបច្ចុប្បន្នមិនមានទៀតទេ) ស្ថិតនៅខាងកើតស័ង្កសី រយៈពេល២យប់ ទើបមកដល់ភូមិត្រពាំងឈូក។

ចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យធ្វើការនៅក្នុងកងកុមារ។ ពេលនោះកងកុមារមានចំនួន២០នាក់។ ខ្ញុំបានទៅរែកអាចម៍គោនៅភូមិត្រពាំងឈូក។ បន្ទាប់មកខ្មែរក្រហមបានប្រើខ្ញុំឲ្យទៅកាប់ដើមទន្ទ្រានខែត្រដើម្បីធ្វើជីដាក់ស្រែ។ កន្លែងធ្វើការងារគឺនៅក្បែរកន្លែងខ្ញុំស្នាក់នៅ។ ឪពុកខ្ញុំបានសង់ខ្ទមតូចមួយនៅភូមិត្រពាំងឈូកសម្រាប់យើងស្នាក់នៅជុំគ្នា។ ក្រោយមកខ្មែរក្រហមបានប្រើខ្ញុំឲ្យទៅរែកដី ដោយកំណត់ក្នុងមួយថ្ងៃត្រូវរែកដីឲ្យបានមួយម៉ែត្រគារ៉េ។ ខ្ញុំធ្វើការងារមិនមានពេលឈប់សម្រាកឡើយ គឺបានសម្រាកតែពេលហូបបាយមួយភ្លែតៗតែប៉ុណ្ណោះ។ ខ្ញុំហូបចុកមិនបានគ្រប់គ្រាន់ឡើយ គឺមានតែសម្លព្រលិតជាមួយនឹងទឹកត្រី។ ពេលនោះ ប្រជាជនត្រូវហូបនៅរោងសហករណ៍ នៅផ្សារត្រាំកក់។

នៅសម័យនោះខ្ញុំបានចូលរៀនអក្ខរកម្មបន្តិចបន្តួចនៅចន្លោះម៉ោងសម្រាកពីធ្វើការងារ។ ខ្ញុំនៅចាំឈ្មោះគ្រូបង្រៀនគឺមានគ្រូឈ្មោះ អែម និងគ្រូឈ្មោះ

រ៉នៗ គ្រូបង្រៀនទាំងពីរនាក់កាចណាស់ៗ នៅក្នុងរបបខ្មែរក្រហមមិនមានសាសនាទេព្រោះខ្មែរក្រហមបំផ្លាញចោលអស់ហើយៗ រីឯសម្លៀកបំពាក់ក៏មិនមានគ្រាប់គ្រាន់ដែរ គឺក្នុងមួយឆ្នាំខ្មែរក្រហមបើកឲ្យប្រជាជនតែ២សម្រាប់ប៉ុណ្ណោះៗ យើងស្លៀកពាក់ទាល់តែមើលទៅរហែកអស់ និងប្រើការលែងបាន ទើបខ្មែរក្រហមចែកឲ្យៗ ខ្ញុំសម្គាល់បានថាខ្មែរក្រហមណាស្លៀកពាក់ពណ៌ខៀវ ឬពណ៌ខ្មៅ ហើយមានកន្សែងបង់កក្រមា គឺជាប្រធានកងៗ

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមិនមានជំងឺធ្ងន់ធ្ងរទេ គឺមានតែវិលមុខតិចតួចប៉ុណ្ណោះៗ ប៉ុន្តែទោះបី ខ្ញុំឈឺក៏មិនឈប់សម្រាកដែរ គឺត្រូវបន្តធ្វើការងារទាំងឈឺៗ មួយវិញទៀត ចំពោះដំណាំ និងសត្វដែលយើងដាំ និងចិញ្ចឹម ក៏មិនបានហូបដែរ គឺខ្មែរក្រហមប្រមូលយកទាំងអស់ៗ នៅសម័យនោះការរៀបការ គឺខ្មែរក្រហមរៀបចំស្ត្រីមួយជួរ និងបុរសមួយជួរ ហើយឲ្យអង្គុយទល់មុខគ្នាៗ បន្ទាប់មកស្ត្រីនិងបុរសដែលខ្មែរក្រហមជ្រើសរើសឲ្យត្រូវឡើងប្តេជ្ញាចិត្តយកគ្នាជាប្តីប្រពន្ធអស់មួយជីវិត ហើយក្នុងការឡើងប្តេជ្ញាមួយលើកៗ គឺមាន៦គូ មានទាំងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ឬហៅម្យ៉ាងទៀតប្រជាជន១៧ៗ ការប្តេជ្ញាចិត្តនេះធ្វើឡើងនៅពេលព្រឹកនៅសាលារៀនត្រាំកក់ៗ ដោយឡែក ខ្ញុំបានចូលរួមការប្រជុំដោយនិយាយអំពីការបង្កបង្កើនផល និងធ្វើស្រែឲ្យបាន៣តោនក្នុងមួយហិកតាៗ

ខ្ញុំមានប្អូនស្រីម្នាក់បានស្លាប់ក្នុងរបបខ្មែរក្រហមឈ្មោះ ង៉ែត ពៅ ដោយសារជំងឺ និងមិនមានអាហារហូបគ្រប់គ្រាន់ៗ ពេលនោះប្អូនស្រីខ្ញុំទើបតែមានអាយុ១២ឆ្នាំប៉ុណ្ណោះៗ រីឯបងប្រុសឈ្មោះ ង៉ែត ត្រី ស្លាប់នៅភ្នំខៀវ ពេលចូលធ្វើជាទាហាន នាសម័យក្រោយមកៗ ក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩ ខ្ញុំបានទៅរស់នៅទីក្រុងភ្នំពេញ ដោយដើររយៈពេល៣យប់៤ថ្ងៃៗ ខ្ញុំបានប្រកបរបររកស៊ីដឹកទឹកលក់ និងបេះត្រកួនលក់ៗ ពេលនោះ ទីក្រុងភ្នំពេញមានសភាពស្ងប់ស្ងាត់ និងព្រៃដុះស៊ុបទ្រុបៗ នៅឆ្នាំ១៩៨៩ ខ្ញុំបានរៀបការជាមួយឈ្មោះ ភិន ពេជ្រ និងមានកូនចំនួន២នាក់ៗ នៅឆ្នាំ១៩៩៥ ខ្ញុំនិងគ្រួសារបានត្រឡប់មករស់នៅភូមិកំណើតវិញរហូតមកដល់សព្វថ្ងៃៗ



វាលស្រែភូមិត្រាំងគរ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៊ុន មុំ ៖ អតីតយុទ្ធនារីខ្មែរក្រហម

**ស៊ុយ សុខមាន**



ប៊ុន មុំ អាយុ៦៧ឆ្នាំ គឺជាកសិករ សព្វថ្ងៃរស់នៅក្នុងភូមិស្រែពពាយ ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៊ុន មុំ ភេទស្រី អាយុ៦៧ឆ្នាំ សព្វថ្ងៃគឺជាកសិករ។ ខ្ញុំមានស្រុកកំណើតនៅ ភូមិស្រែពពាយ ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ប៊ុន ប៊ិន (ស្លាប់) និងម្តាយឈ្មោះ សុខ សៅ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៧ នាក់ គឺប្រុសចំនួន២ នាក់ និង ស្រីចំនួន៥ នាក់។ បងប្អូនរបស់ខ្ញុំបានបាត់បង់ជីវិតចំនួន២ នាក់ ក្នុងរបបខ្មែរក្រហម។ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ ណយ ស៊ីណន ព្រមទាំងមានកូនចំនួន៧ នាក់។ ប្តីរបស់ខ្ញុំស្លាប់បាត់បង់ជីវិតហើយដោយសារជំងឺ។ ចំណែកកូនៗរបស់ខ្ញុំក៏មានគ្រួសារ និងចេញទៅរស់នៅតាមផ្ទះសម្បែងរៀងៗខ្លួន។ រាល់ថ្ងៃ ខ្ញុំរស់នៅតែម្នាក់ឯង។

កាលពីកុមារ ខ្ញុំរស់នៅជាមួយឪពុកម្តាយ ខ្ញុំធម្មតាដូចក្មេងៗដទៃទៀតដែរ ប៉ុន្តែខ្ញុំមិនបានចូលរៀនសូត្រទេ ពីព្រោះឪពុកម្តាយ ខ្ញុំមានជីវភាពក្រីក្រពេក។ ពេលនោះ ឪពុកម្តាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ។ ខ្ញុំធំដឹងក្តីអំឡុងពេលស្រុកទេសកើតមានសង្គ្រាម ហើយសាលារៀនត្រូវបានបិទទ្វារដោយសារការទម្លាក់គ្រាប់បែក។ ដូច្នេះសិស្សមិនមានសាលារៀនសូត្រឡើយ។

ខ្ញុំនៅចាំបានថា នៅពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅក្នុងស្រុកកំណើតធម្មតា។ លុះក្រោយមកនៅចន្លោះពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានទាហាន លន់ នល់ ផ្លាស់ប្តូរឲ្យទៅរស់នៅក្នុងភូមិផ្សេងៗ។

នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំត្រូវបានទាហាន លន់ នល់ ជម្លៀសឲ្យទៅរស់នៅ ទីរួមខេត្តពោធិ៍សាត់។ ខ្ញុំត្រូវបែកពីឪពុកម្តាយបងប្អូន និងរស់នៅពិបាកវេទនាខ្លាំងណាស់។ នៅឆ្នាំ១៩៧៤ ខ្ញុំក៏ចូលធ្វើជាកងទ័ពរំដោះខ្មែរក្រហមវាយប្រឆាំងតទល់នឹងទាហាន លន់ នល់ វិញ។ ពេលធ្វើសង្គ្រាម ខ្ញុំទទួលបានបាយម្នាក់មួយកញ្ចប់ ពីកងដឹកជញ្ជូនយកមកឲ្យខ្ញុំដែលឈរជើងតាមខ្សែត្រៀមប្រយុទ្ធ។

នៅក្នុងឆ្នាំ១៩៧៥ នៅពេលដែលកងទ័ពខ្មែរក្រហមឡើងកាន់អំណាចពេញលេញ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើការនៅរោងចក្រស្ករ។ ការរស់នៅពេលនោះជាក្រុមសហជីព ប៉ុន្តែធ្វើការងារដូច

សហករណ៍។ ខ្ញុំនៅតែត្រូវរស់នៅបែកបាក់ពីឪពុកម្ដាយ និងបងប្អូនទាំងអស់ដដែល ថែមទាំងមិនបានទទួលដំណឹងពីពួកគាត់ទៀតផង។ ក្នុងមួយថ្ងៃ ប្រធានកងប្រើខ្ញុំឲ្យធ្វើការចាប់ពីម៉ោង៦ទៅម៉ោង១១ព្រឹក សម្រាកហូបបបរ ហើយចូលធ្វើការវិញចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច ទើបសម្រាកហូបបបរម្ដងទៀត។

នៅចន្លោះពីឆ្នាំ១៩៧៦ ដល់១៩៧៨ ពេលថ្ងៃខ្ញុំនៅធ្វើការក្នុងរោងចក្រស្កររដដែល ប៉ុន្តែនៅពេលយប់ខ្មែរក្រហមប្រើខ្ញុំឲ្យទៅរែកដី និងលើកប្រព័ន្ធប្រឡាយ។ ខ្មែរក្រហមបានបន្ថែមការងារ ប៉ុន្តែខ្ញុំនៅតែហូបបបរលាយជាមួយសម្លម្ជូរព្រលិតរាល់ថ្ងៃដដែល ធ្វើឲ្យខ្ញុំគ្មានកម្លាំងកំហែងធ្វើការងារឡើយ។

នៅដើមឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀត-ណាមចូលមករំដោះ ខ្ញុំបានលួចរត់គេចចេញពីរោងចក្រស្ករ (ទីតាំងសព្វថ្ងៃនៅស្រុកតាលោសែនជ័យ) ទៅក្រុងខេត្តពោធិ៍សាត់ក៏បានជួបជាមួយម្ដាយខ្ញុំវិញ។ ទោះបីរបបខ្មែរក្រហមបានដួលរលំហើយក៏ពិតមែន ប៉ុន្តែការហូបចុកគឺនៅតែពិបាកខ្លាំង។ ដូច្នេះក្រុមគ្រួសារខ្ញុំនាំគ្នាដើរបូតស្រូវតាមវាលស្រែយកមកបុកហូប។ រហូតដល់ឆ្នាំ១៩៨១ ទើបក្រុមគ្រួសាររបស់ខ្ញុំបានហូបគ្រប់គ្រាន់វិញ។



ផ្ទះរបស់ ប៊ុន មុំ នៅភូមិព្រែកពពាយ ឃុំសន្រ្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ង៉ែត វែន ៖ ប្រជាជនមូលដ្ឋាន

**ឌីម សុខគា**



ង៉ែត វែន អាយុ៧៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិថ្មកែវ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ង៉ែត វែន អាយុ៧៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិថ្មកែវ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ កាលពីក្មេង ខ្ញុំចូលរៀនអក្ខរកម្មនៅវត្តថ្មកែវ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៩ នាក់ គឺស្រី៤ នាក់ និងប្រុស៥ នាក់។ បច្ចុប្បន្ន បងប្អូនរបស់ខ្ញុំនៅរស់រានមានជីវិតចំនួន៣ នាក់។ ខ្ញុំមានកូនចំនួន៩ នាក់ គឺប្រុស៤ នាក់និងស្រី៥ នាក់។

នៅក្នុងឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងមានការទម្លាក់គ្រាប់បែក ប៉ុន្តែមិនបានទម្លាក់គ្រាប់បែកក្នុងភូមិថ្មកែវទេ។ នៅក្នុងរបប លន់ នល់ ប្រជាជនហូបបាយឯកជននៅតាមផ្ទះរៀងៗខ្លួន។ មកដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមចាត់តាំងប្រជាជនឲ្យហូបជាសហករណ៍។ នៅសម័យនោះ ខ្ញុំមិនបានរស់នៅជួបជុំឪពុកម្តាយទេ ព្រោះឪពុកម្តាយខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការតាមកងផ្សេងៗពីគ្នា។ ប្តីរបស់ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅធ្វើការនៅសេដ្ឋកិច្ច គឺដឹកជញ្ជូនស្បៀងអាហារទៅចែកឲ្យសហករណ៍។ ខ្ញុំរស់នៅក្នុងភូមិ និងធ្វើការដកស្ទូងស្រូវនៅក្បែរៗភូមិខ្ញុំ ព្រោះខ្ញុំមានកូនតូចៗ។ ខ្ញុំគឺជាប្រជាជនមូលដ្ឋាន ប៉ុន្តែការហូបចុកជួបការលំបាកខ្លះៗដែរ ព្រោះមិនបានហូបឯកជនទៀ របបអាហារមានតែពីរពេលប៉ុណ្ណោះ គឺពេលថ្ងៃត្រង់ និងពេលល្ងាច។

បន្ទាប់ពីខ្មែរក្រហមប្រមូលប្រជាជនចូលក្នុងសហករណ៍អស់ ខ្ញុំក៏ត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការនៅត្រាំកក់។ ខ្ញុំទៅទាំងគ្រួសារ ប៉ុន្តែខ្មែរក្រហមបែងចែកសមាជិកគ្រួសារខ្ញុំទៅធ្វើការផ្សេងៗតាមកងផ្សេងៗគ្នា។ ពេលនោះខ្ញុំមានកូនចំនួន៥ នាក់ ប៉ុន្តែមានតែ២ នាក់ប៉ុណ្ណោះ ដែលចេញទៅធ្វើការតាមកង ចំណែកកូន៣ នាក់ផ្សេងទៀត ដែលនៅតូចគឺយាយៗជួយមើលថែទាំនៅក្បែរកន្លែងខ្ញុំធ្វើការផ្សេងៗ។ កំឡុងពេលទៅត្រាំកក់ ខ្ញុំធ្វើជាអ្នកដាំបាយ។ ខ្ញុំត្រូវក្រោកតាំងពីព្រលឹម រហូតដល់ពេលល្ងាចទើបបានឈប់សម្រាក ហើយត្រឡប់មកកន្លែងស្នាក់នៅវិញ។ ថ្ងៃមួយ ខ្ញុំភ្លោយមាត់និយាយថា «គ្រាន់តែបាយក្តាំងកំណាញ់ដែរ គ្នាហូបដើម្បីមានកម្លាំងធ្វើការសោះ»។ បន្ទាប់ពីខ្ញុំនិយាយរួច ខ្មែរក្រហមបានហៅសមាជិកកងប្រជុំមួយយប់ទល់ភ្លឺ។ ក្រោយមកទើបខ្ញុំបានដឹងថា ខ្មែរក្រហមប្រជុំនិយាយអំពីកំហុសរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ថាភ័យខ្លាច មិនដឹងថាខ្ញុំស្លាប់នៅថ្ងៃណាឡើយ។ ប៉ុន្តែខ្មែរក្រហមមិនបានធ្វើបាបខ្ញុំទេ

ដោយសារខ្ញុំមានបងប្អូនចូលធ្វើជាទ័ព ក្នុងនោះប្អូនប្រុសរបស់ខ្ញុំម្នាក់បានស្លាប់ដោយសារត្រូវគ្រាប់អំឡុងពេលធ្វើសង្គ្រាម។ ចំណែកបងប្អូន៣នាក់ទៀតរួមមាន ឈ្មោះ ង៉ែត ឌន, ង៉ែត អ៊ូយ ហើយប្អូនស្រី ឈ្មោះ ង៉ែត ស៊ុម ហៅក្រៅ វឿន ធ្វើជាគ្រូពេទ្យ ៧មករា បាត់ខ្លួនពេលបែកក្រុងភ្នំពេញ។

ខ្ញុំបានជួបបងប្អូនម្តង កំឡុងពេលធ្វើបុណ្យជប់លៀងកងទ័ពនៅក្បាលពោធិ៍ និងមានការហូបអាហារឆ្ងាញ់ជុំជាមួយគ្នាមួយពេល។ ខ្ញុំបានឃើញប្អូនខ្ញុំមានសភាពស្គមស្គាំង។ ពេលនោះ ខ្ញុំមិនហ៊ាននិយាយជាមួយបងប្អូនខ្ញុំទេ ព្រោះនៅចំណោមមនុស្សច្រើនម៉្លោះទៀតខ្លាចខ្មែរក្រហមលួចស្តាប់។ រីឯទ្រព្យសម្បត្តិ និងមាសប្រាក់លែងសំខាន់សម្រាប់ខ្ញុំទៀតហើយ គឺធ្វើយ៉ាងណាឲ្យបានហូបគ្រប់គ្រាន់ប៉ុណ្ណោះ។

នៅក្នុងរបបខ្មែរក្រហមវត្តអារាម ព្រះពុទ្ធរូប និងសាសនា ត្រូវខ្មែរក្រហមបំផ្លាញចោល និងលែងគោរព។ ព្រះសង្ឃត្រូវបានខ្មែរក្រហមផ្សឹករួចបញ្ជូនទៅលើកទំនប់ ដូចជាប្រជាជនទូទៅដែរ។ ចំណែកសម្លៀកបំពាក់ ខ្ញុំមិនមានស្លៀកពាក់សមរម្យទេ គឺទាល់តែដាច់រហែកស្លៀកពាក់លែងកើត ទើបខ្មែរក្រហមចែកឲ្យមួយសម្រាប់។ សម្លៀកបំពាក់មានតែពណ៌ខ្មៅតែប៉ុណ្ណោះ។

នៅពេលរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩ ខ្ញុំនិងប្រជាជនផ្សេងទៀតបានរត់គេចខ្លួនទៅដល់ភូមិក្រសាលនៅក្នុងខេត្តកំពង់ស្ពឺ។ ខ្ញុំនិងប្រជាជនជាច្រើននាក់ទៀតបានរែកកូនរែកចៅ ទៅតាម។ ខ្ញុំធ្វើដំណើរដោយគ្មានទិសដៅ ដោយយប់ត្រង់កន្លែងណាខ្ញុំសម្រាកត្រង់កន្លែងនោះ។ ខ្ញុំរត់គេចខ្លួនអស់រយៈពេល៥ថ្ងៃ ទើបត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំបានរុះទ្រុងមាន់មកធ្វើជាផ្ទះស្នាក់នៅ ព្រោះផ្ទះរបស់ខ្ញុំត្រូវបានខ្មែរក្រហមរុះរើអស់ហើយ។ ខ្ញុំបានរស់នៅជួបជុំគ្រួសារវិញ។ បន្ទាប់មក ខ្ញុំបានធ្វើស្រែរួម និងប្រវាស់ដៃគ្នាហើយចែកផលទៅតាមសមាជិកគ្រួសារ ដោយក្នុងសមាជិកម្នាក់ទទួលបាន១២ថាំងក្នុងមួយឆ្នាំ។ ខ្ញុំធ្វើស្រែរួមរយៈពេល៣ឆ្នាំ។

បើប្រៀបធៀបកាលពីអំឡុងរបបខ្មែរក្រហម និងពេលបច្ចុប្បន្នគឺមានភាពខុសប្លែកគ្នា ទាំងការហូបចុក និងការដើរហើរ។ នៅក្នុងរបបខ្មែរក្រហមយើងមិនអាចពិភាក្សាគ្នា ឬសួរនាំគ្នាបានទេ ទោះបីត្រូវជាបងប្អូន និងរស់នៅជាប់របងគ្នាក៏ដោយ។ ខ្ញុំសូមផ្តាំផ្ញើទៅកាន់កូនចៅជំនាន់ក្រោយឲ្យចេះរួបរួមសាមគ្គីគ្នា កុំឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត។



វាលស្រែនៅភូមិថ្មកែវ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ញ៉ា ភឿន ៖ កងចល័តជីកប្រឡាយនៅបឹងព្រះ

ឡាំ ស្រីនីត



ញ៉ា ភឿន អាយុ៦៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ញ៉ា ភឿន ភេទស្រី អាយុ៦៦ឆ្នាំ មានមុខរបរធ្វើស្រែចម្ការ។ ខ្ញុំមានស្រុកកំណើតនៅភូមិម៉ឺរ ឃុំព្រះម្លូ ស្រុកបាកាន ខេត្តពោធិ៍សាត់។ បច្ចុប្បន្នខ្ញុំរស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ញ៉ា ប៉ាន់ និងម្តាយឈ្មោះ កា ហ៊ីង។ ឪពុកម្តាយរបស់ខ្ញុំបានស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនចំនួន១១នាក់ ក្នុងនេះស្លាប់អស់ចំនួន៨នាក់ក្នុងរបបខ្មែរក្រហម។ សព្វថ្ងៃ បងប្អូនខ្ញុំនៅរស់តែស្រីៗ៣នាក់តែប៉ុណ្ណោះ។ ប្តីរបស់ខ្ញុំមានឈ្មោះ ប្រាក់ ហោ មានអាយុ៦៧ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការ។ ក្រោយរៀបការ ខ្ញុំមានកូនចំនួន៧នាក់ ក្នុងនោះស្រី៣នាក់ និងប្រុស៤នាក់។

កាលពីសង្គមចាស់ ខ្ញុំរស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំដែលមានជីវភាពមធ្យម។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ ក្រុមគ្រួសារខ្ញុំនៅស្រុកភូមិធ្វើស្រែចម្ការបានធម្មតា។ ចន្លោះពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ ក្នុងភូមិចាប់ផ្តើមចលាចល ព្រោះមានសង្គ្រាមស៊ីវិលកើតមានឡើង ដូច្នេះគ្រួសារខ្ញុំត្រូវគេចទៅរស់នៅក្នុងព្រៃ ព្រោះខ្លាចរអាការទម្លាក់គ្រាប់បែកពីលើយន្តហោះ និងគ្រាប់ផ្លោងពីរថក្រោះ។ នៅពេលស្ងប់ស្ងាត់ពីការទម្លាក់គ្រាប់បែកទើបប្រជាជននាំគ្នាទៅច្រូតស្រូវក្នុងភូមិ ហើយមិនយូរប៉ុន្មានក៏មានយន្តហោះមកទម្លាក់គ្រាប់បែកម្តងទៀត ធ្វើឲ្យប្រជាជននាំគ្នាក្រាបលើភ្លឺស្រែដើម្បីការពារខ្លួន។ កាលនោះផ្ទះសម្បែងរបស់ប្រជាជនមិនសូវខូចខាតប៉ុន្មានទេ ព្រោះយន្តហោះទម្លាក់ដាក់តែផ្ទះណាដែលមានបងប្អូនជាមេបញ្ជាការកងទ័ពរំដោះប៉ុណ្ណោះ។ ប្រជាជនក្នុងភូមិរបស់ខ្ញុំទាំងអស់ គឺមានការប្រុងប្រយ័ត្នចំពោះការទម្លាក់គ្រាប់បែកយ៉ាងខ្លាំង។ ចំណែកអាហារហូបចុកវិញ គឺត្រូវត្រៀមវេចខ្ចប់ពីផ្ទះយកទៅហូបនៅក្នុងព្រៃ។

នៅឆ្នាំ១៩៧៥ ក្រោយពេលខ្មែរក្រហមបានទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ ខ្មែរក្រហមចាប់បង្កើតសហករណ៍។ អង្គការចាប់ប្រមូលទ្រព្យសម្បត្តិប្រជាជនទាំងអស់យកទៅដាក់នៅក្នុងសហករណ៍រួម តែមិនទាន់ខ្វះខាតអាហារហូបចុកនោះទេ។ ចំណែកឯការងារវិញក៏ខ្មែរក្រហមមិនទាន់ប្រើប្រជាជនឲ្យធ្វើធ្ងន់ធ្ងរហួសកម្លាំងដែរ។

កាលពីនៅកុមារ ខ្ញុំបានចូលរៀនល្មមចេះអានអក្សរបានខ្លះៗ។ ខ្ញុំចាំបានថា មានកុមារជាច្រើនបានចូលរៀនជាមួយខ្ញុំ ប៉ុន្តែយើងមិនមានសាលារៀនត្រឹមត្រូវទេ គឺរៀននៅក្រោមដើមឈើ។ ពេលមេឃ

ភ្លៀង យើងត្រូវផ្អាកការរៀនសូត្រ។ ក្រោយមក អង្គការចាត់តាំងខ្ញុំឲ្យចូលក្នុងកងចល័តកុមារ។ អង្គការបានបែងចែកការងារទៅតាមកម្រិតវ័យរបស់មនុស្សឲ្យមានការងារធ្វើគ្រប់ៗគ្នា។ ខ្ញុំនៅក្មេង អង្គការប្រើឲ្យធ្វើការ ដូចជា កាត់ដើមទន្ទ្រានខែត្រ និងដើរបោចស្មៅនៅតាមវាលស្រែជាដើម។ រីឯអ្នកមានវ័យជំទង់វិញ គឺត្រូវបានខ្មែរក្រហមចាត់ឲ្យចូលធ្វើការនៅក្នុងកងចល័ត ជីកប្រឡាយ និងលើកទំនប់។ ម្ដាយឪពុករបស់ខ្ញុំត្រូវអង្គការប្រើឲ្យធ្វើស្រែ និង ចម្ការនៅក្នុងភូមិ។ ដំបូងឪពុកម្ដាយខ្ញុំមានអាហារហូបចុកគ្រប់គ្រាន់ក្នុងមួយថ្ងៃចុងភៅចែករបបអាហារឲ្យគាត់ពីរពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច។

នៅចុងឆ្នាំ១៩៧៦ អង្គការកាត់បន្ថយរបបអាហារ គឺអង្ករ៣កំប៉ុងបបរលាយជាមួយគ្រាប់ពោតសម្រាប់ប្រជាជន១០០នាក់ ប៉ុន្តែអង្គការបន្ថែមការងារឲ្យខ្ញុំធ្វើការលើសមុន។ ខ្ញុំធ្វើការគ្មានពេលសម្រាកឡើយ ប្រសិនបើខ្ញុំចង់សម្រាក គឺអង្គការនឹងយកកាំភ្លើងមកភ្ជង់ខ្ញុំជាមិនខាន ដូច្នេះខ្ញុំខំប្រឹងធ្វើការងារ ទាំងឈឺទាំងជា។ ខ្មែរក្រហមបានប្រើខ្ញុំឲ្យធ្វើការចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង១១ ទើបបានសម្រាកហូបបបរ ឬ ហូបបាយ។ ក្រោយហូបអាហាររួច ខ្ញុំត្រូវចុះធ្វើការបន្តរហូតដល់ម៉ោង៥ល្ងាច ទើបបានទៅសម្រាករៀងៗខ្លួន ប៉ុន្តែមានថ្ងៃខ្លះ ខ្ញុំត្រូវធ្វើការងារដល់ពេលយប់។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានរស់នៅបែកពីឪពុកម្ដាយរហូត។

នៅក្នុងឆ្នាំ១៩៧៨ អង្គការចាត់តាំងខ្ញុំឲ្យចូលក្នុងកងចល័ត ដែលមានមុខព្រួញជីកប្រឡាយនៅបឹងព្រះពន្លៃ រហូតដល់កងទ័ពវៀតណាមចូលមករំដោះប្រទេសកម្ពុជា។ ពេលកងទ័ពវៀតណាមវាយចូលមក ខ្ញុំបានរត់ឡើងភ្នំស្វារអិលជាមួយនឹងប្រជាជនដទៃទៀត។ ខ្ញុំរត់គេចដោយសារខ្មែរក្រហមប្រាប់ថា «នៅពេលដែលកងទ័ពវៀតណាមចាប់បាននឹងយកទៅទម្លុះប្រមុះអូសតាមរថក្រោះ» ធ្វើឲ្យខ្ញុំភ័យក៏រត់តាមខ្មែរក្រហម។ ខ្ញុំរស់នៅលើភ្នំអស់រយៈពេល២ខែ។ នៅពេលខ្ញុំដឹងថាកងទ័ពវៀតណាមចូលមករំដោះប្រជាជន ទើបខ្ញុំចុះពីលើភ្នំ។ បន្ទាប់មកទៀតខ្ញុំបានទៅរស់នៅព្រំដែនថៃ ប៉ុន្តែខ្ញុំមិនទាន់បានជួបជាមួយឪពុកម្ដាយរបស់ខ្ញុំទេ។

នៅឆ្នាំ១៩៨០បានខ្ញុំត្រឡប់មកជួបជាឪពុកម្ដាយនៅស្រុកកំណើតរបស់ខ្ញុំវិញ ហើយមិនយូរប៉ុន្មានខ្ញុំបានរៀបការ។ ខ្ញុំនិងប្ដីចាប់ផ្ដើមប្រកបរបរធ្វើស្រែតាំងពីពេលនោះមក។ នៅក្នុងរបបខ្មែរក្រហម បងប្អូនរបស់ខ្ញុំត្រូវអង្គការខ្មែរក្រហមយកទៅសម្លាប់ចោលយ៉ាងព្រៃផ្សៃដោយសារពួកគាត់ធ្វើជាកងទ័ព។

ទេសភាពចម្ការ និងភ្នំ នៅក្នុងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សូ សុភ័ណ្ឌ៖ អតីតកងនារីជួសជុលផ្លូវ

**ស៊ុយ សុខមាន**



សូ សុភ័ណ្ឌ អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិសង្រែ ឃុំសង្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សូ សុភ័ណ្ឌ ភេទស្រី អាយុ៦៥ឆ្នាំ គឺជាកសិករ កើតនៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំផ្លាស់មករស់នៅភូមិសង្រែក្នុង ឃុំសង្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ សូ ស៊ិន និងម្តាយឈ្មោះ ណប់ សាន់។ ឪពុកម្តាយខ្ញុំបានស្លាប់ក្នុងរបបខ្មែរក្រហមអស់ហើយដោយសារជំងឺ និងអត់អាហារ។ ខ្ញុំមានបងប្អូនចំនួន៩ នាក់គឺប្រុសចំនួន៦នាក់ និងស្រីចំនួន៣នាក់។ ក្រោយពីរបបខ្មែរក្រហមដួលរលំ បងប្អូនរបស់ខ្ញុំស្លាប់ស្ទើរទាំងអស់ គឺនៅរស់តែខ្ញុំម្នាក់ប៉ុណ្ណោះ។ ខ្ញុំបានរៀបការប្តីឈ្មោះ វេន កុយ និងមានកូនចំនួន៧ នាក់ ក្នុងនោះមានកូនប្រុស៥នាក់ និងកូនស្រីចំនួន២នាក់។

កាលពីកុមារ ខ្ញុំបានរៀនត្រឹមថ្នាក់ទី៩ ចាស់ក៏ឈប់រៀនព្រោះប្រទេសចលាចលដោយសារសង្គ្រាម។ នៅឆ្នាំ១៩៧០ ក្រុមគ្រួសារខ្ញុំផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ ហើយនៅទីនោះយើងមានជីវភាពសមរម្យមិនមានការខ្វះខាតអាហារឡើយ។ ចូលមកដល់ឆ្នាំ១៩៧៤ ខ្ញុំ និងប្អូនប្រុសបានធ្វើដំណើរតាមយន្តហោះពីក្រុងភ្នំពេញទៅខេត្តពោធិ៍សាត់ ព្រោះបងប្រុសរបស់ខ្ញុំធ្វើការជាពេទ្យទាហានប្រចាំខេត្តពោធិ៍សាត់។ ប្អូនប្រុសរបស់ខ្ញុំមកខេត្តពោធិ៍សាត់ក្នុងគោលបំណងដើម្បីចូលរៀនក្នុងក្រុងពោធិ៍សាត់។ ចំណែកខ្ញុំកាលណោះ គឺមកលេងបងប្រុស ។ ខ្ញុំស្នាក់នៅទីរួមខេត្តពោធិ៍សាត់បានរយៈពេល៨ខែ ស្រាប់តែកងទ័ពរំដោះខ្មែរក្រហមវាយឈ្នះទាហានលន់ នល់ និងយកបានទីរួមខេត្តពោធិ៍សាត់ទាំងស្រុង។ បងប្អូនខ្ញុំមិនអាចធ្វើដំណើរទៅទីក្រុងភ្នំពេញបានទេ ព្រោះព្រលានយន្តហោះលែងដំណើរការ ចំណែកផ្លូវជាតិលេខ៥ ត្រូវបានកងទ័ពខ្មែរក្រហមដាក់បារាំងស្កាត់តាមផ្លូវ ហាមមិនឲ្យប្រជាជនធ្វើចរាចរណ៍ ចំណែកផ្លូវដាច់ដោយអន្លើដោយសារការទម្លាក់គ្រាប់បែក។

ក្រោយមក កងទ័ពខ្មែរក្រហមជម្លៀសបងប្អូនខ្ញុំមកកាន់ស្រុកភ្នំក្រវាញ។ នៅតាមផ្លូវបងប្រុសខ្ញុំត្រូវបានខ្មែរក្រហមហៅទៅរៀនសូត្រ ហើយបាត់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំនៅសល់តែបងថ្លៃស្រីម្នាក់គត់ជាទីពឹង។

មកដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញពីស្រុកភ្នំក្រវាញឲ្យមករស់នៅវត្តព្រៃខ្លុង។ ខ្ញុំរស់នៅជុំបងប្អូនបានរយៈពេលមួយសប្តាហ៍ បន្ទាប់មកខ្មែរក្រហមចាប់ផ្តើមបំបែកបងប្អូនខ្ញុំចេញទៀត។ ពេលនោះរូបរាងបងថ្លៃរបស់ខ្ញុំគឺមិនស័ក្តិសមធ្វើស្រែចម្ការឡើយ ដូច្នេះខ្មែរក្រហមក៏ហៅគាត់ទៅ

រៀនសូត្រទៀត។ ចំណែក ខ្ញុំត្រូវទៅនៅក្នុងកងចល័តនារីស្ថិតនៅក្នុងភូមិទួលពង្រ។ នៅ ទីនោះ ខ្ញុំជីកប្រឡាយ លើកភ្លឺស្រែ និងលើកផ្លូវ។ កងចល័តខ្ញុំមានសមាជិកច្រើន ហើយការងារភាគច្រើនគឺជួសជុលផ្លូវ។ ចំពោះរបបអាហារគឺមានបាយ ប៉ុន្តែមិនមានម្ហូបទេ។

នៅចន្លោះពីឆ្នាំ១៩៧៦ ដល់ ឆ្នាំ១៩៧៧ ស្ថានភាពរស់នៅរបស់ខ្ញុំកាន់តែលំបាកឡើងៗ ដោយសារខ្មែរក្រហមចែកអង្ករឲ្យមួយកំប៉ុងហូបគ្នា១០នាក់។ ប្រសិនបើ មានអ្នកឈឺ ប្រធានកងបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យ។ នៅសម័យនោះ ខ្មែរក្រហមបានលុបបំបាត់សាសនា សាលារៀន និងសម្លាប់អ្នកចេះដឹង។ ខ្ញុំអាចនៅរស់បានដោយសារប្រធានកងឲ្យខ្ញុំធ្វើការវេនយប់ ដូច្នេះខ្ញុំអាចលួចពោតហូបបាន។ នៅពេលកងទ័ពវៀតណាមចូលមករំដោះ នៅឆ្នាំ១៩៧៩ ខ្ញុំក៏រត់គេចខ្លួនជាមួយប្រជាជនឯទៀតមកភូមិវិញ។ មួយរយៈក្រោយមក ខ្ញុំក៏រៀបការប្តី និងរស់នៅភូមិសង្រ្កែជាមួយប្តីខ្ញុំរហូតមកដល់បច្ចុប្បន្ន។



ផ្ទះរបស់ សូ សុភ័ណ្ឌ នៅភូមិសង្រ្កែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជា ឡូន ៖ គឺជាជនជាតិមិល និងជាអតីតពេទ្យនៅស្រុកសំបូរ

ឌីន សុខណោង



ជា ឡូន ភេទស្រី អាយុ៦២ឆ្នាំ គឺជាជនជាតិភាគតិចមិល បច្ចុប្បន្នរស់នៅភូមិចង្ហូប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ (អតីតស្រុកសំបូរ) ខេត្តក្រចេះ។ (ដិន សុខណោង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជា ឡូន ភេទស្រី អាយុ៦២ឆ្នាំ គឺជាជនជាតិភាគតិចមិល បច្ចុប្បន្នរស់នៅភូមិចង្ហូប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ (អតីតស្រុកសំបូរ) ខេត្តក្រចេះ។ រាល់ថ្ងៃខ្ញុំអាចនិយាយភាសាជនជាតិភាគតិចមិលបានតិចតួច ដូចជាពាក្យ «ឆាពាង» ដែលភាសាខ្មែរមានន័យថា «ហូបបាយ» និងពាក្យមួយចំនួនទៀត។ ខ្ញុំមានបងប្អូន៤នាក់ គឺស្រីចំនួន១នាក់ និងប្រុសចំនួន៣នាក់។ បងប្អូនរបស់ខ្ញុំនៅរស់រានមានជីវិតទាំងអស់បន្ទាប់ពីរបបខ្មែរក្រហម។

កាលពីក្មេង ខ្ញុំបានចូលរៀនដល់ថ្នាក់ទី៣ បន្ទាប់មកខ្ញុំក៏ឈប់រៀននៅឆ្នាំ១៩៧០ ដោយសារមានការទម្លាក់គ្រាប់បែកពីលើយន្តហោះដែលដឹកនាំដោយលោក លន់ នល់។ នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមចូលមកគ្រប់គ្រងភូមិចង្ហូប ដែលពេលនោះខ្ញុំទើបមានអាយុ១៣ឆ្នាំប៉ុណ្ណោះ។

ខ្មែរក្រហមបានបែងចែកប្រជាជនដែលរស់នៅក្នុងភូមិចង្ហូបចេញជាបួនក្រុមដើម្បីធ្វើការងារ។ អំឡុងពេលនោះ ខ្ញុំក៏ឃើញខ្មែរក្រហមជម្លៀសប្រជាជនថ្មីមកពីស្រុកត្រមូង និងភ្នំពេញ ឲ្យមករស់នៅក្នុងភូមិចង្ហូបដែរ ប៉ុន្តែខ្ញុំមិនដឹងថាប្រជាជនទាំងនោះមានជាតិសាសន៍អ្វីខ្លះទេ។ ប្រជាជនថ្មីដែលមករស់នៅភូមិចង្ហូប សុភាពរាបសា និងមិនសូវហ៊ានតមាត់ជាមួយប្រជាជនចាស់ទេ។

មួយរយៈក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅរៀនផ្នែកពេទ្យ និងធ្វើជាគ្រូពេទ្យនៅស្រុកសំបូរ។ ពេលខ្ញុំបម្រើការងារជាគ្រូពេទ្យនៅទីនោះ ខ្ញុំសង្កេតឃើញមានអ្នកជំងឺច្រើនណាស់ ដែលភាគច្រើនមានជំងឺគ្រុន និងអ្នកជំងឺដែលរងរបួសនៅសមរភូមិ។ មានអ្នកជំងឺជាច្រើនបានស្លាប់ដោយសាររងរបួស និងមានជំងឺធ្ងន់ធ្ងរ។

បន្ទាប់ពីរបបខ្មែរក្រហមបញ្ចប់ទៅ នៅឆ្នាំ១៩៧៩ ប្រជាជនថ្មីទាំងនោះបានវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ហើយខ្ញុំក៏មិនដែលឃើញអ្នកទាំងនោះត្រឡប់មកលេងអ្នកភូមិចង្ហូបដែរ។ ខ្ញុំនៅចងចាំថា ប្រជាជនដែលរស់នៅក្នុងភូមិចង្ហូបមួយចំនួនក៏បានស្លាប់ដោយសារជំងឺដែរក្នុងរបបខ្មែរក្រហម។

សព្វថ្ងៃ ខ្ញុំរស់នៅជាមួយប្តីក្នុងភូមិឃុំដដែល ហើយខ្ញុំមានជំងឺប្រចាំកាយ ដូចជា ក្រពះ ពោះវៀន ខ្សោយបេះដូង និងឈឺទ្រូង។

# អឹម វៀត គ្រូបង្រៀនកុមារនៅក្នុងសម័យខ្មែរក្រហម

ទី ស៊ីថា



អឹម វៀត អាយុ៦៦ឆ្នាំ កើតនៅភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អឹម វៀត អាយុ៦៦ឆ្នាំ កើតនៅភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ ព្រំ អឹម និងម្តាយឈ្មោះ សួស ភីម។ ឪពុកខ្ញុំស្លាប់រយៈពេល១០ឆ្នាំហើយដោយសារជំងឺចាស់ជរា។ ចំណែកម្តាយខ្ញុំស្លាប់នៅក្នុងឆ្នាំ១៩៨៦ ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ខ្ញុំមានបងប្អូនចំនួន៦នាក់ ក្នុងនោះមានប្រុស៤នាក់ និងស្រី២នាក់។ ខ្ញុំគឺជាកូនទី២នៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ ជុក ទឹម និងមានកូនចំនួន៧នាក់ ក្នុងនោះមានប្រុស៣នាក់ និងស្រី៤នាក់។

នៅពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ប្រជាជននៅក្នុងភូមិជ្រៃ បានប្រមូលផ្តុំគ្នា រួមទាំងឪពុករបស់ខ្ញុំដើម្បីចូលរួមធ្វើបាតុកម្មតាមទារសម្តេចព្រះ នរោត្តម សីហនុ ឲ្យមកគ្រប់គ្រងអំណាចវិញ។ ពេលនោះ ប្រជាជនទៅចូលរួមធ្វើបាតុកម្មដោយស្ម័គ្រចិត្ត ដោយនាំគ្នាកាន់រូបថតសម្តេចព្រះ នរោត្តម សីហនុ និងលើកបដាតវ៉ា។ ប្រជាជនធ្វើបាតុកម្មនៅបន្ទាយក្រោម នៅជាំទ្រៀក ក្នុងស្រុកមេមត់។ លុះអ្នកតវ៉ាទៅដល់ខ្នងក្រពើ ទាហាន លន់ នល់ ក៏ដេញបាញ់បាតុកររត់ពេញវាលស្បែង។ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារហើយប្រជាជនមិនបានធ្វើស្រែចម្ការរយៈពេលមួយឆ្នាំ ព្រោះពេលបាតុកម្មរួចក៏មានឧទ្ធម្ភាគចក្រហោះមកទម្លាក់គ្រាប់បែកនៅខ្នងក្រពើ និងនៅវាលយន្តហោះ។ ចាប់ពីម៉ោង៦ព្រឹកដល់ម៉ោង៧ព្រឹក មានឧទ្ធម្ភាគចក្រហោះមកទម្លាក់គ្រាប់ និងបាញ់ផ្លោង ដូច្នេះប្រជាជនក៏នាំគ្នារត់ចូលព្រៃអង្គររយៈពេល៤ទៅ៥យប់ ហើយប្រជាជនខ្លះទៀតលាក់ខ្លួនរហូតដល់កន្លះខែ។ អំឡុងពេលនោះ កងទ័ពអាមេរិក ក៏ចូលមកដាក់បន្ទាយនៅតាមចម្ការរបស់ប្រជាជនដែរ។ ចំណែកការហូបចុក យើងយកអង្ករដែលប្រមូលផលបានឆ្នាំចាស់យកមកហូប។ ពេលស្ងាត់គ្រាប់ផ្លោង និងគ្រាប់បែក យើងចាប់ផ្តើមដាំបាយហូប ប៉ុន្តែពេលល្ងាចខ្លះយើងមិនហ៊ានដាំបាយទេ ព្រោះយន្តហោះ ហោះហើរទៅមកនៅឡើយ។

សម័យនោះ ប្រជាជនភាគច្រើនឈឺជ្រុះសក់ ព្រោះក្តៅ និងហប់ខ្យល់ពេលពួននៅក្នុងរណ្តៅ

ត្រង់សេ។ ខ្ញុំមិនហ៊ានហូបបាយលើផ្ទះទេ គឺហូបនៅក្នុងព្រៃក្រោយផ្ទះ។ លុះដល់ឆ្នាំ១៩៧១ការរស់នៅរបស់ប្រជាជនបានប្រសើរបន្តិច ព្រោះអាចដើរបេះបន្លែតាមព្រៃបានខ្លះ។ ខ្ញុំនៅធ្វើស្រែចម្ការជាមួយឪពុកម្ដាយ ហើយពេលខ្លះក៏មានការបាញ់ផ្លោង និងទម្លាក់គ្រាប់បែកចង្កោមនៅម្ដុំអណ្ដូងជិតវត្តនៅឡើយ។ ពេលនោះឧទ្ធម្ភាគចក្រហោះឆ្លាស់គ្នាទៅមក ដើម្បីទម្លាក់គ្រាប់លាន់ព្រំពង ធ្វើឲ្យខ្ញុំមិនបានដេកពួនឡើយ។ មកដល់ឆ្នាំ១៩៧២ ស្រាប់តែមានការទម្លាក់គ្រាប់បែក បេ-៥២ ថែមទៀត។

កាលនោះ ក្មេងៗរៀននៅពេលយប់ផង និងរត់គេចពីគ្រាប់បែកផង។ នៅពេលឃើញភ្លើងឧទ្ធម្ភាគចក្រភ្លឺភ្លែតៗហោះមកពីចម្ងាយនៅវេលាម៉ោង៦ទៅ៧យប់ ក្មេងៗនាំគ្នារត់ចូលរណ្ដៅត្រង់សេអស់ហើយ ដូច្នេះឧទ្ធម្ភាគចក្រក៏ហួសទៅទម្លាក់នៅក្នុងព្រៃឆ្ងាយៗភូមិវិញ។ ឧទ្ធម្ភាគចក្រទម្លាក់គ្រាប់ពុំគ្រាំៗ ហើយពេលឮសំឡេងឧទ្ធម្ភាគចក្រហោះត្រឡប់ទៅវិញ ក្មេងៗចេញពីរណ្ដៅត្រង់សេឡើងមករៀនបន្ត។ នៅឆ្នាំ១៩៧៤ មិនមានការទម្លាក់គ្រាប់បែកទៀតទេ ហើយខ្មែរក្រហមក៏ចាប់ផ្ដើមរៀបចំការរស់នៅរបស់ប្រជាជនក្នុងភូមិទៅជាសហករណ៍ធ្វើស្រែចម្ការ ប៉ុន្តែហូបបាយនៅតាមផ្ទះរៀងៗខ្លួននៅឡើយ។ លុះដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដាក់ភូមិជ្រៃជាភូមិគំរូ ដោយចាប់ផ្ដើមឲ្យប្រជាជនក្នុងភូមិជ្រៃហូបបាយរួមមុនគេក្នុងចំណោមភូមិទាំងអស់ក្នុងស្រុកត្រមូង។ ខ្មែរក្រហមចាប់ផ្ដើមប្រមូលក្មេងប្រុសទាំងអស់ដែលមានអាយុចាប់ពី១៣-១៨ឆ្នាំឡើងទៅឲ្យទៅធ្វើទាហាន។ ខ្មែរក្រហមបានរៀបចំរចនាសម្ព័ន្ធភូមិជ្រៃរួចរាល់អស់ហើយ ក៏ចាប់ផ្ដើមរៀបចំនៅតាមភូមិផ្សេងៗទៀត។

ពេលនោះ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យបង្រៀនក្មេងនៅក្នុងភូមិជ្រៃនៅពេលព្រឹក ហើយពេលរសៀលទៅឃ្វាលគោ-ក្របី។ ខ្ញុំបង្រៀនក្មេងៗចាប់ពីម៉ោង៧ព្រឹក ដល់ម៉ោង ៩ ព្រឹក ដោយបង្រៀនអក្សរ ក ខ គ និងស្រៈ។ ចំណែកបងប្រុសរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើជាទាហាន និងមិនបានរស់នៅជួបជុំជាមួយគ្រួសារឡើយ។ ខ្ញុំបង្រៀនបានរយៈពេល២ឆ្នាំ ខ្មែរក្រហមឈប់ឲ្យខ្ញុំបង្រៀន ហើយចាត់តាំងខ្ញុំឲ្យទៅជីកអាងទឹក ជីកព្រែក និងលើកប្រព័ន្ធភ្លឺស្រែ ជាមួយកងចល័ត។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្ដើមកំណត់ក្នុងកងចល័តម្នាក់ត្រូវរែកដីឲ្យបានមួយម៉ែត្រគុប។ នៅខែប្រាំងខ្ញុំត្រូវជីកប្រឡាយ ហើយខែវស្សាធ្វើស្រែរួម។ ក្រោយមក ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅស្រុកស្ទួល ខេត្តក្រចេះ។ ខ្ញុំទៅនៅឃុំសំពូច និងស្រែរនាម ប៉ុន្តែខ្ញុំពិបាករស់នៅណាស់ ព្រោះខ្ញុំគឺជាប្រជាជនជម្លៀសទៅថ្មី។ ប្រធានកងចាត់តាំងខ្ញុំឲ្យលើកទំនប់ ប៉ុន្តែខ្មែរក្រហមមិនបានចាត់ទុកខ្ញុំជាប្រជាជនខ្មែរទេ គឺចោទខ្ញុំនិងប្រជាជនជម្លៀសទៅថ្មីថា ក្បាលយួនខ្លួនខ្មែរ ឬ «ពួកបូព៌ា»។ នៅស្រែរនាមមានមនុស្សស្លាប់ច្រើនព្រោះខ្មែរក្រហមបង្ខំឲ្យធ្វើការហួសលើសកម្លាំង។ មានអ្នកខ្លះត្រូវបានខ្មែរក្រហមវាយនៅកណ្ដាលស្រែ ព្រោះធ្វើការមិនគ្រប់តាមផែនការកំណត់។

ខ្ញុំធ្វើការនៅស្រែរនាមរហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយចូលមក ក៏បានរត់ទៅថ្មគ្រែដើម្បីជិះស្រឡាងឆ្លងទៅស្រុកស្ទឹងត្រង់ ហើយបន្តទៅរស់នៅស្រុកចំការលើ។ ចំណែកឪពុកម្ដាយខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅតាំងគោក ហើយខ្ញុំក៏បែកពីពួកគាត់។ ពេលខ្ញុំទៅដល់ស្រុកចំការលើ ខ្មែរក្រហមចាត់តាំងខ្ញុំទៅច្រូតស្រូវ ចំណែកការហូបចុកគឺបានឆ្អែត។ ខ្ញុំរស់នៅស្រុកចំការលើបានរយៈពេល៣ខែ ទើបប្រទេសត្រូវបានរំដោះនៅថ្ងៃទី៧ ខែមករា។ ពេលនោះ ខ្ញុំកំពុងតែកងកណ្ដាប់យកមកទុក ក៏ឮវិទ្យុមួយក្បែរនោះផ្សាយឈ្មោះសមមិត្តហេង សំរិន និងផ្សាយថាប្រទេសត្រូវបានរំដោះហើយ សូមបងប្អូនត្រឡប់ទៅស្រុកកំណើតវិញ។ ខ្ញុំបានធ្វើដំណើររយៈពេលជិត១០ថ្ងៃ ទើបមកជួបឪពុកម្ដាយខ្ញុំនៅស្រុកមេមត់។ ចំណែកប្អូនៗរបស់ខ្ញុំបានស្លាប់អស់ច្រើននៅស្រុកតាំងគោក ខេត្តកំពង់ធំ គឺសល់តែប្អូនស្រីម្នាក់បានមកដល់ផ្ទះ ប៉ុន្តែជាអកុសលប្អូនស្រីរបស់ខ្ញុំក៏ឈឺស្លាប់ទៀត នៅសល់តែខ្ញុំម្នាក់រហូតមកដល់សព្វថ្ងៃ។

# សិស្សានុសិស្សនៃវិទ្យាល័យ ហេង សំរិន ឬស្សីស្រុកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

**សាំង ចាន់ធូ**







សិស្សានុសិស្សនៃវិទ្យាល័យ ហេង សំរិនបុស្សីស្រុកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើប្រធានបទ «ការបង្ខំឲ្យធ្វើការជាទម្ងន់ក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ហេង សំរិនបុស្សីស្រុក សរុបចំនួន ៥០នាក់។ វេទិកាថ្នាក់រៀនចុងសប្តាហ៍នេះ រៀបចំឡើងដើម្បីផ្តល់ចំណេះដឹងដល់សិស្សានុសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។

លោក ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលស្វាគមន៍គណៈគ្រប់គ្រងសាលា និងសិស្សានុសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ហេង សំរិនបុស្សីស្រុក និងដឹកនាំអ្នកចូលរួមវេទិកាថ្នាក់រៀនទាំងអស់ទស្សនាពិព័រណ៍រូបថត។ លោក ទូច វណ្ណេត ពន្យល់អំពីផ្ទាំងពិព័រណ៍រូបថតនីមួយៗទៅកាន់គណៈគ្រប់គ្រងសាលា និងសិស្សានុសិស្សរួមមាន៖ ការកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅសាលា

ក្តីខ្មែរក្រហម, ប្រវត្តិមេដឹកនាំខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំ, ការបង្ខំប្រជាជនឲ្យធ្វើការហួសកម្លាំង, និងការវិលត្រឡប់មកស្រុកកំណើតវិញរបស់ប្រជាជនកម្ពុជា បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩។ បន្ទាប់មក គណៈគ្រប់គ្រងសាលា និងសិស្សានុសិស្ស បន្តចូលទស្សនាពិព័រណ៍ «ក្តីសុបិនកម្ពុជា» របស់ព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ, បណ្ណាល័យខ្មែរក្រហមដែលមានតម្កល់សៀវភៅទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម និងបន្ទប់តម្កល់ឯកសារ។

ជាកិច្ចបន្ត លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានធ្វើបទបង្ហាញអំពី ប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ លោក ស៊ាង ចិន្តា បង្ហាញអំពីបរិបទ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ រួមមាន រដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមជិត៥ឆ្នាំរវាងកងទ័ពលន់នល់ និងកងទ័ពខ្មែរក្រហម, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ, ការបង្ខំប្រជាជនឲ្យធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ និងការកាប់សម្លាប់ទៅលើប្រជាជន។ លោក ស៊ាងចិន្តា លើកឡើងអំពីការពិភាក្សាស្តីពីការបង្ខំឲ្យប្រជាជនធ្វើការជាទម្ងន់ក្នុងរបបខ្មែរក្រហម។ ប្រជាជនទទួលរងការបង្ខំឲ្យធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ ដែលបណ្តាលឲ្យមានបញ្ហាសុខភាពទ្រុឌទ្រោម។ បន្ទាប់ពីមេដឹកនាំខ្មែរក្រហមបានដាក់ចេញ និងអនុវត្តផែនការ៤ឆ្នាំ (១៩៧៧-១៩៨០)។ ផែនការ៤ឆ្នាំផ្តោតសំខាន់ទៅលើការបង្កើនទិន្នផលស្រូវ។ ខ្មែរក្រហមបានប្រមូលផ្តុំប្រជាជនដើម្បីលើកទំនប់ ដែលជាផ្នែកសំខាន់មួយក្នុងការកសាងប្រព័ន្ធធារាសាស្ត្រ។ នៅតាមការដ្ឋានទំនប់ ប្រជាជនទទួលរងការបង្ខំឲ្យធ្វើការងារគ្មានពេលសម្រាក, របបអាហារមិនទទួលបានគ្រប់គ្រាន់, ការធ្លាក់ខ្លួនឈឺដោយគ្មានថ្នាំព្យាបាល និងការចាប់យកទៅសម្លាប់ ដែលបណ្តាលឲ្យមានមនុស្សជាច្រើនបានស្លាប់បាត់បង់ជីវិត។ ដើម្បីឈ្វេងយល់ជាក់ស្តែងបន្ថែមអំពីប្រធានបទពិភាក្សាខាងលើ គណៈគ្រប់គ្រង និងសិស្សានុសិស្សទាំងអស់បានចុះទស្សនកិច្ចផ្ទាល់ទៅកាន់ទំនប់ដែលត្រូវបានកសាងនៅក្នុងរបបខ្មែរក្រហម គឺទំនប់ក្បាលទឹក ស្ថិតនៅក្នុងឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ ការចុះទៅកាន់ទីតាំងទំនប់ក្បាលទឹកមិនត្រឹមតែអនុញ្ញាតឲ្យសិស្សានុសិស្សឃើញផ្ទាល់អំពីស្ថានភាពទំនប់ជាក់ស្តែង និងស្រមៃគិតអំពីគ្រាដែលប្រជាជនត្រូវបានបង្ខំឲ្យធ្វើការលើកទំនប់គ្មានពេលសម្រាក, អាហារហូបចុកមិនគ្រប់គ្រាន់ និងក្រោមកម្តៅថ្ងៃតែប៉ុណ្ណោះទេ គឺការចុះទៅកាន់ទីតាំងដែលប្រជាជនទទួលរងទុក្ខលំបាកក៏បានបណ្តុះចិត្តអាណិតអាសូររបស់សិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយទៅកាន់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ខ្ញុំឈ្មោះ **ចាន់ធន សុខលាង** រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ហេង សំរិន បុស្សីស្រុក។ ក្រោយពេលដែលខ្ញុំបានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ខ្ញុំទទួលបានមេរៀនជាក់ស្តែង និងចំណេះដឹងជាច្រើនសម្រាប់ខ្ញុំ។ ខ្ញុំបន្តយកអ្វីដែលខ្ញុំទទួលបាននាពេលនេះទៅធ្វើការស្រាវជ្រាវបន្ថែមនៅផ្ទះដោយការសាកសួរលោកតាលោកយាយរបស់ខ្ញុំបន្ថែម និងសួរអ្នកគ្រូប្រវត្តិវិទ្យានៅសាលា។



សិស្សានុសិស្សនៃវិទ្យាល័យ ហេង សំរិនបុស្សីស្រុក ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)







*សិស្សានុសិស្សនៃវិទ្យាល័យ ហេង សំរិនបុស្សីស្រុក ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ **លីម សេដ្ឋវិសាល** រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ហេង សំរិនបុស្សីស្រុក។ ខ្ញុំមានអារម្មណ៍សប្បាយចិត្តចំពោះការចំណាយពេលវេលាចុងសប្តាហ៍មករៀនពីប្រវត្តិ-សាស្ត្រខ្មែរក្រហម។ ខ្ញុំយល់ច្រើនពីប្រវត្តិសាស្ត្រខ្មែរដែលប្រជាជនទទួលរងទុក្ខវេទនាយ៉ាងខ្លាំង ទាំងការរស់នៅ និងការហូបចុក។ ដូចទៅនឹងសាច់រឿងរបស់លោកតារបស់ខ្ញុំ តែងតែប្រាប់ខ្ញុំអំពីភាពលំបាកក្នុងការហូបចុកយ៉ាងខ្លាំង សូម្បីតែដំណាំដែលខ្លួនឯងដាំក៏មិនអាចហូបបានដែរ។ ខ្ញុំនឹងយកចំណេះដឹង និងបទពិសោធន៍ដែលខ្ញុំទទួលបាននាពេលនេះ ទៅចែករំលែកជាមួយមិត្តភក្តិ និងសិស្សប្អូនឲ្យបានដឹង និងចូលរួមការពារសន្តិភាពកុំឲ្យរបបខ្មែរក្រហមនេះវិលត្រឡប់មកវិញជាថ្មីម្តងទៀត។

ខ្ញុំឈ្មោះ **លីម សុភ័ក្រ្តា** រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ហេង សំរិនបុស្សីស្រុក។ នៅពេលដែលខ្ញុំបានចូលរួមវេទិកាថ្នាក់រៀនជាមួយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ខ្ញុំមានអារម្មណ៍រំភើបរីករាយជាខ្លាំងពីព្រោះខ្ញុំបានចំណាយពេលវេលាសម្រាកចុងសប្តាហ៍ដើម្បីទទួលបានចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការចុះទៅកាន់ទីតាំងទំនប់កសាងក្នុងរបបខ្មែរក្រហម។ ចំណេះដឹងដែលខ្ញុំទទួលបានថ្មីគឺ ព្រឹត្តិការណ៍ការជម្លៀសប្រជាជនដោយបង្ខំ និងការបង្ខំឲ្យធ្វើការហួសកម្លាំងដែលធ្វើឲ្យប្រជាជនស្លាប់ និងមានភាពទ្រុឌទ្រោម។ កាលពីមុនយាយរបស់ខ្ញុំធ្លាប់បាននិយាយប្រាប់ខ្ញុំអំពីរឿងរ៉ាវដែលគាត់ឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមដែរ។ គាត់បាននិយាយថា នៅរបបខ្មែរក្រហម ប្រជាជនហូបអាហារបានតែបន្តិចបន្តួចតែប៉ុណ្ណោះ ប៉ុន្តែប្រើប្រជាជនឲ្យធ្វើការងារគ្មានពេលសម្រាកទេ។ នៅពេលដែលលោកយាយនិយាយប្រាប់ខ្ញុំម្តងៗ ខ្ញុំមានចិត្តអាណិតលោកយាយណាស់។

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកា

## វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សមកពីវិទ្យាល័យតេជោសែន សំរោង

**សួត វិចិត្រ**



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សមកពីវិទ្យាល័យតេជោសែនសំរោង ចំនួន៣៧ នាក់ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សានុសិស្សមកពីវិទ្យាល័យតេជោសែនសំរោង ចំនួន៣៧ នាក់ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤។ វេទិកាថ្នាក់រៀននេះមានគោលបំណងលើកកម្ពស់ការចងចាំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញទៅកាន់សិស្សានុសិស្ស ព្រមទាំងចាក់បញ្ចាំងខ្សែភាពយន្តឯកសារ ទាក់ទងទៅនឹងជ័យជម្នះរបស់ខ្មែរក្រហមនៅពេលដណ្តើមបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា ដើម្បីឲ្យទៅធ្វើការងារនៅក្នុងសហករណ៍នៅតាមជនបទដាច់ស្រយាល។ ប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួន និងគ្មានគោលដៅច្បាស់លាស់។ ប្រជាជនរាប់សិបនាក់បានស្លាប់ដោយសារការខ្វះអាហារ ជំងឺ និងការសម្លាប់នៅតាមផ្លូវ។ បទបង្ហាញក៏ផ្តោតសំខាន់ទៅលើការធ្វើទុក្ខបុកម្នេញរបស់ខ្មែរក្រហមទៅលើប្រជាជន និង



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សមកពីវិទ្យាល័យតេជោសែនសំរោង ចំនួន៣៧ នាក់ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃដែរ។

ទួលពោធិ៍ជ្រៃ គឺជាទីវាលធំមួយ ស្ថិតនៅកៀកនឹងបឹងទន្លេសាប និងជាប់តំបន់ព្រៃនាមៗ តាមការប៉ាន់ស្មានថា ទាហាន លន់ នល់ ត្រូវបានសម្លាប់នៅទីនោះចន្លោះពី២ពាន់ ទៅ៨ពាន់នាក់។ បន្ទាប់មកសិស្សានុសិស្សបានទស្សនាកុនឯកសារមន្ទីរស-២១ ឬគុកទួលស្លែង ដែលត្រូវបានថតដោយអ្នកថតរូបជនជាតិវៀតណាមម្នាក់ឈ្មោះ ហូ វ៉ាន់តៃ ក្នុងពេលបំពេញបេសកកម្មជាមួយកងទ័ពវៀតណាមនៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩។ នៅទីនោះបានលេចចេញនូវក្លិនអសោច ដែលបង្កឲ្យមានការសង្ស័យ និងចូលទៅកាន់ទីនោះ ក៏ប្រទះឃើញនូវសាកសពអ្នកទោសដែលបានស្លាប់ជាមួយនឹងដៃជើងជាប់ខ្នោះ និងច្រវាក់យ៉ាងព្រៃផ្សៃ។ អ្នកទោសប្រមាណ១៨០០០នាក់ ត្រូវបានឃុំឃាំងនៅក្នុងគុកទួលស្លែង ហើយនៅពេលរបបខ្មែរក្រហមដួលរលំ អ្នកទោសប្រមាណ១២នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត។ តាមរយៈបទបង្ហាញ និងការចាក់បញ្ចាំងកុនឯកសារខាងលើនេះ វេទិកាថ្នាក់រៀនបានផ្សារភ្ជាប់ទៅនឹងអង្គហេតុ (អំពើឃោរឃៅ និងទីតាំងប្រព្រឹត្តអំពើឃោរឃៅ) និងទិដ្ឋភាពផ្លូវច្បាប់នៅក្នុងដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬសាលាក្តីខ្មែរក្រហម។

សំណុំរឿង០០១ ជាបទចោទប្រកាន់ទៅលើ កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺជាអតីតប្រធានមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង ហើយ ឌុច ត្រូវបានតុលាការរកឃើញថា មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ចំណែកឯសំណុំរឿង០០២ គឺពាក់ព័ន្ធទៅនឹងបទចោទលើ អៀង សារី, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ។ ទោះជាយ៉ាងនេះក្តី អៀង សារី និង អៀង ធីរិទ្ធ បានស្លាប់ និងមិនត្រូវបានជំនុំជម្រះទោស ដូច្នេះពិរុទ្ធជនចំនួនពីររូបដែលនៅរស់រានមានជីវិតរួមមាន៖ នួន ជា និង ខៀវ សំផន ត្រូវបានតុលាការជំនុំជម្រះ និងរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយបានរៀបចំផែនការញុះញង់ និងជួយជំរុញឲ្យមានឧក្រិដ្ឋកម្ម ដូចជា មនុស្សឃាត ការធ្វើទុក្ខ





មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀន ស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សមកពីវិទ្យាល័យតេជោសែន សំរោង ចំនួន៣៧ នាក់ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗក្នុងពេលនៃការជម្លៀសប្រជាជនពីលំនៅឋានដំណាក់កាលទី១ និងដំណាក់កាលទី២ ព្រមទាំងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។

នៅផ្នែកចុងក្រោយ សិស្សានុសិស្សក៏បានរៀនអំពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត ដោយផ្តើមចេញពីកម្រិតបុគ្គលម្នាក់ៗ ក្រុមគ្រួសារ សហគមន៍ និងប្រទេសជាតិទាំងមូល។ ខាងក្រោមគឺជាចំណាប់អារម្មណ៍របស់សិស្សានុសិស្សចំនួន៤រូប ដែលបានបង្ហាញទស្សនយល់ឃើញបន្ទាប់ពីចូលរួមក្នុងវេទិកាថ្នាក់រៀន៖

**ភ្លន់ គា** ភេទស្រី អាយុ១៨ឆ្នាំ រៀបរាប់ថា «វេទិកាថ្នាក់រៀនក្នុងថ្ងៃនេះ ខ្ញុំចាប់អារម្មណ៍ទៅលើកុនឯកសារទាក់ទងនឹងមន្ទីរសន្តិសុខស-២១ ដែលបង្ហាញនូវទិដ្ឋភាពដ៏ព្រៃផ្សៃដូចជាការធ្វើទារុណ-កម្មអ្នកទោស។ ខ្ញុំគិតថា មិនគួរណាខ្មែរក្រហមប្រព្រឹត្តទង្វើឃោរឃៅដល់ថ្នាក់នេះទេ។ ដើម្បីចូលរួមទប់ស្កាត់អំពើឃោរឃៅ និងអំពើប្រល័យពូជសាសន៍បែបនេះ គឺយើងត្រូវលុបបំបាត់ការរើសអើង, បេះសាមគ្គីគ្នា និងស្រឡាញ់គ្នាគ្រប់ជាតិសាសន៍ទាំងអស់, ជំរុញការអប់រំ, ការអានសៀវភៅ, ការរៀនសូត្រតាមប្រព័ន្ធទូរសព្ទដៃ ប៊ុអ៊ីនធឺណែត, វិទ្យុ និងទូរទស្សន៍ជាដើម ជាពិសេស គឺត្រូវបេះរកដំណោះស្រាយដោយសន្តិវិធីចំពោះជម្លោះនានា»។

**លី បាល់** ភេទប្រុស អាយុ១៨ឆ្នាំ យល់ឃើញថា «ខ្ញុំបានរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម និងអំពីសង្គ្រាមជាច្រើនដំណាក់កាលក្នុងថ្ងៃនេះ ជាពិសេស គឺអំពើឃោរឃៅ និងការកាប់សម្លាប់ទៅលើជនជាតិខ្មែរដូចគ្នា។ សម្រាប់ខ្ញុំការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជារឿងដ៏ស័ក្តិសម និងយុត្តិធម៌បំផុតដោយសារតែគាត់បានប្រព្រឹត្តអំពើបាបជាច្រើនកន្លងមក ហើយការកាត់ទោសនេះ គឺជាគំរូដល់មនុស្សជំនាន់ក្រោយកុំឲ្យប្រព្រឹត្តទង្វើបែបនោះបន្តទៀត»។

**ធឿន ចានរិត** ភេទស្រី អាយុ២១ឆ្នាំ លើកឡើងថា «វេទិកាថ្នាក់រៀនក្នុងថ្ងៃនេះ ខ្ញុំបានចងចាំអំពីអំពើប្រល័យពូជសាសន៍ ការគ្រប់គ្រង និងការធ្វើសង្គ្រាម។ នៅក្នុងនោះ ខ្ញុំឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងទៅទីជនបទ គឺជាអំពើមួយដែលមិនត្រឹមត្រូវដោយសារបង្កនូវផលវិបាកដល់ប្រជាជនក្នុងទីកន្លែងមួយដែលមិនមែនជាផ្ទះរបស់ខ្លួន»។

**រិទ្ធ ស្រីពៅ** ភេទស្រី អាយុ១៨ឆ្នាំ ឲ្យដឹងថា «ខ្ញុំបានរៀនសូត្រពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទយ៉ាងសង្វេគ។ នៅពេលនោះប្រជាជនមិនបានត្រៀមខ្លួនទេ សូម្បីតែចំណីអាហារ។ ខ្ញុំក៏បានយល់ដឹងអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងសំណុំរឿង០០១ និង០០២ ជាពិសេសទៅលើការកាត់ទោស នួន ជា និង ខៀវ សំផន»។

# សិស្សវិទ្យាល័យ ចារថ្មី ចូលរួមវេទិកាថ្នាក់រៀន ស្តីអំពី «ទំនាក់ទំនងការបរទេសទូទៅ កម្ពុជា-ចិន» ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

**សុភ័ត្រ ភាណា**







*នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ សិស្សវិទ្យាល័យ ចារថ្មី ចំនួន៨១នាក់ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ទំនាក់ទំនងការបរទេសទូទៅ កម្ពុជា-ចិន» និងជីវិតរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យ ចារថ្មី ប្រកបដោយស្មារតីសុរា ហាប់ចំនួន ៨១នាក់បានចូលរួមនៅក្នុងថ្នាក់រៀនស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលជារបបដ៏សាហាវយង់ឃ្នងគ្រប់គ្រងប្រទេសកម្ពុជានៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ បន្ទប់រៀនប្រើប្រាស់ដើម្បីរៀបចំវេទិកានេះឡើង ត្រូវបានតុបតែងលម្អជាពាក់កណ្តាលសារមន្ទីរ- ពាក់កណ្តាលថ្នាក់រៀន ដោយមានតាំងបង្ហាញនូវរូបភាព និងឯកសារបង្ហាញអំឡុងពេលប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនេះ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពាក់ព័ន្ធនានា។

វេទិកាថ្នាក់រៀននេះចាប់ផ្តើមឡើងដោយការពិពណ៌នារៀបរាប់របស់អ្នកស្រី សុភ័ត្រ ភាណា ប្រធានគម្រោងស្រាវជ្រាវភាសាចិននៃមជ្ឈមណ្ឌលឯកសារកម្ពុជា ទៅកាន់សិស្សានុសិស្សលើផ្ទាំងពិព័រណ៍នីមួយៗ។ អ្នកស្រី សុភ័ត្រ ភាណា ក៏បានបំផុសការពិភាក្សាអំពីប្រធានបទទូទៅមួយចំនួនដូចជា ៖ ការជម្លៀសប្រជាជន ដោយបង្ខំចេញពីទីក្រុង, ការធ្វើការងារកសិកម្មហួសកម្លាំង និងការស្លាប់បាត់បង់ជីវិតរបស់ប្រជាជនរាប់លាននាក់។

សិស្សានុសិស្សបានចោទជាសំណួរប្រកបដោយការត្រិះរិះពិចារណា ដែលជំរុញឲ្យកិច្ចពិភាក្សា

ប្រព្រឹត្តទៅគួរជាទីចាប់អារម្មណ៍។ សំណួរទាំងនោះផ្តោតទៅលើទំនាក់ទំនងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានមើលរំលង។ សិស្សមានការចាប់អារម្មណ៍ចំពោះទំនាក់ទំនងរបស់កម្ពុជាប្រជាធិបតេយ្យជាមួយប្រទេសជិតខាង និងសម្ព័ន្ធភាពនៃរបបនេះជាមួយនឹងមហាអំណាចមួយចំនួននាពេលនោះ។ យើងបានវិភាគអំពីរូបភាពស្តីពី «ការរួមសាមគ្គីបដិវត្តន៍» ជាមួយប្រទេសក្នុងប្លុកកុម្មុយនីស្ត និងចោទជាចម្ងល់អំពីតថភាពនៅពីក្រោយទំនាក់ទំនងនេះ។

វេទិកាបានប្រព្រឹត្តទៅដោយសកម្ម។ សិស្សម្នាក់បានលើកឡើងថាតើកម្ពុជាប្រជាធិបតេយ្យធ្លាប់ព្យាយាមបញ្ចុះបញ្ចូលឲ្យសហគមន៍អន្តរជាតិឲ្យគាំទ្រលើគោលនយោបាយជ្រុលនិយមហួសវិស័យរបស់ខ្លួនដែរឬទេ? សំណួរនេះបានជំរុញឲ្យមានការពិភាក្សាអំពីការដាក់ឲ្យនៅឯកោលើរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែមនោគមវិជ្ជាជ្រុលនិយម និងការធ្វើទណ្ឌកម្មឃោរឃៅលើប្រជាជនខ្លួន។

នៅចុងបញ្ចប់នៃវេទិកា យើងបានសំយោគចេញនូវតថភាពច្បាស់មួយថា ទំនាក់ទំនងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យមានសណ្ឋានស្មុគស្មាញ និងប្រទាក់ក្រឡាគ្នា ដោយគួបផ្សំជាមួយនឹងមហិច្ឆតាព្រមទាំងបញ្ហូសតិអារម្មណ៍ ដែលរុញច្រានឲ្យរបបនេះបរាជ័យនៅចុងបញ្ចប់។ ពិព័រណ៌អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្របានផ្តល់ជាមូលដ្ឋានដ៏ចាំបាច់អមជាមួយនឹងការចង់ចេះចង់ដឹង និងសំណួររបស់សិស្សានុសិស្ស ដែលញាំងឲ្យវេទិកាថ្នាក់រៀនស្តីអំពី «ទំនាក់ទំនងការបរទេសទូទៅ កម្ពុជា-ចិន» និងជីវិតរស់នៅក្រោមរបបខ្មែរក្រហម ប្រព្រឹត្តទៅដោយសកម្ម។



នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ សិស្សវិទ្យាល័យ ចារថ្មី ចំនួន៨១រូប ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ទំនាក់ទំនងការបរទេសទូទៅ កម្ពុជា-ចិន» និងជីវិតរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)





# សិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់ និងវិទ្យាល័យ ហេង សំរិន ឫស្សីស្រុក ចូលរួមការត្រួតពិនិត្យ

## និងវាយតម្លៃទៅលើវេទិកាថ្នាក់រៀន និងវេទិកាអប់រំសហគមន៍ ស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា

**ទូច វណ្ណេត និងសាំង ចាន់ធូ**







សិស្សនៃវិទ្យាល័យ ហ៊ុន សែន ស្គន់ និងវិទ្យាល័យ ហេង សំរិន ឫស្សីស្រុក ចូលរួមការត្រួតពិនិត្យ និងវាយតម្លៃទៅលើវេទិកាថ្នាក់រៀន និងវេទិកាអប់រំសហគមន៍ ស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ នៅកម្ពុជា។
(សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចន្លោះពីថ្ងៃទី១០ ខែមីនា ដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយលោក សាំង ចាន់ធូ, លី ដេវីត, ស៊ាង ចិន្តា និង ទូច វណ្ណេត ចុះទៅជួបសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុន សែន ស្គន់ និងវិទ្យាល័យ ហេង សំរិន ឫស្សី ស្រុក សរុបចំនួន ១៥ នាក់ ដែលបានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នាពេលកន្លងមកៗ ការចុះជួបផ្ទាល់ជាមួយសិស្សថ្នាក់ទី១២ ទាំងពីរវិទ្យាល័យនេះ គឺដើម្បីអនុញ្ញាតដល់អ្នកចូលរួមផ្តល់ការវាយតម្លៃចំពោះវេទិកាថ្នាក់រៀនៗ

ខាងក្រោមនេះគឺជាការសរសេរវាយតម្លៃ និងចំណាប់អារម្មណ៍របស់សិស្សថ្នាក់ទី១២ ចំនួន៣នាក់ក្នុងចំណោមសិស្ស១៥នាក់ដែលបានផ្តល់ការវាយតម្លៃទៅលើវេទិកាថ្នាក់រៀន ដូចខាងក្រោម៖

សិស្សឈ្មោះ **ផាន់ ស្រីឡែន** រៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុនសែនស្ពានដែលបានចូលរួម«វេទិកាថ្នាក់រៀន ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» លើកឡើងថា៖«ចំណេះដឹងដែលខ្ញុំនៅចាំមិនភ្លេចដែលទទួលបានពីវេទិកាប្រវត្តិសាស្ត្រខ្មែរក្រហម រួមមាន ការលុបបំបាត់ការប្រើប្រាស់រូបិយប័ណ្ណ (លុយ) និងការលុបបំបាត់សាសនា។ បន្ថែមលើនេះទៀត ខ្ញុំបានដឹងអំពីវិធីសាស្ត្រទប់ស្កាត់អំពើហិង្សា ឬអំពើប្រល័យពូជសាសន៍ ដូចជាការដោះស្រាយជម្លោះដោយសន្តិវិធី និងការប្រឆាំងការរើសអើង។ ខ្ញុំក៏ធ្លាប់យកចំណេះដឹងដែលខ្ញុំរៀនទៅនិយាយជាមួយឪពុកម្តាយ និងមិត្តភក្តិក្នុងថ្នាក់ដែរ។ ជាចុងក្រោយ ខ្ញុំមានសំណូមពរចំពោះ វេទិកាថ្នាក់រៀននេះ គឺឲ្យមានការពិភាក្សាជាក្រុម ដើម្បីទទួលបានបទពិសោធន៍ ចំណេះដឹង និងមានការឡើងធ្វើបទបង្ហាញពីសមាជិកក្រុម។

សិស្សឈ្មោះ **ម៉ានី សុវណ្ណារចនា** រៀនថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុនសែនស្ពាន ដែលបានចូលរួម «វេទិកាថ្នាក់រៀន ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» រៀបរាប់ថា៖«ខ្ញុំបានចូលរួមវេទិកាថ្នាក់រៀនដោយបានទទួលចំណេះដឹងប្រវត្តិសាស្ត្រថ្មី ទាក់ទងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម, ការផ្ទុះសង្គ្រាមរវាងកងទ័ពលន់ នល់ និងខ្មែរក្រហម, ការបង្កើតសហករណ៍, ការធ្វើការងារគ្មានពេលសម្រាក និងមិនមានអាហារហូបគ្រប់គ្រាន់។ ចំណេះដឹងដែលខ្ញុំទទួលបានថ្មីបន្ថែមទៀតនោះគឺ ការចូលរួមការពារ និងទប់ស្កាត់កុំឲ្យអំពើហិង្សា និងអំពើប្រល័យពូជសាសន៍កើតឡើងនាពេលអនាគត។ ខ្ញុំនឹងបន្តនិយាយអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះជាមួយមិត្តភក្តិនៅសាលា និងសមាជិកគ្រួសារនៅផ្ទះ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំណូមពរដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តអនុវត្តកម្មវិធីអប់រំ វេទិកាថ្នាក់រៀននេះ ជាបន្តបន្ទាប់ទៀតដើម្បីឲ្យសិស្សានុសិស្សផ្សេងទៀតអាចមានឱកាសរៀនបន្ថែមអំពីប្រវត្តិសាស្ត្រ និងរៀបចំបន្ថែមពេលវេលាដើម្បីអនុញ្ញាតឲ្យសិស្សចូលរួមធ្វើការងារជាក្រុមនិងធ្វើបទបង្ហាញរបស់ខ្លួន»។

សិស្សឈ្មោះ **អុល ស៊ីវឡាង** រៀនថ្នាក់ទី១២នៃវិទ្យាល័យ ហេង សំរិនបុស្សឫស្សីស្រុក ដែលបានចូលរួមវេទិកាថ្នាក់រៀននាពេលថ្មីៗនេះ បានបង្ហាញចំណាប់អារម្មណ៍ថា៖«វេទិកាថ្នាក់រៀននេះបានផ្តល់ចំណេះដឹង និងបទពិសោធន៍ដែលខ្ញុំមិនដែលដឹង និងទទួលបានពីមុនមក។ ក្នុងវេទិកាថ្នាក់រៀននេះ ខ្ញុំទទួលបានការយល់ដឹងដូចជា៖ ការជម្លៀសប្រជាជនដោយបង្ខំ, ការលុបបំបាត់ទីផ្សារ, ការបំបាត់ព្រះពុទ្ធសាសនា, ការប្រមូលផ្តុំប្រជាជនធ្វើការងារនៅតាមការដ្ឋាន និងការប៉ះទង្គិចរវាងខ្មែរក្រហម និងវៀតណាម។ ខ្ញុំក៏បានយកចំណេះដឹងដែលខ្ញុំដឹងទាំងនោះប្រាប់មិត្តភក្តិ និងបានសួរលោកគ្រូ និងយាយតារបស់ខ្ញុំបន្ថែមទៀត»។

បន្ទាប់មកក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តចុះទៅជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅស្រុកកំពង់សៀម និងស្រុកកោះសូទិន សរុបចំនួន៨នាក់ ក្នុងនោះមានស្រី៤នាក់ និងប្រុស៤នាក់ រួមមាន អ៊ុំ ម៉ម ស្បឿន, ពូ តុងសុភា, យាយ ប៊ុន សេង ហាន, អ៊ុំ មួង សាំងលី, អ៊ុំ ទេព សាវី, អ៊ុំ អៀង សារឿន, អ៊ុំ ម៉ាត់ ត្រីកាស់, អ៊ុំ ម៉ាត់ ទីវើ ដែលបានចូលរួមវេទិកាអប់រំសហគមន៍ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នាពេលកន្លងមក។ ការចុះជួបផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនេះ គឺដើម្បីអនុញ្ញាតដល់អ្នកចូលរួមផ្តល់ការវាយតម្លៃទៅលើវេទិកាអប់រំសហគមន៍ដែលខ្លួនធ្លាប់បានចូលរួមកន្លងមក។




*អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានចូលរួមការត្រួតពិនិត្យ និងវាយតម្លៃទៅលើវេទិកាថ្នាក់រៀន និងវេទិកាអប់រំសហគមន៍ ស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ នៅកម្ពុជា។*
*(សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# សិស្សវិទ្យាល័យ សុខអាន ១ ឧសភា និង វិទ្យាល័យ សុខ អាន ដូងខ្ពស់ បូរីជលសារ

## ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការជម្លៀសប្រជាជនដោយបង្ខំ» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ

ផាន់ ទីន



នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការជម្លៀសប្រជាជនដោយបង្ខំ» ដល់សិស្សានុសិស្ស ចំនួន៤៥នាក់ ក្នុងនោះមានសិស្សស្រី២៩ នាក់ មកពីវិទ្យាល័យ សុខអាន ១ឧសភា និងវិទ្យាល័យ សុខ អាន ដូងខ្ពស់ បូរីជលសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការជម្លៀសប្រជាជនដោយបង្ខំ» ដល់សិស្សានុសិស្ស ចំនួន៤៥នាក់ ក្នុងនោះមានសិស្សស្រី២៩ នាក់ មកពីវិទ្យាល័យ សុខអាន ១ឧសភា និងវិទ្យាល័យ សុខ អាន ដូងខ្ពស់ បូរីជលសារ។ គោលបំណងរបស់វេទិកានេះ គឺដើម្បីបង្កើនចំណេះដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជា-ធិបតេយ្យទៅដល់យុវជនជំនាន់ក្រោយ និងលើកទឹកចិត្តសិស្សានុសិស្សឲ្យឈ្វេងយល់ពីរបៀបទប់ស្កាត់អំពើហិង្សា និងការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហមៗ មុននឹងចាប់ផ្តើមវេទិកាថ្នាក់រៀនសិស្សទាំង

អស់បានបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹង (មុនវេទិកា) ជាមុនៗ

ជាកិច្ចចាប់ផ្តើមវេទិកា គ្រូខុទ្ទេស ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តកែប ជំរុញសិស្សានុសិស្សឲ្យសរសេរសំណួរលើសៀវភៅកត់ត្រារបស់ខ្លួន ទាក់ទងនឹងចម្ងល់ដែលខ្លួនចង់ដឹងពីរបបខ្មែរក្រហម។ ពេលទន្ទឹមនឹងគ្នានោះដែរ គ្រូខុទ្ទេសបានពន្យល់នូវពាក្យគន្លឹះមួយចំនួន ដូចជា ៖ ភូមិភាគបូព៌ា (២០៣), ភូមិភាគនិរតី(៤០៥), ភូមិភាគពាយ័ព្យ (៥៦០), ភូមិភាគឧត្តរ (៣០៣), ភូមិភាគបស្ចិម (៤០១), ភូមិភាគឦសាន (១០៨), សហករណ៍, ការដ្ឋានការងារ និងតំបន់រំដោះមុននឹងចូលដល់មេរៀន។ បន្ទាប់មកគ្រូខុទ្ទេសបង្រៀនអំពីការជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហមក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។ បន្ថែមលើនេះ គ្រូខុទ្ទេសបង្ហាញអំពីវិធីសាស្ត្រសំខាន់ៗមួយចំនួនក្នុងការទប់ស្កាត់អំពើហិង្សា ឬអំពើប្រល័យពូជសាសន៍។

ខណៈនោះ គ្រូខុទ្ទេស ផេង ពង្សរ៉ាស៊ី ក៏បានចាក់បញ្ចាំងវីដេអូឯកសារខ្លីដែលបង្ហាញពី «ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ»។ បន្ទាប់មក គ្រូខុទ្ទេសបានឆ្លើយតបទៅនឹងសំណួររបស់សិស្សដូចខាងក្រោម ៖

១) តើការជម្លៀសប្រជាជនដោយបង្ខំផ្តល់ផលវិបាកអ្វីខ្លះ?

២) តើប្រជាជនទាំងអស់ពេញចិត្តនឹងការជម្លៀសនេះដែរឬទេ?

៣) តើការជម្លៀសប្រជាជនដោយបង្ខំបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនដែរឬទេ?

៤) តើការជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហមដើម្បីអ្វី?

៥) តើប្រជាជនបែកបាក់គ្រួសារដែរឬទេ?

៦) តើមូលហេតុអ្វីបានជាខ្មែរក្រហមបង្កើតរបបប្រល័យពូជសាសន៍បែបនេះឡើង?

៧) តើរបបខ្មែរក្រហមបែងចែកប្រជាជនជាប៉ុន្មានវណ្ណៈ?

៨) តើហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជនពីទីក្រុងទៅជនបទ?

៩) តើហេតុអ្វីបានជាខ្មែរក្រហមចង់បណ្តេញជនជាតិវៀតណាម ឬកងទ័ពវៀតកុងចេញពីប្រទេសកម្ពុជា?

១០) តើមេដឹកនាំខ្មែរក្រហមមាននរណាខ្លះ?

១១) តើរបបខ្មែរក្រហមបានផ្តល់ផលអាក្រក់អ្វីខ្លះ?

១២) តើហេតុអ្វីបានជារបបខ្មែរក្រហមសម្លាប់មនុស្ស?

១៣) តើក្នុងអំឡុងរបបខ្មែរក្រហមមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះ?

១៤) តើមានមូលហេតុអ្វីដែលបណ្តាលឲ្យមានការប្រើប្រាស់អំពើហិង្សាលើប្រជាជនក្នុងរបបខ្មែរក្រហម?

១៥) តើរបបខ្មែរក្រហមមានគោលបំណងអ្វី?

១៦) តើហេតុអ្វីបានជាប្រជាជននិយាយថារបបខ្មែរក្រហមប្រព្រឹត្តអំពើប្រល័យពូជសាសន៍?

១៧) តើហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

១៨) តើការជម្លៀសដោយបង្ខំកើតឡើងយ៉ាងដូចម្តេច?

១៩) តើមេដឹកនាំខ្មែរក្រហមដឹកនាំប្រជាជនដោយរបៀបណា?

២០) តើការជម្លៀសប្រជាជនមានប៉ុន្មានដំណាក់កាល?

២១) តើហេតុអ្វីបានជាមានការបង្ខិតបង្ខំប្រជាជនឲ្យធ្វើការងារលើសម៉ោង?

២២) តើហេតុអ្វីបានជាកើតមានរបបខ្មែរក្រហម?

២៣) តើហេតុអ្វីបានជាមានការបែងចែកវណ្ណៈរវាងប្រជាជនថ្មី និងប្រជាជនចាស់?

២៤) តើហេតុអ្វីបានជាខ្មែរក្រហមធ្វើទារុណកម្មលើប្រជាជន?

នៅចុងបញ្ចប់វេទិកាថ្នាក់រៀន សិស្សបង្ហាញចំណាប់អារម្មណ៍ដូចតទៅ ៖

នាងខ្ញុំឈ្មោះ **ថា ស្រីរ័ត្ន** អាយុ១៧ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី១២នៃវិទ្យាល័យ សុខអាន ១ខសភា។

ក្នុងរយៈពេលមួយព្រឹកនេះ ខ្ញុំទទួលបានចំណេះដឹងពីរបបខ្មែរក្រហមកាន់តែច្បាស់ និងយល់ដឹងអំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងឲ្យទៅនៅតាមជនបទៗ ការបង្កើតឲ្យមានវេទិកាថ្នាក់រៀននេះ គឺធ្វើឲ្យខ្ញុំមានការយល់ដឹងកាន់តែច្បាស់ពីប្រវត្តិសាស្ត្រខ្មែរក្រហម និងជួយពង្រីកចំណេះដឹងដល់ខ្ញុំ។ ខ្ញុំបានដឹងពីការប្រើប្រជាជនឲ្យធ្វើការហួសកម្លាំង និងបង្អត់អាហារប្រជាជន។ តាមរយៈការសិក្សារៀនសូត្រអំពីរបបខ្មែរក្រហមកន្លងមក ធ្វើឲ្យខ្ញុំមានការអាណិតអាសូរប្រជាជនដែលនៅរស់រានមានជីវិតសព្វថ្ងៃនេះ។ ដើម្បីចូលរួមចំណែកក្នុងការទប់ស្កាត់របបខ្មែរក្រហមកុំឲ្យកើតឡើងនាពេលអនាគត យើងត្រូវចៀសវាងការប្រើប្រាស់អំពើហិង្សា។

នាងខ្ញុំឈ្មោះ **ឃឿន មិនា** អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២មកពីវិទ្យាល័យ សុខ អាន ១ ខសភា។ បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីវេទិកាថ្នាក់រៀននេះ ខ្ញុំចាប់អារម្មណ៍ទៅលើផ្ទាំងរូបថតដែលឆ្លុះបញ្ចាំងអំពីរបបខ្មែរក្រហម។ ខ្ញុំក៏បានដឹងអំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីភ្នំពេញឲ្យទៅនៅជនបទ និងមានការបែងចែកការគ្រប់គ្រងជា៦ភូមិភាគ។ ខ្មែរក្រហមបានប្រើល្បិចបោកបញ្ឆោត និងបង្ខិតបង្ខំប្រជាជនឲ្យចេញពីផ្ទះដែលកំពុងរស់នៅឲ្យទៅតំបន់ផ្សេងៗ ដូច្នេះដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ យើងត្រូវខិតខំរៀនសូត្រ, ជៀសឲ្យឆ្ងាយពីអំពើហិង្សា, មិនរើសអើងប្រកាន់វណ្ណៈ និងមានស្មារតីចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ។

ខ្ញុំឈ្មោះ **គៀមរក្សា** អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ សុខ អាន ១ ខសភា។ ក្នុងរយៈពេលចូលរួមវេទិកាថ្ងៃនេះ ខ្ញុំទទួលបានចំណេះដឹងថ្មីៗពីប្រវត្តិសាស្ត្រខ្មែរក្រហមដូចជា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំ ដោយខ្មែរក្រហមលើកឡើងថា អាមេរិកនឹងមកទម្លាក់គ្រាប់បែក









នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការជម្លៀសប្រជាជនដោយបង្ខំ» ដល់សិស្សានុសិស្ស ចំនួន៤៥នាក់ ក្នុងនោះមានសិស្សស្រី២៩ នាក់ មកពីវិទ្យាល័យ សុខអាន១ ខសភា និងវិទ្យាល័យ សុខ អាន ដូងខ្ពស់ បូរីជលសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការជម្លៀសប្រជាជនដោយបង្ខំ» ដល់សិស្សានុសិស្ស ចំនួន៤៥នាក់ ក្នុងនោះមានសិស្សស្រី២៩នាក់ មកពីវិទ្យាល័យ សុខអាន ១ ខសភា និងវិទ្យាល័យ សុខ អាន ដូងខ្ពស់ បូរីជលសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដូច្នេះប្រជាជនត្រូវតែជម្លៀសចេញ, មិនមានស្បៀងអាហារគ្រប់គ្រាន់ឲ្យប្រជាជននៅភ្នំពេញ និងដើម្បីបំបែកក្រុមចារកម្ម។ ខ្ញុំក៏ធ្លាប់ឮតា និងយាយ និយាយប្រាប់ខ្ញុំថា «កូនរបស់ប្រជាជនគឺជាកូនរបស់អង្គការ គឺមានតែអង្គការប៉ុណ្ណោះដែលមានសិទ្ធិក្នុងការសម្រេចចិត្ត ហើយអង្គការប្រើឲ្យធ្វើអ្វីត្រូវតែធ្វើតាម ដូចជា ប្រើឲ្យកូនរបស់ខ្លួនមកស៊ើបការណ៍ពីឪពុកម្តាយខ្លួន រួចហើយរាយការណ៍ប្រាប់អង្គការវិញ»។ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យកើតឡើងនៅថ្ងៃអនាគត យើងត្រូវខិតខំប្រឹងប្រែងរៀនសូត្រឲ្យមានចំណេះដឹង។

ខ្ញុំឈ្មោះ **ពុំ ត្នូ** អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ សុខអាន ដូងខ្ពស់ បូរីជលសារ។ ខ្ញុំបានរៀនពីរបបប្រល័យពូជសាសន៍ដែលខ្មែរសម្លាប់ខ្មែរគ្នាឯងគ្រាន់តែប្រព្រឹត្តកំហុសបន្តិចបន្តួច និងដឹងពីទីកន្លែងដែលខ្មែរក្រហមយកមនុស្សទៅសម្លាប់។ ខ្ញុំពិតជាសោកស្តាយជាខ្លាំងពេលឃើញខ្មែរក្រហមប្រព្រឹត្តដូច្នេះ។ ដើម្បីកុំឲ្យរបបប្រល័យពូជសាសន៍កើតឡើងម្តងទៀត យើងត្រូវលុបបំបាត់អំពើហិង្សា មិនត្រូវរើសអើងពូជសាសន៍, ពណ៌សម្បុរ និងសាសនា។ ការបង្កើតឲ្យមានវេទិកាថ្នាក់រៀននេះឡើងពិតជាមានសារសំខាន់ណាស់ ព្រោះធ្វើឲ្យសិស្សដឹងអំពីប្រវត្តិសាស្រ្តខ្មែរក្រហម និងបានស្គាល់មេដឹកនាំខ្មែរក្រហម ដូចជា សាឡុត ស, នួន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ និង ឌុច ជាដើម។ ចុងក្រោយ ខ្ញុំសូមផ្តាំទៅកាន់យុវជនឲ្យសិក្សាពីរបបខ្មែរក្រហម។

ខ្ញុំឈ្មោះ **ហៀងតារា** អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ សុខ អាន ដូងខ្ពស់បុរីជលសារ។ ខ្ញុំទទួលបានចំណេះដឹងអំពីប្រវត្តិសាស្រ្តខ្មែរក្រហម និងដឹងពីទុក្ខលំបាករបស់ប្រជាជន។ រឿងរ៉ាវដែលខ្ញុំបានចាំជាងគេ គឺលោកគ្រូបានធ្វើបទបង្ហាញអំពីការជម្លៀសប្រជាជននៅក្នុងរបបខ្មែរក្រហម។ ខ្ញុំគិតថាការបង្កើតឲ្យមានវេទិកាថ្នាក់រៀននេះ គឺល្អណាស់សម្រាប់ខ្ញុំ និងយុវជនជំនាន់ក្រោយ។ ខ្ញុំអាណិតអាសូរដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទទួលបានចំណេះដឹងអំពីរបបខ្មែរក្រហមកាន់តែច្បាស់។

នៅពេលរសៀល សិស្សានុសិស្សក៏បានទៅធ្វើទស្សនកិច្ចសិក្សានៅមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់ (អតីតគុកក្រាំងតាចាន់) និងជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដោយផ្ទាល់។

# សិស្សវិទ្យាល័យ តាលោ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មដ៏ឃោរឃៅ» រៀបចំដោយមជ្ឈមណ្ឌលផ្សះផ្សាវាលវែង

**ធី គីមហុង និង មឿន ស្រីណុច**



នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) និង ការទប់ស្កាត់ឧក្រិដ្ឋកម្មដ៏ឃោរឃៅ» ដល់សិស្សានុសិស្សដែលកំពុងសិក្សានៅថ្នាក់ទី១១ និងទី១២ ចំនួន២០នាក់ ក្នុងនោះមានស្រី១៤នាក់ មកពីវិទ្យាល័យតាលោ ស្ថិតក្នុងស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់។ (ទាវ សម្ផស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) និង ការទប់ស្កាត់ឧក្រិដ្ឋកម្មដ៏ឃោរឃៅ» ដល់សិស្សថ្នាក់ទី១១ និង ទី១២ ចំនួន២០នាក់ ក្នុងនោះមានសិស្សស្រីចំនួន១៤នាក់ នៃវិទ្យាល័យតាលោ ស្ថិតក្នុងស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់។ វេទិកានេះគឺផ្តោតលើប្រធានបទការឡើងកាន់អំណាចរបស់ខ្មែរក្រហម និងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង។

ជាការស្វាគមន៍លោក ធី គីមហុង និង ក្រុមការងារបានដឹកនាំសិស្សទស្សនាការិយាល័យរបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងរៀបរាប់ប្រាប់សិស្សអំពីប្រវត្តិនៃការបង្កើតមជ្ឈមណ្ឌលផ្សះផ្សាវាលវែង នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ជាមួយគោលបំណងចំនួន៤ ដូចខាងក្រោម ៖

១) ដើម្បីបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់

ប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។

២) ដើម្បីពង្រឹងដល់ដំណើរការសន្តិភាព និងការទប់ស្កាត់ជម្លោះនានាតាមរយៈកម្មវិធីអប់រំ ដល់សិស្សានុសិស្សជំនាន់ក្រោយដែលភាគច្រើនរស់នៅតាមទីជនបទបានមកចូលរួមរៀនសូត្រ។

៣) លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងការចែករំលែកអំពីរឿងរ៉ាវ និងបទពិសោធន៍ផ្ទាល់ខ្លួនដល់សិស្សានុសិស្សជំនាន់ក្រោយ។

៤) ប្រមែប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ទីតាំងបទឧក្រិដ្ឋដែលបានបន្សល់ទុកពីរបបខ្មែរក្រហម។ បទឧក្រិដ្ឋដែលបានបន្សល់ពីរបបខ្មែរក្រហម។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលជម្រះជម្រាវាលវែងបានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) ដោយលើកយកវិធីសាស្ត្រ K-W-L (ដឹង, ចង់ដឹង, បានដឹង) មកបង្រៀនសិស្ស និងចាប់ផ្តើមដោយសួរសំណួរទៅសិស្សានុសិស្សទាំងអស់ថា តើប្អូនៗបានដឹងអ្វីខ្លះអំពីរបបខ្មែរក្រហម? តើប្អូនៗចង់ដឹងអ្វីខ្លះអំពីរបបខ្មែរក្រហម?

តមក លោក ឡុង ដានី បានធ្វើបទបង្ហាញអំពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម៖ ការជម្លៀសប្រជាជនចេញពីទីក្រុងដោយបង្ខំ និង ការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំមានបីដំណាក់កាល ដូចខាងក្រោម៖

១) នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ បានរយៈពេល២ទៅ៣ម៉ោង មេដឹកនាំខ្មែរក្រហមបានបញ្ជាឲ្យកងទ័ពខ្មែរក្រហមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានា ទៅធ្វើការងារពលកម្មដ៏លំបាកវេទនានៅតាមវាលស្រែនៃតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។ កងទ័ពខ្មែរក្រហមបានយកលេសក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ ដូច្នេះប្រជាជនត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញតែរយៈពេល៣ថ្ងៃនឹងបានវិលត្រឡប់មកផ្ទះវិញ។ ប្រជាជនទាំងអស់មិនចាំបាច់យកទ្រព្យសម្បត្តិច្រើនទៅតាមខ្លួន និងចាក់សោផ្ទះទេ។ ប៉ុន្តែការពិតខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនត្រឡប់មកផ្ទះវិញពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនជម្លៀសច្រើនលើសលប់បានស្លាប់ដោយសារការសម្លាប់ ធ្វើការងារហួសកម្លាំង និងអត់អាហារ។

២) ចាប់តាំងពីចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានការផ្លាស់ទីប្រជាជនជាពិសេសប្រជាជនថ្មីដោយបង្ខំនៅតាមទីជនបទមួយទៅតាមទីជនបទមួយទៀតម្តងហើយម្តងទៀត នៅក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា (រួមបញ្ចូលទាំងការផ្លាស់ទីតាមរយៈរថភ្លើងពីភូមិភាគនិរតី និងភូមិភាគបស្ចិមទៅកាន់ភូមិភាគពាយ័ព្យ)។ ការផ្លាស់ទីប្រជាជននេះពុំមានជូនដំណឹងជាមុន បានបង្កជាទុក្ខវេទនា និងភាពលំបាកលំបិនដល់ប្រជាជន និងសហគមន៍ជាខ្លាំង។

៣) ចាប់តាំងពីរបបខ្មែរក្រហមធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមលែងទុកចិត្តលើកម្មាភិបាល យុទ្ធជន និងប្រជាជននៅភូមិភាគបូព៌ា។ ប្រជាជនភូមិភាគបូព៌ាត្រូវបានខ្មែរក្រហមចោទប្រកាន់ថាជាមនុស្សដែលមានក្បាលយួនខ្លួនខ្មែរ។ ប្រជាជនភូមិភាគបូព៌ាទាំងអស់គឺជាគោលដៅនៃការជម្លៀសដោយបង្ខំចេញពីភូមិភាគបូព៌ា ទៅភូមិភាគពាយ័ព្យ ភូមិភាគកណ្តាល និងភូមិភាគឧត្តរ។ ការជម្លៀសដោយបង្ខំនេះ បានបណ្តាលឲ្យប្រជាជនភូមិភាគបូព៌ាជាច្រើនបានស្លាប់ដោយសារខ្មែរក្រហមសម្លាប់ អត់អាហារ និងជំងឺគ្មានថ្នាំព្យាបាល។ នៅក្នុងឱកាសនោះ លោក ឡុង ដានី បានបង្ហាញសិស្សអំពីទីតាំងទួលពោធិ៍ជ្រៃ គឺជាទីវាលធំមួយស្ថិតនៅក្បែរបឹង



*នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) និង ការទប់ស្កាត់ឧក្រិដ្ឋកម្មដ៏ឃោរឃៅ» ដល់សិស្សានុសិស្សដែលកំពុងសិក្សានៅថ្នាក់ទី១១ និង ទី១២ ចំនួន ២០នាក់ ក្នុងនោះមានស្រី១៤នាក់ មកពីវិទ្យាល័យតាលោ ស្ថិតក្នុងស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់។ (ទាវ សម្ផស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ទន្លេសាប និងជាប់ តំបន់ព្រៃនាម ក្នុងភូមិសាស្ត្រ ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។ ទីតាំងទួលពោធិ៍ជ្រៃនេះត្រូវបានគេស្គាល់ថា ជាកន្លែងដែលខ្មែរក្រហមសម្លាប់ទាហាន លន់ នល់ និង ជនស៊ីវិលរាប់ពាន់នាក់ក្នុងអំឡុងនៃការជម្លៀសដោយបង្ខំជាទ្រង់ទ្រាយធំលើកដំបូងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។*

*ចុងបញ្ចប់នៃវេទិកាលោក ឡុង ដានី បានធ្វើបទបង្ហាញជាសង្ខេបអំពីដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំណុំរឿង 001 និងសំណុំរឿង ០០២ (សំណុំរឿង០០២ វគ្គទី១ និងសំណុំ០០២ វគ្គទី២)។ និយមន័យអំពើប្រល័យពូជសាសន៍ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់កុំឲ្យមានអំពើប្រល័យពូជសាសន៍។*

*បន្ទាប់មក សិស្សដែលចូលរួមក្នុងវេទិកាថ្នាក់រៀននេះបង្ហាញចំណាប់អារម្មណ៍ ដូចខាងក្រោម៖*

*ខ្ញុំឈ្មោះ* **ឆាម ច័ន្ទម៉េង** *ភេទស្រី គឺជាសិស្សរៀនថ្នាក់ទី១២ នៃវិទ្យាល័យតាលោ។ ក្រោយពីបានចូលរួមវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រខ្មែរក្រហម(១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មដ៏ឃោរឃៅ» ក្នុងថ្ងៃនេះរួចមក ខ្ញុំពិតជារំភើប និងសប្បាយរីករាយយ៉ាងខ្លាំង ព្រោះវេទិកាថ្នាក់រៀនបានផ្តល់ចំណេះដឹងយ៉ាងទូលំទូលាយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជាពិសេសការជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅធ្វើការតាមតំបន់ដាច់ស្រយាល គ្មានសិទ្ធិសេរីភាពក្នុងការនិយាយស្តី ប្រជាជនទាំងអស់រស់នៅទាំងភាពភ័យខ្លាចគ្រប់ពេលវេលា និងមិនមានអាហារហូបចុកគ្រប់គ្រាន់។*

*ខ្ញុំឈ្មោះ* **ម៉ាក់ ពិសី** *ភេទស្រី គឺជាសិស្សរៀនថ្នាក់ទី១១ នៃវិទ្យាល័យតាលោ ខ្ញុំពិតជាមានសេចក្តីអំណរអរគុណ និងរំភើបជាខ្លាំងដែលបានក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងអញ្ជើញរូបនាងខ្ញុំ ព្រមទាំងសិស្សានុសិស្សមកពីវិទ្យាល័យតាលោ មកទទួលនូវបទពិសោធន៍និងចំណេះដឹងថ្មីៗជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងយល់ដឹងអំពីអត្ថន័យនៃអំពើប្រល័យពូជសាសន៍ ដើម្បីជាការទប់ស្កាត់របបខ្មែរក្រហម នាពេលអនាគត។*

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមទឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨÷០០ ដល់ម៉ោង ១២÷០០ និងពេលរសៀលពីម៉ោង ២÷០០ ដល់ ម៉ោង ៥÷០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!


























# ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)

**ហង្ស ឆាំឆាន**

## ២.៩. ក្រុមចល័តលើកប្រព័ន្ធភ្លឺស្រែ

បន្ទាប់ពីការប្រមូលផលស្រូវមិនទាន់ទាំងចប់ស្រួលបួលផង ផែនការចល័តលើកប្រព័ន្ធភ្លឺស្រែបានមកដល់។ ការចល័តលើកប្រព័ន្ធភ្លឺស្រែ គឺជាផែនការរយៈពេលវែង ព្រោះត្រូវធ្វើឲ្យហើយទូទាំងស្រុកកោះជ័យ។ ដើម្បីប្រយុទ្ធសមរភូមិក្ដៅគគុកនេះ អ្នកនៅឯភូមិ សង្កាត់ គេចាត់ទុកថាជាក្រុមសមរភូមិក្រោយ មានភារកិច្ចផ្គត់ផ្គង់ក្រុមសមរភូមិមុខជាប្រចាំ មិនអាចឲ្យអង្គភាពណាមួយខ្វះខាតបានទេ បើខ្វះខាតត្រូវទទួលខុសត្រូវចំពោះមុខអង្គការ។ ការចេញដំណើរទៅការដ្ឋានចាប់ពីព្រឹកម៉ោង៦ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ សង្កាត់បឹងដោល ត្រូវបោះជំរំនៅម្តុំអំពិលក្លោងភូមិពានីសង្កាត់ល្វា កន្លះខែក្រោយមកបានប្ដូរទៅម្ដុំបឹងរូង ភូមិដដែល ការដ្ឋាន២នេះភារកិច្ចរបស់ខ្ញុំនៅជាមួយក្រុមចុងភៅដាំស្លមានគ្នា៥នាក់ ចែកជាក្រុមនៅដាំស្ល២នាក់ ឯចំនួន៣នាក់ទៀត ជាអ្នករែកទឹកនិងរកខុសសម្រាប់ផ្គត់ផ្គង់គ្នាចំនួន៣០នាក់ គេដាក់ឈ្មោះឲ្យថាជាអង្គភាព២១ សង្កាត់បឹងដោលផ្នែកយុវជន។

## ២.១០. យុទ្ធសាស្ត្រការងារថ្មី

ក្រោយចូលប្រយុទ្ធសមរភូមិអស់រយៈពេល១ខែ ទទួលបានលទ្ធផលល្អប្រសើរ អង្គភាព២១ ត្រូវបានអង្គការចាត់ទុកថាជាអង្គភាពឈានមុខគេរាប់ទាំងអង្គភាពផ្សេងទៀតចំនួន១០ក្នុងសង្កាត់បឹងដោល។ ដោយសារលទ្ធផលនេះហើយ អង្គការបានលើកទិសដៅកំណត់ការងារឲ្យធ្វើបន្ថែមទៀត គឺពីមុនយើងធ្វើការរួមគ្នា ជួយគ្នាទៅវិញទៅមក អ្នកណាធ្វើមិនបានគ្រប់ផែនការមានគេទៅជួយបង្ហើយ។ បើយើងធ្វើដូច្នេះតទៅទៀត យើងខាតច្រើនណាស់ និងមានបុគ្គលខ្លះជិះជាន់ពលកម្មគេ អាងតែមានគេជួយ ដូច្នេះអង្គការលើកទិសដៅថ្មីម្នាក់ៗត្រូវធ្វើឲ្យហើយនូវភ្លឺស្រែប្រវែងបណ្ដោយ៥ម៉ែត្រ កម្ពស់៦តឹក បាតក្រោម១ម៉ែត្រកន្លះ ខ្នងលើ១ម៉ែត្រ។ ទន្ទឹមគ្នានេះដើម្បីឲ្យកាន់តែល្អ យើងត្រូវរើជំរំទៅទីតាំងថ្មីនៅភូមិកំពង់ថ្កុល ក្នុងសង្កាត់ល្វាដដែល។ បន្ថែមលើនេះ យើងត្រូវបញ្ចូលក្រុមចុងភៅយុវជន និងក្រុមចុងភៅបងប្រុសដោយបន្ថយចំនួននៅតែមួយក្រុម រួចដកយុវជនឲ្យទៅសម្រុកតាមការដ្ឋានភ្លឺស្រែ។ រូបខ្ញុំត្រូវចូលទៅក្នុងក្រុមប្រយុទ្ធ២១នឹងគេដែរ។ នៅការដ្ឋានកំពង់ថ្កុលយើងម្នាក់ៗបានខំប្រឹងយ៉ាងខ្លាំងដើម្បីឲ្យបានលទ្ធផលគ្រប់ជូនអង្គការ។ អ្នកគេពូកែនិងកម្លាំងខ្លាំងម៉ោង១១គេធ្វើហើយក្នុងរយៈពេលមួយព្រឹក ឯពេលល្ងាចគេសម្រាកនៅក្នុងជំរំឬក៏ដើរចេញក្រៅទៅលេងផ្ទះបងប្អូនជិតៗនោះ។ អ្នកខ្លះឆ្លៀតពេលទៅបកល្ពាក់មកធ្វើកន្ទ្រក ឬឡើងកាប់កំពូលត្នោតយកមកធ្វើម្ជូកពាក់។ អ្នកធ្វើមិនហើយពីពេលព្រឹកត្រូវទៅបង្ហើយពេលល្ងាច។

## ២.១១. ការស្លាប់និងរបួសនៅការដ្ឋានសែនត្នោ

កន្លះខែក្រោយមក ក្រុមយើងបានប្ដូរទីតាំងទៅបោះជំរំនៅភូមិសែនត្នោ



ហង្ស ឆាំឆាន ពេលបួសជាព្រះសង្ឃ។

សង្កាត់រំចេក។ សង្កាត់រំចេក គឺជាអតីតសមរភូមិប្រយុទ្ធក្ដៅជាច្រើនលើករវាងកងទ័ព លន់ នល់ ឈ្មោះ សមរភូមិសូរិយា ទី១ របស់លោក ថាច់ ចាន់ ឆ្នាំ១៩៧២ និងសមរភូមិសូរិយា ទី២ របស់លោក អ៊ិត សួង ឆ្នាំ១៩៧៣ ជាមួយទ័ពយៀកកុង។ ដើម្បីឆាប់រួចការងារគ្រប់ផែនការ ក្រុមនីមួយៗបានទៅវាស់ដីរបបត្រូវធ្វើពីល្ងាចឲ្យហើយ ម៉ោង៤ភ្លឺនាំគ្នាទៅធ្វើទុកពេលល្ងាចបានពេលនាំគ្នាទៅរុតត្រីនៅកំពង់សឹង យកមកហូប។ គ្រាន់តែចាប់ផ្ដើមកាប់ដីភ្លាម ស្នូរគ្រាប់សេវេនធីណាយ (៧៩) បានផ្ទុះឡើងជាប់គ្នា២គ្រាប់ធ្វើឲ្យរបួសមនុស្សជាច្រើននាក់ និងម្នាក់ឈ្មោះ ហើយ របួសធ្ងន់ត្រូវចំបំពង់ក គេសែងមកដល់រោងក៏ស្លាប់ទៅ។ អ្នករបួសទាំងប៉ុន្មានត្រូវយកទៅឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យតំបន់២៤បាភ្នំ។

បន្ទាប់មកទីតាំងការដ្ឋានបានប្ដូរទៅភូមិម៉ាំងសាលា ឃុំរាធរចម្ងាយពីសែនភ្លៅប្រមាណជា១០គីឡូម៉ែត្រ។

## ២.១២. ការបោះឆ្នោតជ្រើសរើសតំណាងប្រជាជន

ពេលនេះចូលដល់ចុងខែមីនាហើយ ក្រុមយើងខ្ញុំមានកាតព្វកិច្ចមួយទៀត គឺការបោះឆ្នោតជ្រើសរើសតំណាងប្រជាជន។ យើងបានសម្រាកពីការងារមួយថ្ងៃមុនពេលទៅបោះឆ្នោត។ ពេលបោះឆ្នោតខ្ញុំពិនិត្យឃើញក្នុងការិយាល័យបោះឆ្នោតមានទី១៖ រូបគំរូក្រដាសប្រាក់ថ្មីមួយរៀល ប្រាំរៀល និង ដប់រៀល។ គេប្រកាសប្រាប់ពួកយើងថា ក្រដាសប្រាក់ទាំងនេះអង្គការនឹងផ្សព្វផ្សាយឲ្យចាយតាមទីផ្សារនៅក្រោយខួបជ័យជម្នះ១៧ មេសាខាងមុខ។ ទី២៖ នៅក្នុងសន្លឹកឆ្នោតមានឈ្មោះ បេក្ខជន២នាក់គឺសមមិត្ត ទេព ណន និង សមមិត្ត ស ណូត។ ការងារនៅភូមិម៉ាំងសាលាមិនខុសគ្នាពីការដ្ឋានមុនៗទេ។ មិនយូរប៉ុន្មានក៏ដល់ថ្ងៃខួបជ័យជម្នះ១៧ មេសា។ ក្រុមអង្គភាពចល័តប្រព័ន្ធភ្លឺស្រែទូទាំងស្រុកកោះជ័យ ត្រូវបានសម្រាកចូលរួមក្នុងពិធីនេះបីថ្ងៃជាប់គ្នា មានរបបហូបធម្មតា ដោយមិនបញ្ចេញពលកម្មអ្វីទាំងអស់។ ការចូលរួមក្នុងក្រុមចល័តនេះ ខ្ញុំបានជួបមិត្តចាស់ៗនិងបានស្គាល់មិត្តភក្តិថ្មីនៅតាមសង្កាត់ផ្សេងទៀតជាច្រើន ធ្វើឲ្យរូបខ្ញុំមានទឹកចិត្តជួយការងារសង្គម និងមិនមានការកង្វល់ពីជីវិតដូចពីមុនទៀតឡើយ។

## ២.១៣. ធ្លាក់ខ្លួនឈឺនៅរដូវភ្លៀង

ក្រោយបុណ្យខួប រូបខ្ញុំត្រូវបានអង្គការឲ្យសម្រាកទៅលេងផ្ទះមួយអាទិត្យ។ ៧ថ្ងៃក្រោយខ្ញុំបានទៅដល់ការដ្ឋានថ្មី នៅភូមិស្វាយក្ដៀប សង្កាត់លា។ ម្ដងនេះរបបការងារត្រូវបានបង្កើនពី៥ម៉ែត្រទៅ៦ម៉ែត្រ ដើម្បីបង្កើនល្បឿនឲ្យហើយមុនរដូវវស្សា។ ដោយខែនេះចូលដល់រដូវវស្សាហើយ ភ្លៀងធ្លាក់កក់ខែ៣ទៅ៤មេរួចហើយ។ រោងជម្រកការដ្ឋាន ប្រក់ស្លឹកឲ្យតែការពារកម្ដៅថ្ងៃប៉ុណ្ណោះ មិនអាចធានាបាននឹងការស្រក់ទឹកភ្លៀងបានឡើយ។ ម្ល៉េះហើយពេលភ្លៀងទឹកស្រក់មកលើទទឹកអស់មិនអាចគេងបានទេមួយយប់ទល់ភ្លឺ ពេលខ្លះភ្លៀងជាប់គ្នា២ទៅ៣យប់ក៏មាន។ គួបផ្សំនឹងការហត់ផង ភ្លៀងធ្លាក់ទទឹកដេកមិនបានផង កម្លាំងចល័តក៏ចាប់ផ្ដើមឈឺបន្តបន្ទាប់ រយៈពេល៤ខែកន្លងទៅខ្ញុំមិនដែលឈឺទេតែពេលនេះចាប់ក្ដៅខ្លួនឲ្យមិត្តភក្តិកោសខ្យល់ឲ្យក្រហមដាំពេញខ្លួន ត្រូវបានរថយន្តពេទ្យដឹកទៅព្យាបាលជាង១អាទិត្យនៅពេទ្យតំបន់បាភ្នំ។ នៅក្នុងមន្ទីរ មានកម្មាភិបាលចូលមកសួរសុខទុក្ខពួកយើងស្ទើររាល់ថ្ងៃ ថ្ងៃមួយមិត្តហោ ជាកម្មាភិបាលតំបន់២៤ ក៏មកដែរ។ មិត្ត ហោ គឺជាអតីតកូនសិស្សខ្ញុំបួសជាសាមណេរឆ្នាំ១៩៧០ គាត់មកនេះតំណាងឲ្យសមមិត្ត ប៉ែន សីហា ប្រធានសេនាធិការតំបន់២៤។ ឃើញខ្ញុំមិត្តហោ រត់មកឱបខ្ញុំដោយក្ដីនឹករឭករួចបបួលខ្ញុំទៅលេងកន្លែងគាត់។ ពេលនោះមិត្តហោ បាននាំខ្ញុំទៅឲ្យជួបបង ប៉ែន សីហា ហើយក៏បែកពីខ្ញុំទៅ។ បង ប៉ែន សីហា គាត់មិនជាអ្នកចូលចិត្តនិយាយច្រើនទេ គ្រាន់តែសួរពីសុខទុក្ខខ្ញុំ និងឪពុកម្ដាយខ្ញុំរួចសួរថាបើមូលដ្ឋានគេហៅឲ្យធ្វើការជាមួយគេ ធ្វើឬអត់ឆាន? ខ្ញុំឆ្លើយទាំងគិតថា ចាំមើលសិនបង គាត់ក៏សើចហើយឲ្យខ្ញុំទៅហូបទឹកត្នោតជាមួយមិត្តហោ និងកម្មាភិបាល៤នាក់ទៀតដែលខ្ញុំមិនស្គាល់ មានម្នាក់នោះគេប្រាប់ខ្ញុំថា សមមិត្ត កែវ មុន្នី។

## ២.១៤. ការរំសាយពីកងចល័តទៅធ្វើស្រែនៅភូមិវិញ

ក្រោយពីមានសុខភាពល្អដូចដើមវិញ ប្រធានមន្ទីរពេទ្យតំបន់២៤បានចេញលិខិតធ្វើដំណើរឲ្យខ្ញុំត្រឡប់ទៅការដ្ឋានវិញ។ ខ្ញុំចេញដើរមួយព្រឹកបានជួបមិត្តរី គឺជាប្រធានយុវជនសង្កាត់ប្រចាំចល័តប្រព័ន្ធភ្លឺស្រែ។ ឃើញលិខិតខ្ញុំអានហើយ មិត្តរី សួរខ្ញុំដោយសើចញឹមៗថា ចង់ទៅផ្ទះ ឬធ្វើការភ្លឺស្រែតទៅទៀត ឆាន? ខ្ញុំឆ្លើយថាស្រេចលើអង្គការ។ មិត្តរី តបវិញ ទៅភូមិវិញចុះជួយភ្ជួរគេ។ រវាងខ្ញុំនិងមិត្តរី ជាមិត្តរួមថ្នាក់រៀននៅសាលាវត្តបឹងដោលតាំងពីឆ្នាំ១៩៥៧។ ខ្ញុំរង់ចាំទទួលលិខិតដំណើរទៅប្រគល់ឲ្យប្រធានភូមិមួយទៀត បើគ្មានលិខិតទេគ្រោះថ្នាក់ណាស់ ប្រធានភូមិអាចចោទថាខ្ញុំរត់ចោលជួរ និងប្ដឹងទៅសន្តិសុខចាប់ដាក់គុកភ្លាម។

## ២.១៥. ឥរិយាបថកម្មាភិបាលមួយចំនួនប្រែប្រួល

ខ្ញុំសប្បាយចិត្តណាស់ពេលត្រឡប់ជួបជុំអ្នកមានគុណ និងប្អូនៗវិញតែពេលចុះធ្វើស្រែពេលទៅរុតត្រី ខ្ញុំមានការងឿងឆ្ងល់លើអត្តចរិតរបស់កម្មា-ភិបាលមួយចំនួន និយាយពាក្យប្លែកៗមករកខ្ញុំដូចជាពាក្យថា (ឆាន អើយកុំទៅខ្វល់អីថ្ងៃហ្នឹងនិងស្អែកវាខុសគ្នាណាបើបានធ្វើធំថ្ងៃក្រោយមើលខ្ញុំផងណា) ខ្ញុំចេះតែគិតម្នាក់ឯង និងស្រមៃទៅអតីត-កាលឆ្នាំ១៩៦៤ ឆ្នាំ១៩៦៦ និងឆ្នាំ១៩៧០ ខ្ញុំបានចូលរួម បានដឹងរឿងពួកខ្មែរក្រហមច្រើន និងបានបដិសេធជាច្រើនលើកនូវអ្វីដែលគេចង់បាន ខ្ញុំរួមដៃជាមួយពួកគេ។ ឥឡូវនេះ ខ្ញុំមិនបាននិយាយតបអ្វីទាំងអស់ គ្រាន់តែគិតថា តើពួកនេះចង់ប្រើល្បិចអីទៀតក្រោយពីចងអាឃាតខ្ញុំច្រើនលើកមក។ ស្រាប់តែមានព័ត៌មានជាបន្តបន្ទាប់ពីពួកនេះមកប្រាប់ខ្ញុំថា «គេចាប់ ចាន់ ចក្រី ហើយ» បន្ទាប់មក «តា ឈូក ក៏គេចាប់ដែរហើយ» បន្ទាប់គ្នានោះអ្នកនៅក្បែរផ្ទះខ្ញុំជាច្រើនទៀតមានបង ប៉ែន សីលា តាមី មិត្តយន។ គេចាប់អស់ហើយ។ ខ្ញុំ

មិនបានចាប់អារម្មណ៍ទេ នៅតែធ្វើការធម្មតានឹងគេទៅ។

## ២.១៦. ឪពុកមាសុំខ្ញុំទៅនៅស្រុកពាមជរ

ក្រោយពីពិភាក្សារវាងលោកពូកាន ឡេ ប្តីប្អូនពៅឪពុកខ្ញុំ ជាមួយអ្នកម្តាយ លោកឪពុកខ្ញុំ និងខ្ញុំជាច្រើនលើក ទើបថ្ងៃ១មករា ១៩៧៧ ខ្ញុំដាច់ចិត្តចាកចេញពីគ្រួសារ តាមបំណងលោកទាំងបី និងប្អូនៗម្តងទៀតគឺទៅនៅជាមួយម្តាយមីងឈ្មោះ ហង្ស សោ នៅភូមិខត្តម សង្កាត់ព្រែកក្របៅ ស្រុកពាមជរ ខេត្តព្រៃវែង ព្រោះលោកពូជាប់រវល់ការងារជាប្រធានសង្កាត់ព្រែកក្របៅ និង កូនប្រុសស្រី គាត់៥នាក់ទៅធ្វើបដិវត្តន៍អស់ហើយ ពុំមានកម្លាំងមនុស្សធំនៅជួយមើលមីង បើបានខ្ញុំនៅជាមួយ ហាក់ដូចជាកក់ក្តៅម្យ៉ាងដែរ។ លោកឪពុកធំឈ្មោះ ហង្ស ដូ ជាអ្នកជូនទៅដល់ទន្លេដីក្រហមត្រូវឆ្លងទូក អ្នកដំណើរជាច្រើននាក់បានឆ្លងកាត់ទន្លេ ក្នុងនោះមានកម្មាភិបាលពាណិជ្ជកម្មតំបន់ម្នាក់ឈ្មោះ គង់ ប៉ាល់ ជាអតីតលោកសង្ឃនៅវត្តជាមួយខ្ញុំក្នុងឆ្នាំ១៩៦២។ ឃើញខ្ញុំ មិត្តប៉ាល់ស្ទុះមកចាប់ដៃខ្ញុំសម្តែងការនឹករឭករឿងអតីតកាលលេងបានបន្តិច ដល់ត្រើយម្ខាងក៏លាគ្នាទៅ។ ទៅដល់ផ្ទះម្តាយមីង អារម្មណ៍ខ្ញុំអរទៅ ប្រាប់ឲ្យទៅចូលរួមភ្ជួរដីចម្ការជាមួយប្រជាជនជាច្រើនទៀត។

## ២.១៧. ការភ្ជួររាស់ក្នុងអតីតសមរភូមិគ្រាប់មីន

ថ្ងៃចុះភ្ជួរ ខ្ញុំបានជួបមនុស្សថ្មីជាច្រើននាក់ ដែលខ្ញុំមិនធ្លាប់ស្គាល់តែភាគច្រើនអ្នកទាំងនោះជាប្រជាជនថ្មី មានថ្មី១៧មេសា និងថ្មីមកពីមូលដ្ឋានផ្សេងដូចជា មកពីស្រុកពាមរក៍ ស្រុកបាភ្នំ ស្រុកកោះជ័យ។ ការភ្ជួរទើបតែចាប់ផ្តើមថ្ងៃដំបូងក្នុងចម្ការដើមមន ដែលគេបោះបង់ក្នុងសម័យសង្គ្រាមតាំងពីឆ្នាំ១៩៧០មក។ ពេលភ្ជួរ មិត្ត អ៊ុន គឺជាប្រធានក្រុមបានប្រាប់ពួកយើងខ្ញុំថា ពេលភ្ជួរកុំគិតតែពីភ្ជួរមិត្តយើង គឺភ្នែកទាំងអស់គ្នាត្រូវសម្លឹងមើលដើមមនណាគួរភ្ជួរបំបុកផ្តាច់ក៏បុកផ្តាច់ទៅ បើអាដើមកដុំ កុំបុកវាអាចបាក់នង្គ័លត្រូវមានទោស និងអ្វីដែលប្រយ័ត្នជាងគេគឺការពារអាយុជីវិតខ្លួនឯង បើមើលឃើញគ្រាប់ត្រូវប្រាប់គ្នាឲ្យជៀសកាលណាប្រហែសអាចផ្ទុះស្លាប់ទាំងអស់គ្នា។ យើងខ្ញុំក៏ចុះភ្ជួរដោយប្រុងប្រយ័ត្នបំផុត គ្រាន់តែមួយគន្លងលើកដំបូងប្រវែង៣០០ម យើងទាំងអស់គ្នាបានឃើញគ្រាប់ច្រើនប្រភេទជាងម្ភៃ មានគ្រាប់ផ្លោងកាំភ្លើងធំ១៥៥ មីលីម៉ែត្រ ១០៥មីលីម៉ែត្រ ៧៥មីលីម៉ែត្រ ៦០មីលីម៉ែត្រ សេវេនធីណាយ។ ពួកយើងបានប្រមូលទុកមួយដុំនូវគ្រាប់ណាដែលអាចកាន់បានទុកដុតនៅពេលល្ងាចក្រោយពេលយើងឡើងដល់ភូមិ។ ថ្ងៃដំបូងការភ្ជួររបស់ក្រុមយើង ពុំបានច្រើនប៉ុន្មានទេ ព្រោះម្នាក់ៗភ្នែកនៅរំពៃមើលតែគ្រាប់ និងស្រែកប្រាប់គ្នាឲ្យជួយយកអ្នកណាគេដឹងពីរបៀបកាន់គ្រាប់មិនឲ្យផ្ទុះ គេចូលទៅយកភ្លាមជាពិសេសអ្នកដែលធ្លាប់ឆ្លងកាត់សមរភូមិ។ អ្នកដែលមិនធ្លាប់ដូចខ្ញុំកាលបើឃើញគេរត់ទៅយកគ្រាប់ ខ្ញុំគេចចេញឲ្យឆ្ងាយពីគេទាល់តែគេយកទៅទុកដាក់ស្រួលបួលហើយទើបមកចាប់នង្គ័លភ្ជួរបន្ត។ រាល់ម៉ោង៦ល្ងាចស្នូរគ្រាប់បានផ្ទុះឡើងផ្ទួនៗគ្នា អ្នកដុតត្រូវរាប់គ្រាប់ផ្ទុះហើយត្រូវប្រាកដថាវាផ្ទុះអស់ឬនៅ។ បើនៅ ព្រឹកឡើងទៅមើលយកទៅដុតទៀត។ រយៈពេលជាង២ខែយើងខ្ញុំបានចូលប្រឡូកក្នុងសមរភូមិនេះ ដោយពុំមានអ្នកណាមួយគ្រោះថ្នាក់ទេ។ នៅការដ្ឋានភូមិផ្សេងទៀតដែលស្ថិតនៅក្បែរក៏មានករណីដូចគ្នាដែរ។ ប្លែកតែនៅតាមផ្ទះប្រជាជនកាប់ដីដាំដំណាំនៅពេលចប់ការងារសមូហភាព គាត់ដាំចេក បុដំឡូងសម្រាប់គ្រួសារប៉ះចំលើគ្រាប់សេវេនធីណាយ ផ្ទុះស្លាប់ និងរបួសជាបន្តបន្ទាប់។ ជាធម្មតាលោកពូចប់ពីការងារពេលល្ងាច គាត់មកសម្រាកនៅផ្ទះតែងតែមកជជែកលេងជាមួយខ្ញុំពីនេះពីនោះស្ទើរជារៀងរាល់ថ្ងៃ។ បងប្អូនឪពុកម្តាយខ្ញុំមានបងប្អូន៥នាក់ ប្រុស៣នាក់និង ស្រី២នាក់។ បងគេស្រីមានកូនម្នាក់ប្រុសម្នាក់បួសរៀន និងស្នាក់នៅជាមួយនឹងខ្ញុំដែរ។ ចប់បរិញ្ញាបត្រឆ្នាំ១៩៧២ ចូលធ្វើទាហានលន់ នល់ គេយកទៅសម្លាប់បាត់ទៅ។ លោកអ៊ុំ លោកពូ អ្នកមីងទាំងអស់គ្នាស្រឡាញ់ និងគោរពយើងទាំងពីរនាក់ណាស់ ដោយកំណត់ថា យើងខ្ញុំទាំងពីរនាក់ជាមនុស្សបង្គោលអនាគតក្នុងគ្រួសារ។ ល្ងាចខ្លះ លោកពូហៅខ្ញុំឲ្យទៅស្គាល់កម្មាភិបាលផ្សេងទៀតដែលជាកូនចៅរបស់គាត់នៅមន្ទីរសង្កាត់ និងនិយាយជជែកគ្នាពីនេះពីនោះរហូតដល់ម៉ោង១០ ទើបឲ្យមកផ្ទះវិញ។ ភាពស្និទ្ធស្នាលរវាងលោកពូ និងខ្ញុំពេលនោះ ខុសគ្នាពីមុនឆ្នាំ១៩៧០ ធ្វើឲ្យខ្ញុំមានភាពកក់ក្តៅច្រើន។

## ២.១៨. អ្នកមីងនិងលោកឪពុកមាបបួលរកប្រពន្ធ

ល្ងាចមួយអ្នកមីង និងប្អូនស្រីជីដូនមួយខ្ញុំ បានអង្គុយជជែកគ្នាលេងជាមួយខ្ញុំ រួចអ្នកមីងបន្តសួរមុនថា លោកក្មួយ មិនគិតគូររកប្រពន្ធកូននឹងគេទេអី? ខ្ញុំឆ្លើយថា មិនទេមីង។ ប្អូនស្រីខ្ញុំចាប់ផ្តើមនិយាយ លោកបងនៅដល់ណាទៀត? ឆ្នាំនេះ២៩ឆ្នាំហើយបែបចាំដល់៦០បានដល់គូឬ? ខ្ញុំឃើញកូនគេម្នាក់នៅក្បែរផ្ទះយើងស្អាតគួរសមដែរ ស័ក្តិសមនឹងលោកបង។ នាងទៅដាំបាយឲ្យក្រុមបងហូបរាល់ថ្ងៃ នាងឈ្មោះនារី សារ៉ែត ទៅមើលខ្លួនឯងម្តងមើល ខ្ញុំបានប្រាប់និងបានសួរទៅម៉ែគេៗព្រមហើយ លោកបង។ អ្នកមីងក៏បន្ថែមថាពូ និងមីងអាណិត

ក្មួយឯងឮបងប្រាប់ថា ស្ទើរគេបីនាក់ហើយតែអង្គការមិនឲ្យការ អញ្ចឹងកុំចាំគេអី មិនមែនគូយើង រកអ្នកព្រែកក្រជៅទៅ ហើយនៅជាមួយមីងទៅ ក្មួយគ្រាន់បានជាគ្នា។ ខ្ញុំបានឆ្លើយថា ស្រេចលើពូ និងមីង ក្រោយពីបានដឹងដំណឹងដូច្នេះដល់គ្រួសារខាងស្រី ទាំងសាមីខ្លួនទាំងខ្ញុំបានលបលួចមើលគ្នាទៅវិញទៅមកជាបន្តបន្ទាប់នៅក្នុងក្រុមភ្ជួរចម្ការ។ រូបខ្ញុំឃើញគេហើយធ្វើអាកប្បកិរិយាដូចជាមិនដឹង ឯសាមីខ្លួននិងអ្នកដាំបាយជាមួយ និងបងប្អូនគេពេលឃើញខ្ញុំបានរាក់ទាក់សួរនាំប្លែកៗបានន័យថាគេចាប់អារម្មណ៍នឹងខ្ញុំហើយខ្ញុំក៏សម្តែងការគួរសមដាក់វិញដែរ។ ស្រាប់តែល្ងាចមួយលោកពូ បានហៅខ្ញុំទៅកន្លែងគាត់ ហើយឲ្យជិះកង់តាមគាត់ដើរមើលក្នុងភូមិ។ ខ្ញុំមិនបានដឹងពីបំណងរបស់គាត់ទេ ចេះតែជិះតាមគាត់ទៅចូលផ្ទះចំនួន៣ រហូតដល់ម៉ោង៧ ទើបត្រឡប់មកកន្លែងវិញទាំងពីរនាក់។ មួយស្របក់ក្រោយមក ខ្ញុំបានឃើញនារីម្នាក់ចូលមករួចលោកពូប្រាប់នាងឲ្យអង្គុយជិតខ្ញុំរួចប្រាប់ថា នារីជាប្រធានកងចល័តកាប់ព្រៃពូហៅមកដើម្បីពិភាក្សារឿងកាប់ព្រៃចាប់ពីស្អែកទៅ។ ខ្ញុំក៏មិនចាប់អារម្មណ៍ទេ បើឮថា ប្រធានគេទៀតនោះ កាន់តែមិនសូវចូលចិត្តទៀតព្រោះកន្លងមកខ្ញុំបានប្រកែកគ្នាជាមួយប្រធាននារីជាច្រើនលើកដែលហើយព្រោះតែសំដីរបស់នាងមើលស្រាលមកលើអ្នកថ្មីដូចជាពួកខ្ញុំ។ នាងមកអង្គុយក្បែរខ្ញុំដែលមានចង្កៀងប្រេងម៉ាស៊ូតបញ្ឆេះប៉ុនមេដៃដាក់ពីមុខនាង តាមពិតនាងដឹងខ្លួនហើយ មានគេប្រាប់នាងថា លោកពូយកនាងមកឲ្យខ្ញុំមើល នៅតែខ្ញុំទេដែលមិនដឹងអី។ កំពុងតែអង្គុយ នាងបានរុញចង្កៀងចេញឲ្យឆ្ងាយពីមុខនាងមិនឲ្យខ្ញុំឃើញនាងច្បាស់។ ដើម្បីសម្តែងការស្វាគមន៍ទាំងទើសទាល់ ខ្ញុំក៏បានសួរនាងថា នារីផ្ទះនៅឯណា? នាងឆ្លើយរបៀបអៀនថា នៅក្បែរព្រែកអាមួយដោយខ្ញុំមិនស្គាល់ព្រែកនោះក៏សួរបន្តទៀត ព្រែកនោះនៅដល់ណានារី ឆ្ងាយឬជិត? នាងឆ្លើយថា នៅប្រហែល ១០០ម៉ែត្រពីកន្លែងនេះ។ លោកពូទៅណាបាត់បន្តិចក៏ចូលមក ទាញចង្កៀងដាក់ឲ្យកាន់តែជិតមុខនាង។ រួចនិយាយថា ឲ្យគេសុំស្គាល់ផងមើលកុំអៀនអីគង់តែស្គាល់គ្នាទេថ្ងៃក្រោយ។ និយាយហើយលោកពូក៏ចេញទៅបាត់យ៉ាងយូរ ខ្ញុំទន្ទឹងរង់ចាំតែស្តាប់ផែនការរបស់គាត់ឆ្លើយយ៉ាងម៉េច? ចុះហេតុអ្វីក៏ទុកឲ្យខ្ញុំអង្គុយតែពីរនាក់អៀនណាស់ខ្ញុំ ដើម្បីកុំឲ្យស្ងាត់ព្រោះសាមីខ្លួនប្រធានកាប់ព្រៃ គ្មានបានសួរនាំខ្ញុំពីអ្វីសោះ គិតតែអង្គុយ ខាំជាយក្រមា ខ្ញុំក៏បន្តនិយាយទាំងទើសទាល់ពីនេះពីនោះរហូតដល់ម៉ោងប្រហែលជា១០ ទើបឃើញលោកពូចូលមករួចនិយាយថា យប់ជ្រៅហើយនាំគ្នាទៅដេកពួន។ នារីចេញទៅបាត់លោកពូសួរខ្ញុំថា ម៉េចទៅក្មួយពេញចិត្តឬអត់? ខ្ញុំសួរគាត់វិញថា ពូហៅគេមកឲ្យខ្ញុំមើលឬ? គាត់ឆ្លើយថាចេះសួរអញ្ចឹងកើត និយាយគ្នាមួយល្ងាចហើយ ខ្ញុំឆ្លើយថា ខ្ញុំអត់បានមើលផងពូ អញ្ចឹងធ្វើម៉េច? ពូស្អែកឲ្យគេទៅផ្ទះយើងចាំខ្ញុំមើល និងឲ្យមីងជួយមើលផង។ ស្អែកឡើងប្អូនជីដូនមួយជិះគោមកហៅ ឲ្យទៅមើលប្រពន្ធ ខ្ញុំមិនបានស្គាល់ឈ្មោះសាមីខ្លួនទេ ទើបតែដឹងពីប្អូនថា នាងឈ្មោះ នារី សាវ៉ាយ រឿងនេះបានឮដល់គ្រួសារនារី សារ៉ែត ធ្វើឲ្យគេអាក់អន់ចិត្តជាខ្លាំងតែគ្មានមិនហ៊ាននិយាយ។

ពេលទៅដល់ផ្ទះបានជួបគ្នាតាមការណាត់ តែខ្ញុំមិនមានពាក្យអ្វីនិយាយច្រើនជាមួយនាងត្រឹមតែពាក្យថា នារីមកយូរហើយឬ? នាងឆ្លើយថា មកតាំងពីព្រឹកម្ល៉េះ មកលេងផ្ទះមីងនៅជិតនេះផង គាត់គឺជាជាងធ្វើផាលនង្គ័ល។ បានជួបគ្នាហើយ នាងក៏បានលាខ្ញុំទៅ ព្រោះខ្ញុំត្រូវត្រឡប់ទៅភ្ជួរពេលល្ងាចទៀត។ ក្រោយពីនាងចេញទៅបាត់មីងក៏សួរទៅខ្ញុំថា ម៉េចដែរក្មួយ។ ខ្ញុំឆ្លើយថា ខ្ញុំសូមផ្ញើវាសនាលើពូមីងហើយពេលនេះ អរគុណ ពូ មីង ដែលបានជួយជ្រោមជ្រែងខ្ញុំ។

## ២.១៩. ការបង្ហាញខ្លួននៅមុខគ្រួសារខាងស្រី

រំលង២ថ្ងៃក្រោយមកលោកពូបានប្រាប់ឲ្យខ្ញុំទៅបង្ហាញមុខអនាគតឪពុកនិងម្តាយក្មេក ពេលទៅដល់ផ្ទះមានមនុស្សជាច្រើននាក់ ដែលខ្ញុំពុំធ្លាប់ស្គាល់មកមើលខ្ញុំ ដោយពេលនោះជាពេលយប់ផងខ្ញុំមើលស្គាល់ច្បាស់តែលោកឪពុកក្មេកនិងម្តាយក្មេកពួកគាត់ចាស់ៗលោកឪពុកអាយុ៧០ឆ្នាំហើយ។ ឯអ្នកម្តាយអាយុ៦០ឆ្នាំជាង។ ពេលពួកគាត់ឃើញខ្ញុំមកម្នាក់ឯង ហាក់ដូចជាសប្បាយចិត្តណាស់រៀបបាយ ទទួលខ្ញុំហូបជុំគ្នា។ រួចលោកឪពុកក៏សួរពីការរៀនសូត្ររបស់ខ្ញុំ ខ្ញុំប្រាប់គាត់ពីការរៀនសូត្ររបស់ខ្ញុំហើយបញ្ជាក់ប្រាប់ថាខ្ញុំប្រាប់អ៊ំតាមត្រង់ ខ្ញុំមិនដែលនិយាយប្រាប់អ្នកណាដូច្នេះទេព្រោះឪពុកខ្ញុំហាមណាស់ កុំនិយាយអួតពីការរៀនសូត្រឲ្យសោះគ្រោះថ្នាក់ណាស់លោកកូនក្នុងសង្គមនេះ។ លោកឪពុកក្មេកឆ្លើយថាល្អណាស់កុំមាត់កូន បានជាគាត់និយាយដូច្នេះព្រោះនៅក្បែរផ្ទះគាត់មានមិត្តភក្តិខ្ញុំជាច្រើននាក់ចេញពីសាលាបាលីជាន់ខ្ពស់ដូចខ្ញុំក្នុងសង្កាត់នេះ គេស៊ើបដឹងយកទៅសម្លាប់អស់ហើយ។ លោកឪពុកក្មេកខ្ញុំគាត់ជាអតីតអ្នកបួសរៀនសាលាបាលីជាន់ខ្ពស់នៅព្រះវិហារ ព្រះកែវមរកតក្នុងវាំង។ ក្រោយ សម្តេចព្រះសង្ឃរាជ ជួន ណាត ពីរជំនាន់ឮពីប្រវត្តិរៀនសូត្ររបស់ខ្ញុំ គាត់អរណាស់ហើយក៏ព្រួយបារម្ភពីខ្ញុំដូចលោកឪពុកបង្កើតរបស់ខ្ញុំដែរ។ ខ្ញុំបានមកលេងគាត់ស្ទើររៀងរាល់ថ្ងៃ និយាយពីនេះពីនោះផងជាពិសេសបានមើលមុខអនាគតភរិយាផង។

**(តទៅលេខក្រោយ)**

រូបក្របមុខ ៖
កម្មករធ្វើផ្លូវរថភ្លើងក្នុងរបបខ្មែរក្រហមឈរអមសងខាងផ្លូវរថភ្លើង (ឆ្នាំ១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្របក្រោយ ៖
ប្រជាជនធ្វើការនៅក្នុងកងចល័តក្នុងរបបខ្មែរក្រហមដើរនៅតាមបណ្ដោយផ្លូវរថភ្លើង (ឆ្នាំ១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣
DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110
Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 291, March 2024 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.